# ព្រះពុទ្ធជាបុគ្គលដ៏អស្ចារ្យ



## បុគ្គលឯក គឺព្រះភគវន្ត

## តថាគតអរហន្តសម្មាសម្ពុទ្ធ


ប្រមូលរៀបរៀង

ដោយខ្ញុំព្រះករុណា ខ្ញុំបាទ

**ខន្តិរាម វ៉េន តិរម្យ អម្ពវនារាមិក**



ថ្ងៃសៅរ៍ ៨កើត ខែមិគសិរ ព.ស.២៥៥៥

# មាតិកា


| | |
|---|---|
| នមក្ការ រតនត្តយស្ស | ១ |
| ឯកបុគ្គលវគ្គ បាលី-ប្រែ | ២ |
| មនោរថបូរណី អដ្ឋកថា | ១៣ |
| អដ្ឋកថាសូត្រទី១ | ១៣ |
| សច្ចៈមានពីរយ៉ាង | ១៥ |
| បុគ្គលកថា ដោយហេតុ៨ប្រការ | ១៦ |
| អត្ថរបស់ឯកបុគ្គល មាន៣អត្ថ | ២០ |
| មជ្ឈិមប្រទេស | ២២ |
| ពាក្យថា ឧប្បជ្ជមានោ ឧប្បជ្ជតិ | ២៣ |
| ពាក្យថា លោកានុកម្បាយ | ២៧ |
| ពាក្យសួរ មាន៥ប្រការ | ៣១ |
| ពាក្យថាតថាគតោ មានហេតុ៨យ៉ាង | ៣៤ |
| ពាក្យថាអរហំ មានហេតុ៥យ៉ាង | ៦៥ |
| ពាក្យថាសម្មាសម្ពុទ្ធោ | ៧៦ |
| អដ្ឋកថាសូត្រទី២ | ៨២ |
| អដ្ឋកថាសូត្រទី៣ | ៨៤ |
| អដ្ឋកថាសូត្រទី៤ | ៩២ |
| អដ្ឋកថាសូត្រទី៥ | ៩៣ |
| អដ្ឋកថាសូត្រទី៦-១៧ | ៩៧ |
| បដិសម្ភិទាវិភង្គ | ១០២ |
| សម្មោហវិនោទនី ពណ៌នាសង្ខេបវារៈ | ១០៦ |
| ពណ៌នាសច្ចវារៈជាដើម | ១១៨ |

# ព្រះពុទ្ធជាបុគ្គលដ៏អស្ចារ្យ

## **នមត្ថុ រតនត្តយស្ស**

*កិរិយានមស្ការនៃខ្ញុំ សូមមានចំពោះប្រជុំបីនៃរត្ន ជាគ្រឿងត្រេកអររបស់ពួកជនអ្នកត្រូវការព្រះនិព្វាន*

**អរហំ សម្មាសម្ពុទ្ធោ ភគវា** *ព្រះមានព្រះភាគ ព្រះអង្គឆ្ងាយចាកកិលេសហើយ ត្រាស់ដឹងនូវព្រះធម៌ទាំងពួង ដោយប្រពៃនិងដោយព្រះអង្គឯង,* **ពុទ្ធំ ភគវន្តំ អភិវាទេមិ** *ខ្ញុំព្រះករុណាសូមក្រាបបង្គំ នូវព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ហើយ។*

**ស្វាក្ខាតោ ភគវតា ធម្មោ** *ព្រះធម៌ ដែលព្រះមានព្រះភាគសម្តែងប្រពៃហើយ,* **ធម្មំ នមស្សាមិ** *ខ្ញុំព្រះករុណាសូមក្រាបបង្គំ នូវព្រះធម៌។*

**សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃសាវកនៃព្រះមានព្រភាគ លោកបដិបត្តិប្រពៃហើយ,* **សង្ឃំ វន្ទាមិ** *ខ្ញុំព្រះករុណាសូមក្រាបបង្គំ នូវព្រះសង្ឃ។*

## ឯកបុគ្គលវគ្គ

**១៧០. ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ។ កតមោ ឯកបុគ្គលោ? តថាគតោ អរហំ សម្មាសម្ពុទ្ធោ។ អយំ ខោ ភិក្ខវេ ឯកបុគ្គលោ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ។**

១៧០. ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វ-លោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកនេះឯង កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដី

ចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិង មនុស្សទាំងឡាយ។

**១៧១. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវោ ទុល្លភោ លោកស្មឹ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវោ ទុល្លភោ លោកស្មឹ**

១៧១. ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯក រកបានដោយកម្រក្នុងលោក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯកនេះឯង រកបានដោយកម្រក្នុងលោក។

**១៧២. ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ អច្ឆរិយមនុស្សោ កតមោ ឯកបុគ្គលោ? តថាគតោ អរហំ សម្មាសម្ពុទ្ធោ អយំ ខោ ភិក្ខវេ ឯកបុគ្គលោ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ អច្ឆរិយមនុស្សោ**

១៧២. ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ជាមនុស្សអស្ចារ្យ។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុ

ទាំងឡាយ បុគ្គលឯកនេះឯង កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងជាមនុស្សអស្ចារ្យ។

**១៧៣. ឯកបុគ្គលស្ស ភិក្ខវេ កាលកិរិយា ពហុនោ ជនស្ស អនុតប្បា ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស កាលកិរិយា ពហុនោ ជនស្ស អនុតប្បា ហោតិ។**

១៧៣. ម្នាលភិក្ខុទាំងឡាយ កាលកិរិយានៃបុគ្គលឯក ជាទីសោកស្តាយនៃជនច្រើន។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ កាលកិរិយានៃបុគ្គលឯកនេះឯង ជាទីសោកស្តាយនៃជនច្រើន។

**១៧៤. ឯកបុគ្គលោ ភិក្ខវេ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ អទុតិយោ អសហាយោ អប្បដិមោ អប្បដិសមោ អប្បដិភាគោ អប្បដិបុគ្គលោ អសមោ អសមសមោ ទ្វិបទានំ អគ្គោ។ កតមោ ឯកបុគ្គលោ? តថាគតោ អរហំ សម្មាសម្ពុទ្ធោ ។ អយំ ខោ ភិក្ខវេ ឯកបុគ្គលោ លោកេ ឧប្បជ្ជមានោ ឧប្បជ្ជតិ អទុតិយោ អសហាយោ អប្បដិមោ អប្បដិសមោ អប្បដិភាគោ អប្បដិបុគ្គលោ អសមោ អសមសមោ ទ្វិបទានំ អគ្គោ។**

១៧៤. ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើង ក្នុងលោក ក៏រមែងកើតឡើង មិនមានអ្នកជាគម្រប់ពីរ មិនមានសំឡាញ់ មិនមានអ្នកមានអត្តភាពដូច មិនមានអ្នកដូចដោយអត្តភាព ជាអ្នកបែកចែកចំណែកធម៌មិនមានអ្នកចាប់កំហុសបាន មិនមានបុគ្គលប្រៀបផ្ទឹមបាន មិនមានបុគ្គលស្មើ ស្មើតែនឹងបុគ្គលដែលឥតគេស្មើ ប្រសើរបំផុតជាងពួកសត្វមានជើងពីរ។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកនេះឯង កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង មិនមានអ្នកជាគម្រប់ពីរ មិនមានសំឡាញ់ មិនមានអ្នកមានអត្តភាពដូច មិនមានអ្នកដូចដោយអត្តភាព ជាអ្នកបែងចែកចំណែកធម៌មិនមានអ្នកចាប់កំហុសបាន មិនមានបុគ្គលប្រៀបផ្ទឹមបាន មិនមានបុគ្គលស្មើ ស្មើតែនឹងបុគ្គលដែលឥតគេស្មើ ប្រសើរបំផុតជាងពួកសត្វមានជើងពីរ។

**១៧៥. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា[1] មហតោ ចក្ខុ-**

1 **ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា មហតោ ចក្ខុស្ស បាតុភាវោ ហោតីតិ** ភិក្ខវេ ឯកបុគ្គលស្ស តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវេន មហន្តស្ស ចក្ខុស្ស បាតុភាវោ ហោតិ។ តស្មិំ បុគ្គលេ បាតុភូតេ តំ បាតុភូតមេវ ហោតិ។ (អដ្ឋកថា)

**ស្ស បាតុភាវោ ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថា-គតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯក-បុគ្គលស្ស បាតុភាវា មហតោ ចក្ខុស្ស បាតុភាវោ ហោតិ។**

១៧៥. ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបញ្ញា-ចក្ខុដ៏ប្រសើរ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ ការកើតប្រាកដនៃបុគ្គលឯក គឺនរណា? គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបញ្ញាចក្ខុដ៏ប្រសើរ រមែងមាន ព្រោះការកើតប្រាកដ នៃបុគ្គលឯកនេះឯង។

**១៧៦. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា មហតោ អាលោកស្ស បាតុភាវោ ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវា មហតោ អាលោកស្ស បាតុភាវោ ហោតិ។**

១៧៦. ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃពន្លឺបញ្ញាដ៏ប្រសើរ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដ នៃពន្លឺបញ្ញាដ៏ប្រសើរ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៧៧. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា មហតោ ឱភាសស្ស បាតុភាវោ ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវា មហតោ ឱភាសស្ស បាតុភាវោ ហោតិ។**

១៧៧. ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃរស្មីបញ្ញាដ៏ប្រសើរ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃរស្មីបញ្ញាដ៏ប្រសើរ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៧៨. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា ឆន្នំ អនុត្តរិយានំ បាតុភាវោ ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវា ឆន្នំ អនុត្តរិយានំ បាតុភាវោ ហោតិ។**

១៧៨. ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃអនុត្តរិយៈ៦ប្រការ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក

។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃអនុត្តរិយៈ៦ប្រការ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៧៩. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា ចតុន្នំ បដិសម្ភិទានំ សច្ឆិកិរិយា ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវា ចតុន្នំ បដិសម្ភិទានំ សច្ឆិកិរិយា ហោតិ។**

១៧៩. ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា៤ប្រការ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា៤ប្រការ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៨០. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា អនេកធាតុបដិវេធោ ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវា អនេកធាតុបដិវេធោ ហោតិ។**

១៨០. ម្នាលភិក្ខុទាំងឡាយ ការត្រាស់ដឹងនូវធាតុច្រើនប្រការ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការត្រាស់ដឹងនូវធាតុច្រើនប្រការ រមែងមាន ព្រោះការកើតប្រាកដ នៃបុគ្គលឯកនេះឯង។

**១៨១. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា នានាធាតុបដិវេធោ ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវា នានាធាតុបដិវេធោ ហោតិ។**

១៨១. ម្នាលភិក្ខុទាំងឡាយ ការត្រាស់ដឹងនូវធាតុផ្សេងៗ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការត្រាស់ដឹងនូវធាតុផ្សេងៗ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៨២. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា វិជ្ជាវិមុត្តិផលសច្ឆិកិរិយា ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស**

**ចាតុភាវា វិជ្ជាវិមុត្តិផលសច្ឆិកិរិយា ហោតិ។**

១៨២. ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា និងវិមុត្តិផល រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិផល រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៨៣. ឯកបុគ្គលស្ស ភិក្ខវេ ចាតុភាវា សោតាបត្តិផលសច្ឆិកិរិយា ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស ចាតុភាវា សោតាបត្តិផលសច្ឆិកិរិយា ហោតិ។**

១៨៣. ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលរមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៨៤. ឯកបុគ្គលស្ស ភិក្ខវេ ចាតុភាវា សកទាគាមិផលសច្ឆិកិរិយា ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថាគត-**

**ស្ស អរហតោ សម្មាសម្ពុទ្ធស្សៈ ឥមស្ស ខោ ភិក្ខវេ ឯក-បុគ្គលស្ស បាតុភាវា សកទាគាមិផលសច្ឆិកិរិយា ហោតិៈ**

១៨៤. ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលរមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផលរមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៨៥. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា អនាគាមិផល-សច្ឆិកិរិយា ហោតិៈ កតមស្ស ឯកបុគ្គលស្ស? តថាគតស្ស អរហតោ សម្មាសម្ពុទ្ធស្សៈ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវា អនាគាមិផលសច្ឆិកិរិយា ហោតិៈ**

១៨៥. ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផលរមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៨៦. ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា អរហត្ត-ផលសច្ឆិកិរិយា ហោតិ។ កតមស្ស ឯកបុគ្គលស្ស? តថា-គតស្ស អរហតោ សម្មាសម្ពុទ្ធស្ស។ ឥមស្ស ខោ ភិក្ខវេ ឯកបុគ្គលស្ស បាតុភាវា អរហត្តផលសច្ឆិកិរិយា ហោតិ។**

១៨៦. ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក។ បុគ្គលឯក គឺនរណា? គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយ ការធ្វើឲ្យជាក់ច្បាស់ នូវអរហត្តផល រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯកនេះឯង។

**១៨៧. នាហំ ភិក្ខវេ អញ្ញំ ឯកបុគ្គលម្បិ សមនុបស្សាមិ, យោ ឯវំ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតំ សម្មទេវ អនុប្បវត្តេតិ; យថយិទំ ភិក្ខវេ សារិបុត្តោ។ សារិបុត្តោ ភិក្ខវេ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតំ សម្មទេវ អនុប្បវត្តេតីតិ។**

១៨៧. ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណារកមើលមិនឃើញ នូវបុគ្គលដទៃសូម្បីតែម្នាក់ អ្នកញ៉ាំងធម្មចក្ដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅ

ដោយត្រឹមត្រូវ ដូចជាសារីបុត្តនេះសោះឡើយ។ ម្នាលភិក្ខុទាំងឡាយ មានតែសារីបុត្តទើបញ៉ាំងធម្មចក្កដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅដោយត្រឹមត្រូវបាន។

**ឯកបុគ្គលវគ្គោ និដ្ឋិតោ**

ឯកបុគ្គលវគ្គ ចប់។

(ក្នុងបិដកលេខ៤០ ទំព័រ៤៩ ដល់៥២ បព្វៈ
ទី១៣៩-១៤៥ ទំព័រទី៤៩-៥២ សម្តែងសរសេរ
ដោយសង្ខេប, ក្នុងទីនេះ ខ្ញុំសូមសរសេរបង្ហាញ
ដោយពិស្តារតាមច្បាប់ឆដ្ឋសង្គាយនា អង្គុត្តរនិកាយ
ឯកកនិបាត ឯកបុគ្គលវគ្គ បព្វៈទី១៧០ ដល់១៨៧
គឺមានព្រះសូត្រប្រមាណ ១៨សូត្រ)

# មនោរថបូរណី

# អដ្ឋកថាអង្គុត្តរនិកាយ

# ឯកកនិបាត ឯកបុគ្គលវគ្គ

(លេខបញ្ញៈច្បាប់ឆដ្ឋសង្គាយនា)

## អដ្ឋកថាសូត្រទី១

១៧០. ឯកបុគ្គលវគ្គ សូត្រទី១ មានវិនិច្ឆ័យដូចទៅនេះ៖

បទថា **ឯកបុគ្គលោ** = ឯកោ បុគ្គលោ។ បទថា **ឯកោ** ក្នុងទីនេះ ជាការកំណត់ចំនួន ដែលមានសេចក្តីបដិសេធអ្នកទីពីរជាដើម។ បទថា **បុគ្គលោ** ជាពាក្យនិយាយដោយសន្មតមិនមែនជាពាក្យនិយាយដោយបរមត្ថទេ។ ពិតមែន ទេសនារបស់ព្រះពុទ្ធដ៏មានព្រះភាគ មាន២យ៉ាង គឺសម្មតិទេសនា១ បរមត្ថទេសនា១ ។ បណ្តាទេសនាទាំង២នោះ ទេសនាមានសភាពបែបនេះថា "បុគ្គល ស្រី ប្រុស ខត្តិយៈ ព្រាហ្មណ៍ ទេវតា មារ" ជាដើម ឈ្មោះថា **សម្មតិទេសនា**។ ទេសនាមានសភាពបែបនេះថា "អនិច្ចំ ទុក្ខំ អនត្តា ខន្ធ ធាតុ អាយតនៈ សតិបដ្ឋាន" ជាដើម ឈ្មោះថា **បរមត្ថទេសនា**។ ទេសនាទាំង២នេះ សត្វទាំងឡាយណា ស្តាប់នូវទេសនា ដោយអំណាចនៃការសន្មត អាចដើម្បីចាក់ធ្លុះនូវអត្ថ លះបង់នូវ

មោហៈ សម្រេចនូវគុណវិសេសបាន, ព្រះភគវាទ្រង់សម្តែង សម្មុតិទេសនា ដល់សត្វទាំងឡាយនោះ។ តែបើសត្វទាំងឡាយណា ស្តាប់នូវទេសនា ដោយអំណាចនៃបរមត្ថ អាចដើម្បីចាក់ធ្លុះនូវអត្ថ លះបង់នូវមោហៈ សម្រេចនូវគុណវិសេសបាន, ព្រះភគវាទ្រង់សម្តែងសម្មតិទេសនា ដល់សត្វទាំងឡាយនោះ។

ក្នុងរឿងនេះ គប្បីជ្រាបឧបមាដូចតទៅនេះថា៖ ដូចគ្រូអាចារ្យដែលឈ្លាសក្នុងទេសភាសា(កថាក្នុងប្រទេស តំបន់) ពណ៌នាសេចក្តីនៃត្រៃវេទ ពួកជនណា កាលបើគាត់និយាយដោយភាសាទមិឡ តែងដឹងសេចក្តីបាន, គាត់តែងតែប្រាប់ដោយភាសាទមិឡ ដល់ពួកជននោះ; ពួកជនណា តែងដឹងសេចក្តីបាន ដោយបណ្តាភាសាទាំងឡាយ មានអន្ធភាសាណាមួយ, គាត់តែងតែប្រាប់ ដោយភាសានោះៗ ដល់ពួកជននោះ យ៉ាងណា; ពួកមាណព(អ្នកសិក្សា) បានអាស្រ័យអាចារ្យដែលឈ្លាសវាងវៃហើយ តែងរៀននូវសិល្បវិជ្ជាបានដោយឆាប់រហ័ស ក៏យ៉ាងនោះដែរ។ ក្នុងពាក្យឧបមានោះ ព្រះពុទ្ធដ៏មានជោគ លោកប្រៀបដូចគ្រូអាចារ្យ, ព្រះត្រៃបិដកដែលព្រះអង្គឋិតនៅ ក្នុងភាពគឺទ្រង់គប្បីសម្តែង ប្រៀបដូច

ត្រៃវេទ, ភាពឈ្លាសវៃក្នុងសម្មតិទេសនានិងបរមត្ថទេសនា (របស់ទ្រង់) ប្រៀបដូចភាពឈ្លាសវៃក្នុងទេសភាសា (របស់អាចារ្យ), ពួកវេនេយ្យសត្វដែលអាចចាក់ធ្លុះ ដោយអំណាចនៃសម្មតិនិងបរមត្ថ ប្រៀបដូចពួកមាណពអ្នកដឹងទេសភាសាផ្សេងៗ (គឺភាសាដែលខ្លួនអាចដឹងបាន), ការសម្តែងដោយអំណាចនៃសម្មុតិនិងបរមត្ថ របស់ព្រះភគវា ប្រៀបដូចការបង្រៀនដោយភាសាទមិឡជាដើម របស់អាចារ្យ។ សមដូចលោកពោលទុកក្នុងទីនេះថា៖

ទុវេ សច្ចានិ អក្ខាសិ, សម្ពុទ្ធោ វទតំ វរោ;
សម្មុតឹ បរមត្ថញ្ច, តតិយំ នុបលព្ភតិ។

ព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រសើរជាងពួកអ្នកប្រាជ្ញខាងសម្តី ទ្រង់បានត្រាស់សច្ចៈ២ប្រការ គឺសម្មតិ-សច្ចៈ១ បរមត្ថសច្ចៈ១, គឺគេមិនបានសច្ចៈទី៣ទេ។

សង្កេតវចនំ សច្ចំ, លោកសម្មុតិការណា;
បរមត្ថវចនំ សច្ចំ, ធម្មានំ ភូតការណា។

ពាក្យសង្កេត ជាសច្ចៈ ព្រោះហេតុពិតនៃការសន្មតរបស់លោក, ពាក្យបរមត្ថ ជាសច្ចៈ ព្រោះហេតុពិតរបស់ធម៌ទាំងឡាយ។

តស្មា វោហារកុសលស្ស, លោកនាថស្ស សត្ថុនោ;
សម្មុតឹ វោហរន្តស្ស, មុសាវាទោ ន ជាយតិ។

ព្រោះហេតុនោះ មុសាវាទ ទើបមិនមាន ដល់ព្រះបរមលោកនាថទ្រង់ឈ្លាសក្នុងវោហារ ជាសាស្ដាចារ្យ (របស់សត្វលោក) ដែលត្រាស់វោហារដោយសន្មត។

ម្យ៉ាងទៀត ព្រះភគវាទ្រង់ត្រាស់បុគ្គលកថា ដោយហេតុ៨ប្រការ គឺដើម្បីបំភ្លឺហិរិនិងឱត្តប្បៈ១ ដើម្បីបំភ្លឺកម្ម-ស្សកតា (ភាវៈនៃសត្វមានកម្មជារបស់ខ្លួន)១ ដើម្បីបំភ្លឺការធ្វើរបស់បុរសចំពោះខ្លួន១ ដើម្បីបំភ្លឺអនន្តរិយកម្ម១ ដើម្បីបំភ្លឺព្រហ្មវិហារ១ ដើម្បីបំភ្លឺបុព្វេនិវាស១ ដើម្បីបំភ្លឺទក្ខិណាវិសុទ្ធិ១ ដើម្បីការមិនលះបង់នូវការសន្មតរបស់លោក១ ។ មែនហើយ កាលព្រះអង្គទ្រង់ត្រាស់ថា "ខន្ធ ធាតុ អាយតនៈខ្មាស់បាប ខ្លាចបាប" ដូច្នេះ មហាជនតែងមិនដឹង តែងដល់នូវការវង្វេង, ត្រឡប់ជាសត្រូវថា "នេះជាអ្វី? ខន្ធ ធាតុអាយតនៈ ឈ្មោះថាខ្មាស់បាប ខ្លាចបាប"។ តែបើទ្រង់ត្រាស់ថា "ស្រី ប្រុស ខត្តិយៈ ព្រាហ្មណ៍ ទេវតា មារ ខ្មាស់បាបខ្លាចបាប" ដូច្នេះ មហាជនទើបដឹង មិនដល់នូវការវង្វេង, មិនត្រឡប់ជាសត្រូវ។ ព្រោះហេតុនោះ ព្រះភគវាទើបត្រាស់

នូវបុគ្គលកថា **ដើម្បីបំភ្លឺហិរិនិងឱត្តប្បៈ។**

សូម្បីកាលព្រះអង្គទ្រង់ត្រាស់ថា "ខន្ធ ធាតុ អាយតនៈ មានកម្មជារបស់ខ្លួន" ដូច្នេះ មហាជនតែងមិនដឹង តែងដល់នូវការវង្វេង, ត្រឡប់ជាសត្រូវថា "នេះជាអី? ខន្ធ ធាតុ អាយតនៈ ឈ្មោះថាមានកម្មជារបស់ខ្លួន"។ តែបើទ្រង់ត្រាស់ថា "ស្រី ប្រុស ខត្តិយៈ ព្រាហ្មណ៍ ទេវតា មារ មានកម្មជារបស់ខ្លួន" ដូច្នេះ មហាជនទើបដឹង មិនដល់នូវការវង្វេង, មិនត្រឡប់ជាសត្រូវ។ ព្រោះហេតុនោះ ព្រះភគវាទើបត្រាស់នូវបុគ្គលកថា **ដើម្បីបំភ្លឺកម្មស្សកតា។**

សូម្បីកាលព្រះអង្គទ្រង់ត្រាស់ថា "ខន្ធ ធាតុ អាយតនៈ ឲ្យជាងកសាងវិហារធំមានវេឡុវ័នជាដើម" ដូច្នេះ មហាជនតែងមិនដឹង តែងដល់នូវការវង្វេង, ត្រឡប់ជាសត្រូវថា "នេះជាអី? ខន្ធ ធាតុ អាយតនៈ ឈ្មោះថាឲ្យជាងកសាងវិហារ"។ តែបើទ្រង់ត្រាស់ថា "ព្រះបាទពិម្ពិសារ ឲ្យជាងកសាងវត្តវេឡុវ័ន, អនាថបិណ្ឌិកសេដ្ឋី ឲ្យជាងកសាងវត្តជេតពន" ដូច្នេះ មហាជនទើបដឹង មិនដល់នូវការវង្វេង, មិនត្រឡប់ជាសត្រូវ។ ព្រោះហេតុនោះ ព្រះភគវាទើបត្រាស់នូវបុគ្គលកថា **ដើម្បីបំភ្លឺការធ្វើរបស់បុរសចំពោះខ្លួន។**

សូម្បីកាលព្រះអង្គទ្រង់ត្រាស់ថា "ខន្ធ ធាតុ អាយតនៈ ផ្តាច់ជីវិតមាតា បិតា ព្រះអរហន្ត, ធ្វើព្រះលោហិតឲ្យពុះពង, ធ្វើការបំបែកសង្ឃ" ដូច្នេះ មហាជនតែងមិនដឹង តែងដល់នូវការវង្វេង, ត្រឡប់ជាសត្រូវថា "នេះជាអ្វី? ខន្ធ ធាតុ អាយតនៈ ឈ្មោះថាធ្វើអនន្តរិយកម្ម"។ តែបើទ្រង់ត្រាស់ថា "ព្រះបាទអជាតសត្តុសម្លាប់ព្រះបាទពិម្ពិសារ ជាបិតារបស់ខ្លួន, អតីតៈព្រះមហាមោគ្គល្លានសម្លាប់មាតាបិតា, ពួកតិរ្ថិយសម្លាប់ពួកព្រះអរហន្ត, ភិក្ខុទេវទត្តធ្វើរុហិរុប្បាទកម្ម និងសង្ឃភេទកម្ម" ដូច្នេះ មហាជនទើបដឹង មិនដល់នូវការវង្វេង, មិនត្រឡប់ជាសត្រូវ។ ព្រោះហេតុនោះ ព្រះភគវាទើបត្រាស់នូវបុគ្គលកថា **ដើម្បីបំភ្លឺអនន្តរិយកម្ម។**

សូម្បីកាលព្រះអង្គទ្រង់ត្រាស់ថា "ខន្ធ ធាតុ អាយតនៈ មានមេត្តា" ដូច្នេះ មហាជនតែងមិនដឹង តែងដល់នូវការវង្វេង, ត្រឡប់ជាសត្រូវថា "នេះជាអ្វី? ខន្ធ ធាតុ អាយតនៈ ឈ្មោះថាមានមេត្តា"។ តែបើទ្រង់ត្រាស់ថា "នាងសាមាវតីមានមេត្តាធំធេង ជាងពួកឧបាសិកាឯទៀត" ដូច្នេះ មហាជនទើបដឹង មិនដល់នូវការវង្វេង, មិនត្រឡប់ជាសត្រូវ។ ព្រោះហេតុនោះ ព្រះភគវាទើបត្រាស់នូវបុគ្គលកថា **ដើម្បីបំភ្លឺ**

**ព្រហ្មវិហារ។**

សូម្បីកាលព្រះអង្គទ្រង់ត្រាស់ថា "ខន្ធ ធាតុ អាយតនៈ រលឹកនូវបុព្វេនិវាស" ដូច្នេះ មហាជនតែងមិនដឹង តែងដល់នូវការវង្វេង, ត្រឡប់ជាសត្រូវថា "នេះជាអ្វី? ខន្ធ ធាតុ អាយតនៈ ឈ្មោះថារលឹកនូវបុព្វេនិវាស"។ តែបើទ្រង់ត្រាស់ថា "ព្រះសោភិតៈរលឹកជាតិបានច្រើន ជាងពួកភិក្ខុឯទៀត" ដូច្នេះ មហាជនទើបដឹង មិនដល់នូវការវង្វេង, មិនត្រឡប់ជាសត្រូវ។ ព្រោះហេតុនោះ ព្រះភគវាទើបត្រាស់ នូវបុគ្គលកថា **ដើម្បីបំភ្លឺបុព្វេនិវាស។**

សូម្បីកាលព្រះអង្គទ្រង់ត្រាស់ថា "ខន្ធ ធាតុ អាយតនៈ កំពុងតែទទួលទាន" ដូច្នេះ មហាជនតែងមិនដឹង តែងដល់នូវការវង្វេង, ត្រឡប់ជាសត្រូវថា "នេះជាអ្វី? ខន្ធ ធាតុ អាយតនៈ ឈ្មោះថាទទួលទាន"។ តែបើទ្រង់ត្រាស់ថា "ពួកបុគ្គលអ្នកមានសីល មានធម៌ល្អទទួលទាន" ដូច្នេះ មហាជនទើបដឹង មិនដល់នូវការវង្វេង, មិនត្រឡប់ជាសត្រូវ ។ ព្រោះហេតុនោះ ព្រះភគវាទើបត្រាស់ នូវបុគ្គលកថា **ដើម្បីបំភ្លឺទក្ខិណាវិសុទ្ធិ។**

ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់មិនលះបង់ នូវការសន្មតរបស់សត្វលោក ទ្រង់ឋិតក្នុងលោកសមញ្ញា (ឈ្មោះនៃសត្វលោក) ក្នុងលោកនិរុត្តិ (ភាសានៃសត្វលោក) ក្នុងលោកាភិលាប (ការចរចានៃសត្វលោក)នោះឯង ទើបទ្រង់សម្ដែងធម៌។ ព្រោះហេតុនោះ ព្រះភគវាទើបត្រាស់ នូវបុគ្គលកថា **ដើម្បីការមិនលះបង់នូវសន្មតរបស់លោក**។

ដោយប្រការដូច្នេះ ដែលឈ្មោះថាបុគ្គលឯក ព្រោះបុគ្គលនោះ មានតែមួយ។ កេនដ្ឋេន ឯកបុគ្គលោ? បុគ្គលឯកដោយអត្ថថាដូចម្ដេច? គឺអសទិសដ្ឋេន ដោយអត្ថថាមិនដូច ១ គុណវិសិដ្ឋដ្ឋេន ដោយអត្ថថាវិសេសដោយគុណ១ អសមសមដ្ឋេន ដោយអត្ថថាស្មើគ្នាតែនឹងបុគ្គលដែលឥតគេស្មើ១ ។ សេចក្ដីថា ព្រះអង្គទ្រង់មិនដូចនឹងមហាជនដ៏សេសដោយពោធិសម្ភារគុណទាំងឡាយ រាប់តាំងពីការពិចារណានូវបារមីទាំង១០ តាមលំដាប់មក និងដោយពុទ្ធគុណទាំងឡាយ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថាបុគ្គលឯក **ដោយអត្ថថាមិនដូច**។ ព្រះអង្គទ្រង់មានព្រះគុណទាំងឡាយវិសេសជាងគុណទាំងឡាយ របស់ពួកសត្វដ៏សេស ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថាបុគ្គលឯក **ដោយអត្ថថា**

**វិសេសដោយគុណ។** ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គមុនៗ ទ្រង់មិនស្មើ ដោយសត្វគ្រប់ជំពូក, ព្រះអង្គ(បរមគ្រូនៃយើង) តែមួយអង្គនេះឯង ទើបស្មើនឹងសម្មាសម្ពុទ្ធទាំងឡាយអង្គមុននោះ ដោយគុណគឺរូបកាយផង ដោយគុណគឺនាមកាយផង ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថាបុគ្គលឯក **ដោយអត្ថថាស្មើគ្នាតែនឹងបុគ្គលដែលឥតគេស្មើ។**

បទថា **លោកេ** បានដល់ លោក៣ គឺសត្តលោក១ ឱកាសលោក១ សង្ខារលោក១ ។ កថាពោលដោយពិស្តារនៃលោកទាំង៣នោះ (គឺខ្ញុំពុទ្ធឃោស) ពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គរួចហើយ។ បណ្តាលោកទាំង៣នោះ ក្នុងទីនេះ សត្តលោក គឺលោកប៉ងយកហើយ។ ឯព្រះតថាគតនុ៎ះ សូម្បីទ្រង់កើតឡើងក្នុងសត្តលោក ទ្រង់កើតឡើងក្នុងទេវលោកក៏មិនមែន, កើតឡើងក្នុងព្រហ្មលោក ក៏មិនមែន, គឺទ្រង់កើតឡើងក្នុងមនុស្សលោកប៉ុណ្ណោះ។ សូម្បីក្នុងមនុស្សលោក ក៏ទ្រង់មិនកើតឡើងក្នុចក្កវាឡដទៃដែរ គឺទ្រង់កើតឡើងតែក្នុងចក្កវាឡនេះប៉ុណ្ណោះ។ សូម្បីក្នុងចក្កវាឡនេះ ក៏ទ្រង់មិនចេះតែកើតឡើងក្នុងទីទាំងពួងដែរ។

ក្នុងទិសខាងកើត មាននិគមឈ្មោះគជង្គលៈ, បន្ទាប់ពីនោះ មាននគរឈ្មោះមហាសាល, បន្ទាប់ពីនោះ ជាបច្ចន្តជនបទ, រួមចូលខាងក្នុងមក ជាមជ្ឈិមប្រទេស។ ក្នុងទិសអាគ្នេយ៍ មានស្ទឹងឈ្មោះសល្លវតី, បន្ទាប់ពីនោះ ជាបច្ចន្តជនបទ, រួមចូលខាងក្នុងមក ជាមជ្ឈិមប្រទេស។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះសេតកណ្ណិកៈ, បន្ទាប់ពីនោះជាបច្ចន្តជនបទ, រួមចូលខាងក្នុងមក ជាមជ្ឈិមប្រទេស។ ក្នុងទិសខាងលិច មានស្រុករបស់ពួកព្រាហ្មណ៍ឈ្មោះថូណៈ*, បន្ទាប់ពីនោះ ជាបច្ចន្តជនបទ, រួមចូលខាងក្នុងមក ជាមជ្ឈិមប្រទេស។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរទ្ធជៈ, បន្ទាប់ពីនោះ ជាបច្ចន្តជនបទ, រួមចូលខាងក្នុងមក ជាមជ្ឈិមប្រទេស។ ព្រះតថាគតទ្រង់កើតឡើង តែក្នុងមជ្ឈិម-ប្រទេស ដែលលោកកំណត់ទុក ដូចពោលមកហើយនោះ ដោយបណ្តោយ ៣០០យោជន៍ ដោយទទឹង ២៥០យោជន៍ ដោយជុំវិញ ៩០០យោជន៍។ មិនមែនតែព្រះតថាគតប៉ុណ្ណោះទេ, ព្រះបច្ចេកពុទ្ធ អគ្គសាវក អសីតិមហាថេរ ពុទ្ធមាតា ពុទ្ធបិតា ស្តេចចក្កពត្តិ និងព្រាហ្មណ៍គហបតី ដែលជាបុគ្គលសំខាន់ដទៃទៀត ក៏កើតឡើងតែក្នុងមជ្ឈិមប្រទេសនេះឯង។

ក៏ឯពីរបទនេះថា **ឧប្បជ្ជមានោ ឧប្បជ្ជតិ** ជាពាក្យដែលលោកធ្វើឲ្យប្លែកមែន។ ក៏ក្នុងពាក្យនេះ អ្នកសិក្សាគប្បីជ្រាបសេចក្តីយ៉ាងនេះថា "ព្រះតថាគតកាលកើតឡើង រមែងកើតឡើង ដើម្បីប្រយោជន៍ដល់ជនច្រើន, មិនមែនដោយហេតុដទៃទេ"។ ឯអធិការនេះ លក្ខណៈមានសភាពបែបនេះ អ្នកណាមួយ មិនអាចហាមឃាត់នូវពាក្យទាំងពីរនុ៎ះ ដោយលក្ខណៈនៃសព្ទដទៃទេ។

មួយទៀត សេចក្តីផ្សេងគ្នាក្នុងពាក្យទាំងនេះ គប្បីជ្រាបដូច្នេះថា "ឧប្បជ្ជមានោ នាម (ឈ្មោះថាកាលកើតឡើង), ឧប្បជ្ជតិ នាម (ឈ្មោះថាកំពុងកើតឡើង), ឧប្បន្នោ នាម (ឈ្មោះថាកើតឡើងហើយ)។ សេចក្តីពិស្តារថា ព្រះតថាគតអង្គនោះ ទ្រង់បានទទួលព្យាករណ៍ ចាប់តាំងពីព្រះបាទមូលរបស់ព្រះពុទ្ធទីបង្ករមក ទ្រង់កាលស្វែងរកនូវពុទ្ធការកធម៌ ក៏បានឃើញនូវបារមីទាំងឡាយ១០ បានមានសេចក្តីពេញចិត្តគិតថា "អាត្មាអញត្រូវតែបំពេញធម៌ទាំងនេះ" សូម្បីកាលបំពេញទានបារមី ក៏ឈ្មោះថា **កាលកើតឡើង**, សូម្បីកាលបំពេញសីលបារមី ក៏ឈ្មោះថា **កាលកើតឡើង**, សូម្បីកាលបំពេញនេក្ខម្មបារមី ក៏ឈ្មោះថា **កាលកើតឡើង**, សូម្បីកាល

បំពេញបញ្ញាបារមី ក៏ឈ្មោះថា **កាលកើតឡើង**, សូម្បីកាលបំពេញវីរិយបារមី ក៏ឈ្មោះថា **កាលកើតឡើង**, សូម្បីកាលបំពេញខន្តិបារមី ក៏ឈ្មោះថា **កាលកើតឡើង**, សូម្បីកាលបំពេញសច្ចបារមី ក៏ឈ្មោះថា **កាលកើតឡើង**, សូម្បីកាលបំពេញអធិដ្ឋានបារមី ក៏ឈ្មោះថា **កាលកើតឡើង**, សូម្បីកាលបំពេញមេត្តាបារមី ក៏ឈ្មោះថា **កាលកើតឡើង**, សូម្បីកាលបំពេញឧបេក្ខាបារមី ក៏ឈ្មោះថា **កាលកើតឡើង**; សូម្បីកាលបំពេញឧបបារមី១០ ក៏ឈ្មោះថា **កាលកើតឡើង**; សូម្បីកាលបំពេញបរមត្ថបារមី១០ ក៏ឈ្មោះថា **កាលកើតឡើង**។ សូម្បីកាលលះបង់នូវមហាបរិច្ចាគ៥ ក៏ឈ្មោះថា **កាលកើតឡើង**។ សូម្បីកាលបំពេញអត្តត្ថចរិយា ញាតត្ថចរិយា លោកត្ថចរិយា ក៏ឈ្មោះថា **កាលកើតឡើង**។ សូម្បីកាលញ៉ាំងពុទ្ធការកធម៌ឲ្យដល់ទីបំផុត អស់បួនអសង្ខេយ្យមួយសែនមហាកប្ប ក៏ឈ្មោះថា **កាលកើតឡើង**។ សូម្បីកាលលះបង់នូវអត្តភាពជាវេស្សន្តរ ហើយចាប់បដិសន្ធិ ក្នុងតុសិតបុរី ឋិតនៅអស់ ៥៧កោដិ ៦លានឆ្នាំ(មនុស្ស) ក៏ឈ្មោះថា **កាលកើតឡើង**។ ព្រះអង្គដែលពួកទេវតាអារាធនាហើយ សូម្បីកាលប្រមើលមើលមហាវិលោកនៈ៥ ហើយចុះ

ចាប់បដិសន្ធិក្នុងព្រះឧទរ របស់មហាមាយាទេវី នៅក្នុងព្រះគភ៌អស់១០ខែ មិនខ្វះមិនលើស ក៏ឈ្មោះថា **កាលកើតឡើង** ។ សូម្បីកាលទ្រង់ឋិតនៅកណ្តាលនិវេសន៍ អស់២៩ឆ្នាំ ក៏ឈ្មោះថា **កាលកើតឡើង**។ សូម្បីកាលទ្រង់ឃើញទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ មានឆន្ទជាសម្លាញ់ ទ្រង់ឡើងកាន់យានដ៏ប្រសើរគឺសេះកណ្ឋកៈ[2] យាងចេញសាងអភិនេស្រ្កម ក្នុងថ្ងៃប្រសូតរបស់រាហុលដ៏ចម្រើន ក៏ឈ្មោះថា **កាលកើតឡើង**។ សូម្បីកាលទ្រង់ឈានកន្លងនូវរជ្ជសីមាបី (អស់តែមួយរាត្រី) និងបួសទៀបឆ្នេរនៃស្ទឹងអនោមា ក៏ឈ្មោះថា **កាលកើតឡើង**។ សូម្បីកាលទ្រង់ធ្វើនូវមហាបធាន អស់៦ឆ្នាំ ក៏ឈ្មោះថា **កាលកើតឡើង**។ នាកាលញាណដល់នូវការចាស់ក្លា សូម្បីកាលទ្រង់នាំមកនូវអាហារដ៏គ្រោតគ្រាត ក៏ឈ្មោះថា **កាលកើតឡើង**។ សូម្បីកាលទ្រង់ឡើង កាន់មហាពោធិមណ្ឌដ្ឋាន ក្នុងថ្ងៃវិសាខបុណ្ណមី វេលារសៀល ហើយកម្ចាត់នូវពលរបស់មាររួចរលឹកនូវបុព្វេនិវាស ក្នុងបឋមយាម ជម្រះនូវទិព្វចក្ខុក្នុងមជ្ឈិមយាម ពិចារណានូវបដិច្ចសមុប្បាទ ដែលមានអង្គ១២

2 កន្លែងខ្លះថា កណ្ឌកៈ។

ដោយអនុលោមបដិលោម ក្នុងបច្ឆិមយាម ហើយបានចាក់ធ្លុះនូវសោតាបត្តិមគ្គ ក៏ឈ្មោះថា**កាលកើតឡើង**។ ក្នុងខណៈសោតាបត្តិផលក្តី ក្នុងខណៈសកទាគាមិមគ្គក្តី ក្នុងខណៈសកទាគាមិផលក្តី ក្នុងខណៈអនាគាមិមគ្គក្តី ក្នុងខណៈអនាគាមិផលក្តី ក៏នៅតែឈ្មោះថា **ឧប្បជ្ជមានោ កាលកើតឡើង**។ តែក្នុងខណៈអរហត្តមគ្គ ទើបឈ្មោះថា **ឧប្បជ្ជតិ កំពុងកើតឡើង**។ ក្នុងខណៈអរហត្តផល ឈ្មោះថា **ឧប្បន្នោ កើតឡើងហើយ**។ ពិតមែនហើយ ឥទ្ធិវិធញាណជាដើមរបស់ព្រះពុទ្ធទាំងឡាយ មិនមែនកើតឡើងតាមលំដាប់ ដូចពួកសាវកទេ, គឺគុណរាសី(គំនរគុណ) មានសព្វញ្ញុតញ្ញាណជាដើមទាំងអស់ ឈ្មោះថាជាគុណមកជាមួយនឹងអរហត្តមគ្គតែម្តង។ ព្រោះហេតុនោះ គុណធម៌ទាំងនោះ ឈ្មោះថា **ឧប្បន្នា កើតឡើងហើយ** ក្នុងខណៈអរហត្តផល ព្រោះមានកិច្ចទាំងអស់សម្រេចហើយ។ ក៏ក្នុងសូត្រនេះ គប្បីជ្រាបថា "ឧប្បជ្ជតិ = កំពុងកើតឡើង" សំដៅយកខណៈអរហត្តផលនុ៎ះឯង, អត្ថក្នុងពាក្យថា ឧប្បជ្ជតិ នេះ គឺ ឧប្បន្នោ ហោតិ ។

បទថា **ពហុជនហិតាយ** សេចក្តីថា ព្រះអង្គកើតឡើងដើម្បីប្រយោជន៍ដល់ជនច្រើន។ បទថា **ពហុជនសុខាយ**

សេចក្តីថា ទ្រង់កើតឡើង ដើម្បីសេចក្តីសុខដល់ជនច្រើន។ បទថា **លោកានុកម្បាយ** សេចក្តីថា ទ្រង់អាស្រ័យនូវសេចក្តីអនុគ្រោះ ដល់សត្វលោក ទើបកើតឡើង។

សួរថា៖ ដល់សត្វលោកណា?

ឆ្លើយថា៖ ដល់សត្វដែលបានស្តាប់ធម្មទេសនា របស់ព្រះតថាគត ហើយផឹកនូវអមតបាន[3] (ទឹកអម្រឹត) ត្រាស់ដឹងនូវធម៌។ ពិតណាស់ ព្រះភគវាទ្រង់ញ៉ាំង៧សប្តាហ៍ឲ្យកន្លងទៅ នៅនាមហាពោធិមណ្ឌដ្ឋាន ហើយចេញអំពីពោធិ-មណ្ឌដ្ឋាន យាងមកដល់ឥសិបតនមិគទាយវ័ន សម្តែងធម្មចក្កប្បវត្តនសូត្រថា "ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា"ជាដើម ពួកព្រហ្មដែលរាប់បានប្រមាណ១៨កោដិ និងអញ្ញាសិកោណ្ឌញ្ញត្ថេរមានអាយុ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងថ្ងៃទី៥ ក្នុងកាលជាទីបញ្ចប់អនត្តលក្ខណសូត្រ ពួកព្រះថេរៈបញ្ចវគ្គិយ បានតាំងស៊ប់ក្នុងព្រះអរហត្តហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ បន្ទាប់ពីនោះ ទ្រង់ញ៉ាំងពួកបុរស៥៥នាក់ មានយសជាប្រធានឲ្យតាំងស៊ប់

3 អានថា អៈម៉ៈតៈបាន ប្រែថា ទឹកមិនស្លាប់ (ទឹកអម្រឹត, ព្រះនិព្វាន)។

ក្នុងព្រះអរហត្តហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ បន្ទាប់ពីនោះ ទ្រង់ញ៉ាំងពួកភទ្ទវគ្គិយ៣០នាក់ ឲ្យបានសម្រេចមគ្គ៣ ផល៣ ហើយ, ទ្រង់កើតឡើងដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងគយាសីសប្រទេសក្នុងកាលជាទីបញ្ចប់អាទិត្តបរិយាយសូត្រ ទ្រង់ញ៉ាំងជដិល១ពាន់រូប ឲ្យបានតាំងស៊ប់ក្នុងព្រះអរហត្តហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងតាលដ្ឋិវ័នពួកព្រាហ្មណ៍និងគហបតី ១១ម៉ឺននាក់ មានព្រះបាទពិម្ពិសារជាប្រមុខ ស្តាប់ព្រះធម្មទេសនា របស់ព្រះសាស្តាហើយ បានតាំងស៊ប់ក្នុងសោតាបត្តិផលហើយ, និង១ម៉ឺននាក់ បានតាំងនៅក្នុងព្រះត្រៃសរណៈ; ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងកាលជាទីបញ្ចប់នៃការអនុមោទនាដោយតិរោកុដ្ដសូត្រ ពួកសត្វ៨ម៉ឺន ៤ពាន់ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងសមាគមរបស់នាយសុមនមាលាការ ពួកសត្វ ៨ម៉ឺន ៤ពាន់ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងសមាគមរបស់ដំរីធនបាលក៍ ពួកសត្វ ១ម៉ឺន ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បី

អនុគ្រោះដល់សត្វលោកនោះ។ ក្នុងសមាគមរបស់ខទិរង្គារ-ជាតក ពួកសត្វ ៨ម៉ឺន ៤ពាន់ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងសមាគមរបស់ជម្ពុកាជីវក ពួកសត្វ ៨ម៉ឺន ៤ពាន់ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងសមាគមរបស់អានន្ទសេដ្ឋី ពួកសត្វ ៨ម៉ឺន ៤ពាន់ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងថ្ងៃសម្តែងបារាយនសូត្រនាបាសាណកចេតិយ ពួកសត្វ ១៤កោដិ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងថ្ងៃសម្តែងយមកបាដិហារ្យ ពួកសត្វ ២០កោដិ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងពិភពតាវតិង្ស កាលព្រះអង្គទ្រង់គង់លើបណ្ឌុកម្ពលសិលា ទ្រង់ធ្វើមាតាឲ្យជាកាយសក្ខី សម្តែងអភិធម្ម ៧គម្ពីរ ពួកសត្វ ៨០កោដិ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងថ្ងៃចុះអំពីទេវលោក ពួកសត្វ ៣០កោដិ ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។

ក្នុងសក្កបញ្ហសូត្រ ពួកទេវតា ៨ម៉ឺន ផឹកនូវអមតបានហើយ, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ ក្នុងឋានៈទាំង៤នេះ គឺមហាសមយសូត្រ មង្គលសូត្រ ចូឡរាហុលោវាទសូត្រ សមចិត្តបដិបទាសូត្រ ពួកសត្វដែលបានសម្រេចធម៌ កំណត់ចំនួនមិនបាន, ទ្រង់កើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកនោះ។ បន្ទាប់ពីនេះ មានថ្ងៃនេះ ជាដើមទៅ និងក្នុងកាលជាអនាគត អ្នកសិក្សាគប្បីជ្រាបអត្ថនេះ ដោយអំណាចនៃពួកសត្វដែលអាស្រ័យព្រះសាសនា ហើយតាំងនៅស៊ប់ ក្នុងផ្លូវឋានសួគ៌និងព្រះនិព្វាន។

បទថា **ទេវមនុស្សានំ** សេចក្តីថា ព្រះអង្គមិនមែនកើតឡើង ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយប៉ុណ្ណោះទេ, គឺទ្រង់កើតឡើង ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ សូម្បីដល់ពួកនាគនិងគ្រុឌដ៏សេសដែរ។ ប៉ុន្តែការសម្តែងបែបនេះ ដើម្បីបង្ហាញនូវពួកបុគ្គល ដែលបដិសន្ធិដោយសហេតុកៈ ជាអ្នកគួរដើម្បីធ្វើឲ្យជាក់ច្បាស់នូវមគ្គនិងផលបាន។ ព្រោះហេតុនោះ ទើបគួរជ្រាបថា ព្រះតថាគតទ្រង់កើតឡើង ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បី

សេចក្ដីសុខ សូម្បីដល់ពួកសត្វតិរច្ឆានទាំងឡាយនោះដែរ។

បទថា **កតមោ ឯកបុគ្គលោ** នេះជាពាក្យសួរ។ ក៏ធម្មតាពាក្យសួរនេះ មាន៥ប្រការ គឺអទិដ្ឋជោតនាបុច្ឆា (ការសួរជាគ្រឿងបំភ្លឺនូវវត្ថុដែលមិនទាន់ឃើញ)១ ទិដ្ឋសំសន្ទនាបុច្ឆា (ការសួរជាគ្រឿងប្រៀបធៀបវត្ថុ ដែលបានឃើញហើយ)១ វិមតិច្ឆេទនាបុច្ឆា (ការសួរជាគ្រឿងកាត់នូវសេចក្ដីសង្ស័យ)១ អនុមតិបុច្ឆា (ការសួរដើម្បីឲ្យទទួលតាមមតិ)១ កថេតុ-កម្យតាបុច្ឆា (ការសួរដោយបំណងឆ្លើយដោយខ្លួនឯង)១។

នេះ ជាសេចក្ដីផ្សេងគ្នានៃពាក្យទាំងនោះ៖ ចុះអទិដ្ឋ-ជោតនាបុច្ឆា តើដូចម្ដេច? គឺលក្ខណៈតាមប្រក្រតី ជាវត្ថុដែលខ្លួនមិនដឹង មិនឃើញ មិនបានថ្លឹង មិនបានពិចារណា មិនប្រាកដ មិនជាក់ច្បាស់។ បុគ្គលសាកសួរសំនួរ ដើម្បីការដឹង ការឃើញ ការថ្លឹង ការពិចារណា ការប្រាកដ ការជាក់ច្បាស់ នេះ ឈ្មោះថា**អទិដ្ឋជោតនាបុច្ឆា**។

ចុះទិដ្ឋសំសន្ទនាបុច្ឆា តើដូចម្ដេច? គឺលក្ខណៈតាមប្រក្រតីជាវត្ថុដែលខ្លួនដឹង ឃើញ ថ្លឹងបាន ពិចារណា ប្រាកដជាក់ច្បាស់ហើយ។ បុគ្គលសាកសួរសំនួរ ដើម្បីប្រៀបធៀបជាមួយនឹងពួកបណ្ឌិតដទៃ នេះឈ្មោះថា**ទិដ្ឋសំសន្ទនាបុច្ឆា**។

ចុះវិមតិច្ឆេទនាបុច្ឆា តើដូចម្ដេច? គឺតាមប្រក្រតី បុគ្គលស្ទុះទៅកាន់សេចក្ដីសង្ស័យ ស្ទុះទៅកាន់សេចក្ដីងឿងឆ្ងល់ មានចិត្តបែកជាពីរថា "ឯវំ នុ ខោ = យ៉ាងនេះឬ? ន នុ ខោ = ឬថាមិនមែនទេ? កឹ នុ ខោ = អ្វីហ្ន៎? កថំ នុ ខោ = ប្រការដូចម្ដេចហ្ន៎? គេសួរសំនួរដើម្បីកាត់នូវសេចក្ដីសង្ស័យ នេះឈ្មោះថា**វិមតិច្ឆេទនាបុច្ឆា**។

កតមា **អនុមតិបុច្ឆា**? ភគវា ហិ ភិក្ខូនំ អនុមតិយា បញ្ហំ បុច្ឆតិ– "តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វា"តិ? "អនិច្ចំ ភន្តេ"។ "យំ បនានិច្ចំ, ទុក្ខំ វា តំ សុខំ វា"តិ? "ទុក្ខំ ភន្តេ"។ "យំ បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ, កល្លំ នុ ខោ តំ សមនុបស្សិតុំ– ឯតំ មម, ឯសោហមស្មិ, ឯសោ មេ អត្តា"តិ? "នោ ហេតំ ភន្តេ"តិ, អយំ **អនុមតិបុច្ឆា**។

ចុះអនុមតិបុច្ឆា តើដូចម្ដេច? គឺព្រះភគវាទ្រង់ត្រាស់សួរបញ្ហា ដោយសេចក្ដីយល់ឃើញត្រូវតាម របស់ពួកភិក្ខុថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្ដីនោះថាដូចម្ដេច? រូប ទៀង ឬមិនទៀង"? "បពិត្រព្រះអង្គដ៏ចម្រើន រូប មិនទៀងទេ"។ "របស់ណា មិនទៀង, របស់នោះ ជាទុក្ខ ឬជាសុខ"? "បពិត្រព្រះអង្គដ៏ចម្រើន របស់នោះ ជាទុក្ខ"។

"របស់ណា មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរដើម្បីនឹងយល់ឃើញនូវរបស់នោះថា 'នុ៎ះរបស់អញ, អញជានុ៎ះ, នុ៎ះជាខ្លួនរបស់អញ'ដែរឬ"? "បពិត្រព្រះអង្គដ៏ចម្រើន ហេតុនោះ មិនគួរនឹងយល់ឃើញយ៉ាងនោះទេ"។

ចុះកថេតុកម្យតាបុច្ឆា តើដូចម្ដេច? គឺព្រះភគវាទ្រង់ត្រាស់សួរបញ្ហា ដោយព្រះបំណងសម្ដែងដោយព្រះអង្គឯងដល់ពួកភិក្ខុថា "ម្នាលភិក្ខុទាំងឡាយ សតិបដ្ឋាននេះ មាន៤ ។ ៤ គឺអ្វីខ្លះ? នេះ ឈ្មោះថា**កថេតុកម្យតាបុច្ឆា**។

បណ្ដាសំនួរទាំង៥ នោះ សំនួរ៣ខាងដើម មិនមានដល់ព្រះពុទ្ធទាំងឡាយទេ។ ព្រោះហេតុអ្វី? ព្រោះថា ក្នុងអទ្ធា (កាលដ៏វែងឆ្ងាយ)ទាំង៣ វត្ថុអ្វីមួយ ដែលមានបច្ច័យប្រជុំតាក់តែង ឬវត្ថុដែលមិនមានបច្ច័យប្រជុំតាក់តែង ផុតចាកអទ្ធា ឈ្មោះថាជាវត្ថុ ដែលព្រះពុទ្ធទាំងឡាយមិនដឹង មិនឃើញ មិនបានថ្លឹង មិនបានពិចារណា មិនប្រាកដ មិនជាក់ច្បាស់ រមែងមិនមាន, ព្រោះហេតុនោះ ទើបព្រះអង្គមិនមានអទិដ្ឋជោតនាបុច្ឆា។ ចំណែកឯវត្ថុណា ព្រះភគវាទ្រង់មិនចាក់ធ្លុះ ដោយញាណរបស់ព្រះអង្គ, កិច្ចគឺការប្រៀបធៀបចំពោះវត្ថុនោះ ជាមួយនឹងអ្នកដទៃ គឺសមណៈក្ដី

ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី រមែងមិនមាន; ព្រោះហេតុនោះ ទើបព្រះអង្គមិនមានទិដ្ឋសំសន្ទនាបុច្ឆា។ ក៏ព្រោះតែព្រះអង្គមិនមានសេចក្តីរារែកព្រះទ័យ ជាហេតុថាយ៉ាងមេច មានវិចិកិច្ឆាឆ្លងផុតហើយ មានសេចក្តីសង្ស័យខ្ទាត់ចេញហើយ ក្នុងធម៌ទាំងអស់, ព្រោះហេតុនោះ ទើបព្រះអង្គមិនមានវិមតិច្ឆេទនាបុច្ឆា។ តែថា បុច្ឆាពីរទៀត ទើបមានចំពោះព្រះភគវា, ហើយបណ្តាបុច្ឆាទាំងពីរនោះសោត បុច្ឆានេះ គប្បីជ្រាបថា ជាកថេតុកម្យតាបុច្ឆា។

ពាក្យថា **តថាគតោ**

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់កាលបង្ហាញនូវបុគ្គលឯក ដែលសួរដោយបុច្ឆានោះ ទើបទ្រង់ត្រាស់ថា **តថាគតោ អរហំ សម្មាសម្ពុទ្ធោ** ។ បណ្តាបទទាំងឡាយ បទថា **តថាគតោ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ព្រះនាមថាតថាគត ដោយហេតុ៨យ៉ាង គឺ៖

១. តថា អាគតោតិ តថាគតោ ទ្រង់ព្រះនាមថាតថាគតព្រោះព្រះអង្គមកហើយ យ៉ាងនោះ។

២. តថា គតោតិ តថាគតោ ទ្រង់ព្រះនាមថាតថាគតព្រោះព្រះអង្គទៅហើយ យ៉ាងនោះ។

៣. តថលក្ខណំ អាគតោតិ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គមកហើយកាន់លក្ខណៈពិត។

៤. តថធម្មេ យាថាវតោ អភិសម្ពុទ្ធោតិ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គត្រាស់ដឹងច្បាស់នូវពួកធម៌ដែលពិត តាមសេចក្តីពិត ។

៥. តថទស្សិតាយ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គឃើញនូវអារម្មណ៍ដែលពិត។

៦. តថវាទិតាយ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គពោលតែពាក្យពិត។

៧. តថាការិតាយ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គធ្វើយ៉ាងនោះ។

អភិភវនដ្ឋេន តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះអត្ថថាព្រះអង្គគ្របសង្កត់នូវសព្វសត្វទាំងអស់។

កថំ តថា អាគតោតិ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គមកហើយ យ៉ាងនោះ តើដូចម្តេច? ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គមុនៗ ទ្រង់ដល់នូវសេចក្តីខ្វល់ខ្វាយដើម្បីប្រយោជន៍ដល់សព្វសត្វ ព្រះអង្គមកហើយ យ៉ាងណា, (ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។)

គឺព្រះមានព្រះភាគវិបស្សី ព្រះអង្គមកហើយ យ៉ាងណា, (ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។) ព្រះមានព្រះភាគសិខី ព្រះអង្គមកហើយ យ៉ាងណា, (ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។) ព្រះមានព្រះភាគវេស្សភូ ព្រះអង្គមកហើយ យ៉ាងណា, (ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។) ព្រះមានព្រះភាគកកុសន្ធៈ ព្រះអង្គមកហើយ យ៉ាងណា, (ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។) ព្រះមានព្រះភាគកោណាគមនៈ ព្រះអង្គមកហើយ យ៉ាងណា, (ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។) ព្រះមានព្រះភាគកស្សបៈ ព្រះអង្គមកហើយ យ៉ាងណា, (ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។) លោកពោលអធិប្បាយដូចម្ដេច? លោកពោលអធិប្បាយថា ព្រះមានព្រះភាគទាំងឡាយ (មុនៗ) នោះ ព្រះអង្គមកហើយ ដោយអភិនីហារណា, ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ ដោយអភិនីហារនោះ។

ម្យ៉ាងទៀត ព្រះមានព្រះភាគវិបស្សី ទ្រង់បំពេញបារមី ៣០ គឺបារមី១០ ឧបបារមី១០ បរមត្ថបារមី១០ គឺទានបារមី

ទានឧបបារមី ទានបរមត្ថបារមី សីលបារមី សីលឧបបារមី សីលបរមត្ថបារមី នេក្ខម្មបារមី នេក្ខម្មឧបបារមី នេក្ខម្ម-បរមត្ថបារមី បញ្ញាបារមី បញ្ញាឧបបារមី បញ្ញាបរមត្ថបារមី វីរិយបារមី វីរិយឧបបារមី វីរិយបរមត្ថបារមី ខន្តិបារមី ខន្តិឧបបារមី ខន្តិបរមត្ថបារមី សច្ចបារមី សច្ចឧបបារមី សច្ចបរមត្ថបារមី អធិដ្ឋានបារមី អធិដ្ឋានឧបបារមី អធិដ្ឋាន-បរមត្ថបារមី មេត្តាបារមី មេត្តាឧបបារមី មេត្តាបរមត្ថបារមី ឧបេក្ខាបារមី ឧបេក្ខាឧបបារមី ឧបេក្ខាបរមត្ថបារមី, ទ្រង់បរិច្ចាគនូវមហាបរិច្ចាគ៥ គឺនយនបរិច្ចាគ (ការលះបង់ភ្នែក) ១ ធនបរិច្ចាគ (ការលះបង់ទ្រព្យ)១ រជ្ជបរិច្ចាគ (ការលះបង់រាជ្យ)១ បុត្តបរិច្ចាគ (ការលះបង់កូន)១ ទារបរិច្ចាគ (ការលះបង់ប្រពន្ធ)១[4] ទ្រង់បំពេញនូវបុព្វបយោគ បុព្វចរិយា ធម្មក្ខានៈ និងញាតត្ថចរិយាជាដើម ហើយដល់នូវទីបំផុតនៃពុទ្ធិចរិយា(ការប្រព្រឹត្តទៅបញ្ញា) ព្រះអង្គមកហើយ យ៉ាងណា, ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។ ព្រះមានព្រះភាគសិខី... ព្រះមានព្រះភាគវេស្សភូ... ព្រះមានព្រះភាគកកុសន្ធៈ... ព្រះមានព្រះភាគកោណាគមនៈ

4 ទីដទៃ មហាបរិច្ចាគ៥ គឺបរិច្ចាគទ្រព្យ១ កូន១ ប្រពន្ធ១ អវយវៈ១ ជីវិត១ ។

... ព្រះមានព្រះភាគកស្សបៈ ទ្រង់បំពេញបារមី៣០ គឺ បារមី១០ ឧបបារមី១០ បរមត្ថបារមី១០, ទ្រង់បរិច្ចាគនូវ មហាបរិច្ចាគ៥ ទ្រង់បំពេញនូវបុព្វយោគ បុព្វចរិយា ធម្មក្ខានៈ និងញាតត្ថចរិយាជាដើម ហើយដល់នូវទីបំផុត នៃពុទ្ធិចរិយា ព្រះអង្គមកហើយ យ៉ាងណា, ព្រះមានព្រះភាគ នៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។

មួយទៀត ព្រះមានព្រះភាគវិបស្សី... ព្រះមានព្រះភាគ សិខី... ព្រះមានព្រះភាគវេស្សភូ... ព្រះមានព្រះភាគកកុសន្ធៈ ... ព្រះមានព្រះភាគកោណាគមនៈ... ព្រះមានព្រះភាគ កស្សបៈ ទ្រង់អប់រំ ចម្រើននូវសតិបដ្ឋាន៤ សម្មប្បធាន៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពលៈ៥ ពោជ្ឈង្គៈ៧ អរិយមគ្គមានអង្គ ៨ ព្រះអង្គមកហើយ យ៉ាងណា, ព្រះមានព្រះភាគនៃយើង ក៏ព្រះអង្គមកហើយ យ៉ាងនោះ។

យថេវ លោកម្ហិ វិបស្សិអាទយោ,
សព្វញ្ញុភាវំ មុនយោ ឥធាគតា;
តថា អយំ សក្យមុនីបិ អាគតោ,
តថាគតោ វុច្ចតិ តេន ចក្ខុមា។

ព្រះសក្យមុនីទាំងឡាយ មានព្រះវិបស្សីជាដើម

ទ្រង់យាងមកហើយ កាន់ភាពជាសព្វញ្ញូ ក្នុងលោកនេះ យ៉ាងណា, ព្រះសក្យមុនី(នៃយើង)នេះ ក៏ទ្រង់យាងមកហើយ យ៉ាងនោះ; ព្រោះហេតុនោះ ព្រះពុទ្ធទ្រង់មានចក្ខុ ទើបបណ្ឌិតហៅថា **តថាគត**។

ព្រះមានព្រះភាគទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គមកហើយ យ៉ាងនោះ ដោយប្រការយ៉ាងនេះ។

កថំ តថា គតោតិ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គទៅហើយ យ៉ាងនោះ តើដូចម្ដេច? ព្រះមានព្រះភាគវិបស្សី... ព្រះមានព្រះភាគសិខី... ព្រះមានព្រះភាគវេស្សភូ... ព្រះមានព្រះភាគកកុសន្ធៈ... ព្រះមានព្រះភាគកោណាគមនៈ... ព្រះមានព្រះភាគកស្សបៈ ប្រសូតមកភ្លាមទ្រង់យាងទៅហើយ យ៉ាងណា, (ព្រះមានព្រះភាគនៃយើងក៏ទ្រង់យាងទៅហើយ យ៉ាងនោះ។) ព្រះអង្គទ្រង់យាងទៅហើយ ដូចម្ដេច? អធិប្បាយថា ព្រះអង្គប្រសូតមកភ្លាមទ្រង់ជាន់លើផែនដី ដោយព្រះបាទដ៏ស្មើ មានព្រះភក្ត្របែរទៅទិសឧត្តរ ទ្រង់យាងទៅហើយ ដោយឈានព្រះបាទ៧ជំហាន។ សមដូចព្រះអង្គទ្រង់ត្រាស់ថា “ម្នាលអានន្ទព្រះពោធិសត្វប្រសូត្រមកភ្លាម ជាន់ដោយព្រះបាទដ៏ស្មើ

មានព្រះភក្រ្តបែរទៅទិសឧត្តរ ឈានទៅបាន៧ជំហាន កាល ពួកទេវតាបាំងសេតច្ឆត្រ ទតមើលគ្រប់ទិស បន្លឺអាសភិវាចា (ព្រះវាចាដ៏អង្គអាច)ថា 'អគ្គោហមស្មិ លោកស្ស, ជេដ្ឋោ-ហមស្មិ លោកស្ស, សេដ្ឋោហមស្មិ លោកស្ស, អយមន្តិមា ជាតិ, នត្ថិទានិ បុនព្ភវោ = យើងជាបុគ្គលដ៏កំពូលរបស់ លោក, យើងជាបុគ្គលដ៏ចម្បងបំផុតរបស់លោក, យើងជា បុគ្គលដ៏ប្រសើររបស់លោក, ជាតិនេះ ជាជាតិចុងក្រោយ (របស់យើងហើយ) ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ'"[5] ។ ក៏ដំណើរយាងទៅ របស់ព្រះអង្គនោះ បានជាអាការៈពិត ឥតប្រែប្រួល ព្រោះជាបុព្វនិមិត្តនៃការបានសម្រេចគុណ-វិសេសជាច្រើនអនេក។ ពិតមែន ព្រះអង្គប្រសូតមកភ្លាម គង់ជាន់នៅស៊ប់ដោយព្រះបាទដ៏ស្មើ, នេះ ជាបុព្វនិមិត្តនៃ ការបានចំពោះឥទ្ធិបាទ៤ របស់ព្រះអង្គ, ការបែរព្រះភក្រ្តទៅ ទិសឧត្តរ ជាបុព្វនិមិត្តនៃលោកុត្តរធម៌ទាំងអស់, ការឈាន ទៅ៧ជំហាន ជាបុព្វនិមិត្ត នៃការបានចំពោះរតនៈគឺ ពោជ្ឈង្គៈ៧, ការលើកឡើងនូវឆ្លិតចាមរ ដែលពោលទុកក្នុង ពាក្យនេះថា "ឆ្លិតចាមរទាំងឡាយ មានដងជាវិការៈនៃមាស

---

5 ទី.ម.មហាបទានសូត្រ, ម.ឧបរិ.អច្ឆរិយអព្ភូតសូត្រ។

សំយុងចុះ″ ជាបុព្វនិមិត្តនៃការញាំញី នូវតិរ្ថិយទាំងអស់, ការបាំងស្វេតឆ័ត្រ ជាបុព្វនិមិត្តនៃការបានចំពោះស្វេតឆ័ត្រ គឺការប្រាសចាកមន្ទិលដ៏ប្រសើរ គឺអរហត្តផលនិងវិមុត្តិ, ការទតមើលគ្រប់ទិស ជាបុព្វនិមិត្តនៃការបានចំពោះសព្វញ្ញុត-ញ្ញាណ និងអនាវរណញ្ញាណ, ការបន្លឺអាសភិវាចា ជាបុព្វនិមិត្តនៃការប្រកាសធម្មចក្កប្បវត្តនសូត្រដ៏ប្រសើរ ដែលអ្នកណាមួយមិនអាចឲ្យប្រព្រឹត្តទៅបាន។ សូម្បីព្រះមានព្រះភាគអង្គនេះ ក៏ព្រះអង្គទៅហើយ យ៉ាងនោះ។ ក៏ដំណើរយាងទៅ របស់ព្រះអង្គនោះ បានជាអាការៈពិត ឥតប្រែប្រួល ព្រោះជាបុព្វនិមិត្ត នៃការបានសម្រេចគុណវិសេសទាំងនោះ។ ដូច្នោះពួកអាចារ្យដែលមានក្នុងកាលមុនបានពោលទុកថា

មុហុត្តជាតោវ គវម្បតី យថា,
សមេហិ បាទេហិ ផុសី វសុន្ធរំ;
សោ វិក្កមី សត្ត បទានិ គោតមោ,
សេតញ្ច ឆត្តំ អនុធារយុំ មរូ។
គន្ត្វាន សោ សត្ត បទានិ គោតមោ,
ទិសា វិលោកេសិ សមា សមន្តតោ;
អដ្ឋង្គុបេតំ គិរមព្ភុទីរយិ,

សីហោ យថា បព្ពតមុទ្ធនិដ្ឋិតោ។

ព្រះគរម្បតីគោតម ទ្រង់ប្រសូតមកភ្លាម ទ្រង់ជាន់ស៊ប់លើផែនដី ដោយយុគលបាទដ៏ស្មើ ទ្រង់ឈានយាងទៅបាន៧ជំហាន, ពួកទេវតាក៏បានឈរបាំងស្វេតឆ័ត្រ, ព្រះគោតមអង្គនោះ បានយាងទៅបាន៧ជំហាន ទតមើលទិសទាំងឡាយ ដោយជុំវិញស្មើគ្នា បន្លឺអាសភិវាចាប្រកបដោយអង្គ៨ ដូចរាជសីហ៍ឈរលើកំពូលភ្នំដូច្នោះ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គទៅហើយ យ៉ាងនោះ ដោយប្រការយ៉ាងនេះ។

ម្យ៉ាងទៀត ព្រះមានព្រះភាគវិបស្សី... ព្រះមានព្រះភាគសិខី... ព្រះមានព្រះភាគវេស្សភូ... ព្រះមានព្រះភាគកកុសន្ធៈ ... ព្រះមានព្រះភាគកោណាគមនៈ... ព្រះមានព្រះភាគកស្សបៈ ទ្រង់លះបង់កាមច្ឆន្ទៈ ដោយនេក្ខម្មៈ ទៅហើយ, ទ្រង់លះបង់ព្យាបាទៈ ដោយអព្យាបាទ ទៅហើយ, ទ្រង់លះបង់ថីនមិទ្ធៈ ដោយអាលោកសញ្ញា ទៅហើយ, ទ្រង់លះបង់ឧទ្ធច្ចកុក្កុច្ចៈ ដោយអវិក្ខេបៈ ទៅហើយ, ទ្រង់លះបង់វិចិកិច្ឆាដោយធម្មវវត្ថាន ទៅហើយ, ទ្រង់ទម្លាយអវិជ្ជា ដោយញាណ

ទៅហើយ, ទ្រង់បន្ទាបង់អរតិ ដោយបាមោជ្ជៈ ទៅហើយ, ទ្រង់គាស់បំបើកទ្វារគឺនីវរណៈ ដោយបឋមជ្ឈាន ទៅហើយ, ទ្រង់រម្ងាប់វិតក្កៈនិងវិចារៈ ដោយទុតិយជ្ឈាន ទៅហើយ, ទ្រង់ប្រាសចាកបីតិ ដោយតតិយជ្ឈាន ទៅហើយ, ទ្រង់លះបង់សុខនិងទុក្ខ ដោយចតុត្ថជ្ឈាន ទៅហើយ, ទ្រង់កន្លងបង់រូបសញ្ញាបដិឃសញ្ញានិងនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ទៅហើយ, ទ្រង់កន្លងបង់អាកាសានញ្ចាយតនសមាបត្តិ ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ទៅហើយ, ទ្រង់កន្លងបង់វិញ្ញាណញ្ចាយតនសមាបត្តិ ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ទៅហើយ, ទ្រង់កន្លងបង់អាកិញ្ចញ្ញាយតនសមាបត្តិ ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ទៅហើយ។ ទ្រង់លះបង់និច្ចសញ្ញា ដោយអនិច្ចានុបស្សនា ទៅហើយ, ទ្រង់លះបង់សុខសញ្ញា ដោយទុក្ខានុបស្សនា ទៅហើយ, ទ្រង់លះបង់អត្តសញ្ញា ដោយអនត្តានុបស្សនា ទៅហើយ, ទ្រង់លះបង់នន្ទិ ដោយនិព្វិទានុបស្សនា ទៅហើយ, ទ្រង់លះបង់រាគៈ ដោយវិរាគានុបស្សនា ទៅហើយ, ទ្រង់លះបង់សមុទយៈ ដោយនិរោធានុបស្សនា ទៅហើយ, ទ្រង់លះបង់អាទាន ដោយបដិនិស្សគ្គានុបស្សនា

ទៅហើយ, ទ្រង់លះបង់យនសញ្ញា ដោយខយានុបស្សនា ទៅហើយ, ទ្រង់លះបង់អាយូហនៈ ដោយវយានុបស្សនា ទៅហើយ, ទ្រង់លះបង់ធុវសញ្ញា ដោយវិបរិណាមានុបស្ស-នា ទៅហើយ, ទ្រង់លះបង់និមិត្តសញ្ញា ដោយអនិមិត្តានុ-បស្សនា ទៅហើយ, ទ្រង់លះបង់បណិធិ ដោយអប្បណិហិ-តានុបស្សនា ទៅហើយ, ទ្រង់លះបង់អភិនិវេសៈ ដោយសុញ្ញតានុបស្សនា ទៅហើយ, ទ្រង់លះបង់សារាទានាភិនិ-វេសៈ ដោយអធិបញ្ញាធម្មវិបស្សនា ទៅហើយ, ទ្រង់លះបង់សម្មោហាភិនិវេសៈ ដោយយថាភូតញាណទស្សនៈ ទៅហើយ, ទ្រង់លះបង់អាលយាភិនិវេសៈ ដោយអាទីនវានុ-បស្សនា ទៅហើយ, ទ្រង់លះបង់អប្បដិសង្ខា ដោយបដិ-សង្ខានុបស្សនា ទៅហើយ, ទ្រង់លះបង់សំយោគាភិនិវេសៈ ដោយវិវដ្ដានុបស្សនា ទៅហើយ, ទ្រង់កាច់បំបាក់នូវពួកកិលេស ដែលតាំងនៅក្នុងទីតែមួយជាមួយនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ ទៅហើយ, ទ្រង់លះបង់នូវពួកកិលេសដ៏គ្រោតគ្រាត ដោយសកទាគាមិមគ្គ ទៅហើយ, ទ្រង់គាស់ឡើងនូវពួកកិលេសដ៏ល្អិត ដោយអនាគាមិមគ្គ ទៅហើយ, ទ្រង់ចូលទៅកាត់ផ្ដាច់ នូវពួកកិលេសទាំងអស់ ដោយ

អរហត្តមគ្គ ក៏ទៅហើយ យ៉ាងណា, ព្រះមានព្រះភាគនៃយើង ទ្រង់លះបង់កាមច្ឆន្ទៈ ដោយនេក្ខម្មៈ ទៅហើយ, ទ្រង់លះបង់ព្យាបាទៈ ដោយអព្យាបាទ ទៅហើយ, ទ្រង់លះបង់ថីនមិទ្ធៈ ដោយអាលោកសញ្ញា ទៅហើយ, ទ្រង់លះបង់ឧទ្ធច្ចកុក្កុច្ចៈ ដោយអវិក្ខេបៈ ទៅហើយ, ទ្រង់លះបង់វិចិកិច្ឆា ដោយធម្មវវត្ថាន ទៅហើយ, ទ្រង់ទម្លាយអវិជ្ជា ដោយញាណ ទៅហើយ, ទ្រង់បន្ទាបង់អរតិ ដោយបាមោជ្ជៈ ទៅហើយ, ទ្រង់គាស់បំបើកទ្វារគឺនីវរណៈ ដោយបឋមជ្ឈាន ទៅហើយ, ទ្រង់រម្ងាប់វិតក្កៈនិងវិចារៈ ដោយទុតិយជ្ឈាន ទៅហើយ, ទ្រង់ប្រាសចាកបីតិ ដោយតតិយជ្ឈាន ទៅហើយ, ទ្រង់លះបង់សុខនិងទុក្ខ ដោយចតុត្ថជ្ឈាន ទៅហើយ, ទ្រង់កន្លងបង់រូបសញ្ញាបដិឃសញ្ញានិងនានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ ទៅហើយ, ទ្រង់កន្លងបង់អាកាសានញ្ចាយតនសមាបត្តិ ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ទៅហើយ, ទ្រង់កន្លងបង់វិញ្ញាណញ្ចាយតនសមាបត្តិ ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ទៅហើយ, ទ្រង់កន្លងបង់អាកិញ្ចញ្ញាយតនសមាបត្តិ ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ទៅហើយ។ ទ្រង់លះបង់និច្ចសញ្ញា ដោយអនិច្ចា-

នុបស្សនា ទៅហើយ, ទ្រង់លះបង់សុខសញ្ញា ដោយទុក្ខា-
នុបស្សនា ទៅហើយ, ទ្រង់លះបង់អត្តសញ្ញា ដោយអនត្តា-
នុបស្សនា ទៅហើយ, ទ្រង់លះបង់នន្ទិ ដោយនិព្វិទានុបស្ស-
នា ទៅហើយ, ទ្រង់លះបង់រាគៈ ដោយវិរាគានុបស្សនា
ទៅហើយ, ទ្រង់លះបង់សមុទយៈ ដោយនិរោធានុបស្សនា
ទៅហើយ, ទ្រង់លះបង់អាទាន ដោយបដិនិស្សគ្គានុបស្សនា
ទៅហើយ, ទ្រង់លះបង់ឃនសញ្ញា ដោយខយានុបស្សនា
ទៅហើយ, ទ្រង់លះបង់អាយូហនៈ ដោយវយានុបស្សនា
ទៅហើយ, ទ្រង់លះបង់ធុវសញ្ញា ដោយវិបរិណាមានុបស្ស-
នា ទៅហើយ, ទ្រង់លះបង់និមិត្តសញ្ញា ដោយអនិមិត្តានុ-
បស្សនា ទៅហើយ, ទ្រង់លះបង់បណិធិ ដោយអប្បណិហិ-
តានុបស្សនា ទៅហើយ, ទ្រង់លះបង់អភិនិវេសៈ ដោយ
សុញ្ញតានុបស្សនា ទៅហើយ, ទ្រង់លះបង់សារាទានាភិនិ-
វេសៈ ដោយអធិបញ្ញាធម្មវិបស្សនា ទៅហើយ, ទ្រង់លះបង់
សម្មោហាភិនិវេសៈ ដោយយថាភូតញាណទស្សនៈ ទៅ
ហើយ, ទ្រង់លះបង់អាលយាភិនិវេសៈ ដោយអាទីនវានុ-
បស្សនា ទៅហើយ, ទ្រង់លះបង់អប្បដិសង្ខា ដោយបដិ-
សង្ខានុបស្សនា ទៅហើយ, ទ្រង់លះបង់សំយោគាភិនិវេសៈ

ដោយវិវដ្ដានុបស្សនា ទៅហើយ, ទ្រង់កាច់បំបាក់នូវពួកកិលេស ដែលតាំងនៅក្នុងទីតែមួយជាមួយនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ ទៅហើយ, ទ្រង់លះបង់នូវពួកកិលេសដ៏គ្រោតគ្រាត ដោយសកទាគាមិមគ្គ ទៅហើយ, ទ្រង់គាស់ឡើងនូវពួកកិលេសដ៏ល្អិត ដោយអនាគាមិមគ្គ ទៅហើយ, ទ្រង់ចូលទៅកាត់ផ្ដាច់ នូវពួកកិលេសទាំងអស់ ដោយអរហត្តមគ្គ ក៏ទៅហើយ យ៉ាងនោះ។

ព្រះមានព្រះភាគទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គទៅហើយ យ៉ាងនោះ ដោយប្រការយ៉ាងនេះ។

កថំ តថលក្ខណំ គតោតិ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គទៅហើយ កាន់លក្ខណៈពិត តើដូចម្ដេច? គឺបឋវីធាតុមានភាពរឹងជាលក្ខណៈ ពិត ឥតប្រែប្រួល, អាបោធាតុមានការហូរសើមជាលក្ខណៈ ពិត ឥតប្រែប្រួល, តេជោធាតុមានភាពក្ដៅជាលក្ខណៈ ពិត ឥតប្រែប្រួល, វាយោធាតុមានភាពតឹងញ័រជាលក្ខណៈ ពិត ឥតប្រែប្រួល, អាកាសធាតុមានការប៉ះមិនបានជាលក្ខណៈ ពិត ឥតប្រែប្រួល, វិញ្ញាណធាតុមានការដឹងច្បាស់ជាលក្ខណៈ ពិតឥតប្រែប្រួល។

រូប មានការវិនាសទៅជាលក្ខណៈ, វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ, សញ្ញា មានការចាំអារម្មណ៍ជាលក្ខណៈ, សង្ខារទាំងឡាយ មានការតក់តែងជាលក្ខណៈ, វិញ្ញាណ មានវិជាននៈ (ការដឹងច្បាស់) ជាលក្ខណៈ (ពិត ឥតប្រែប្រួល)។

វិតក្កៈ មានអភិនិរោបនៈ (ការលើកចិត្តឡើងកាន់អារម្មណ៍)ជាលក្ខណៈ, វិចារៈ មានអនុមជ្ជនៈ (ការស្ទាបអង្អែល, តាមពិចារណា) ជាលក្ខណៈ, បីតិ មានផរណៈ (ការផ្សាយទៅ) ជាលក្ខណៈ, សុខ មានសាតៈ (ការសប្បាយស្រួល) ជាលក្ខណៈ, ចិត្តេកគ្គតា មានអវិក្ខេបៈជាលក្ខណៈ, ផស្សៈមានផុសនៈ(ការប៉ះ)ជាលក្ខណៈ(ពិត ឥតប្រែប្រួល)។

សទ្ធិន្ទ្រិយ មានអធិមោក្ខ(ការជឿស៊ប់) ជាលក្ខណៈ, វីរិយិន្ទ្រិយមានបគ្គហៈ(ការផ្គងឡើង)ជាលក្ខណៈ,សតិន្ទ្រិយៈមានឧបដ្ឋាន(ការតម្កល់មាំ)ជាលក្ខណៈ, សមាធិន្ទ្រិយ មានអវិក្ខេបៈជាលក្ខណៈ, បញ្ញិន្ទ្រិយ មានបជាននៈ(ការដឹងដោយប្រការ)ជាលក្ខណៈ (ពិត ឥតប្រែប្រួល)។

សទ្ធាពលៈមានការមិនញាប់ញ័រ ក្នុងអស្សទ្ធិយៈ (ការមិនជឿ) ជាលក្ខណៈ, វីរិយពលៈមានការមិនញាប់ញ័រ ក្នុង

កោសជ្ជៈ(ការខ្ជិល) ជាលក្ខណៈ, សតិពលៈ មានការមិនញាប់ញ័រ ក្នុងមុដ្ឋស្សច្ចៈ (ការភ្លេចសតិ) ជាលក្ខណៈ, សមាធិពលៈ មានការមិនញាប់ញ័រ ក្នុងឧទ្ធច្ចៈ(ការអណ្តែតអណ្តូង) ជាលក្ខណៈ, បញ្ញាពលៈ មានការមិនញាប់ញ័រ ក្នុងអវិជ្ជា(ការមិនដឹង)ជាលក្ខណៈ (ពិត ឥតប្រែប្រួល)។

សតិសម្ពោជ្ឈង្គៈមានឧបដ្ឋានជាលក្ខណៈ, ធម្មវិចយ-សម្ពោជ្ឈង្គៈ មានបវិចយៈ(ការពិនិត្យពិច័យ) ជាលក្ខណៈ, វីរិយសម្ពោជ្ឈង្គៈ មានបគ្គហៈជាលក្ខណៈ, បីតិសម្ពោជ្ឈង្គៈ មានផរណៈជាលក្ខណៈ, បស្សទ្ធិសម្ពោជ្ឈង្គៈ មានវូបសមៈ (ការស្ងប់)ជាលក្ខណៈ, សមាធិសម្ពោជ្ឈង្គៈ មានអវិក្ខេបៈ ជាលក្ខណៈ, ឧបេក្ខាសម្ពោជ្ឈង្គៈ មានបដិសង្ខាន (ការពិចារណា) ជាលក្ខណៈ (ពិត ឥតប្រែប្រួល)។

សម្មាទិដ្ឋិ មានទស្សនៈជាលក្ខណៈ, សម្មាសង្កប្បៈ មានអភិនិរោបនៈជាលក្ខណៈ, សម្មាវាចា មានបរិគ្គហៈ ជាលក្ខណៈ, សម្មាកម្មន្តៈមានសមុដ្ឋានជាលក្ខណៈ, សម្មា-អាជីវៈ មានវោទានៈជាលក្ខណៈ, សម្មាវាយាមៈមានបគ្គហៈ ជាលក្ខណៈ, សម្មាសតិ មានឧបដ្ឋានៈជាលក្ខណៈ, សម្មា-សមាធិ មានអវិក្ខេបៈជាលក្ខណៈ (ពិត ឥតប្រែប្រួល)។

អវិជ្ជាមានអញ្ញាណជាលក្ខណៈ, សង្ខារទាំងឡាយមានចេតនាជាលក្ខណៈ, វិញ្ញាណមានវិជាននៈជាលក្ខណៈ, នាមមាននមនៈ (ការបង្អោនទៅ) ជាលក្ខណៈ, រូបមានរុប្បនៈជាលក្ខណៈ, សឡាយតនៈ មានអាយតនៈ(ការត)ជាលក្ខណៈ, ផស្សៈមានផុសនៈជាលក្ខណៈ, វេទនា មានអារម្មណ៍ដែលត្រូវដឹងជាលក្ខណៈ, តណ្ហា មានហេតុជាលក្ខណៈ, ឧបាទានៈ មានការចាប់ប្រកាន់ជាលក្ខណៈ, ភព មានអាយូហនៈ (ការប្រមូលមក)ជាលក្ខណៈ, ជាតិ មាននិព្វត្តិ(ការកើត) ជាលក្ខណៈ, ជរា មានជីរណៈ(ការចាស់គ្រាំគ្រា) ជាលក្ខណៈ, មរណៈមានចុតិជាលក្ខណៈ (ពិត ឥតប្រែប្រួល)។

ធាតុទាំងឡាយ មានសភាពសូន្យទទេជាលក្ខណៈ, អាយតនៈទាំងឡាយ មានការតជាលក្ខណៈ, សតិបដ្ឋានទាំងឡាយ មាករតម្កល់មាំជាលក្ខណៈ, សម្មប្បធានទាំងឡាយ មានការផ្គងជាលក្ខណៈ, ឥទ្ធិបាទទាំងឡាយមានការសម្រេចជាលក្ខណៈ, ឥន្ទ្រិយទាំងឡាយ មានអធិបតីជាលក្ខណៈ, ពលៈទាំងឡាយ មានការមិនញាប់ញ័រ ជាលក្ខណៈ, ពោជ្ឈង្គៈទាំងឡាយ មានការនាំចេញជាលក្ខណៈ, មគ្គ មានហេតុជាលក្ខណៈ (ពិត ឥតប្រែប្រួល)។

សច្ចៈទាំងឡាយ មានការពិតជាលក្ខណៈ, សមថៈមាន អវិក្ខេបៈជាលក្ខណៈ, វិបស្សនាមានអនុបស្សនាជាលក្ខណៈ, សមថៈនិងវិបស្សនាទាំងឡាយ មានរសតែមួយជាលក្ខណៈ, យុគនទ្ធធម៌ទាំងឡាយ មានការមិនប្រព្រឹត្តកន្លងជាលក្ខណៈ (ពិត ឥតប្រែប្រួល)។

សីលវិសុទ្ធិ មានសំវរៈជាលក្ខណៈ, ចិត្តវិសុទ្ធិ មាន អវិក្ខេបៈជាលក្ខណៈ, ទិដ្ឋិវិសុទ្ធិ មានទស្សនៈជាលក្ខណៈ។

ខយញ្ញាណ មានសមុច្ឆេទជាលក្ខណៈ, អនុប្បាទ-ញ្ញាណ មានបស្សទ្ធិជាលក្ខណៈ (ពិត ឥតប្រែប្រួល)។

ឆន្ទៈ មានឫសមូលជាលក្ខណៈ, មនសិការ មាន សមុដ្ឋានជាលក្ខណៈ, ផស្សៈ មានសមោធានជាលក្ខណៈ, វេទនា មានសមោសរណៈជាលក្ខណៈ, សមាធិ មានភាព ប្រមុខជាលក្ខណៈ, សតិ មានអាធិបតេយ្យជាលក្ខណៈ, បញ្ញា មានភាពប្រសើរជាងពួកធម៌ទាំងនោះ ជាលក្ខណៈ, វិមុត្តិ មានសារធម៌ជាលក្ខណៈ, និព្វានដែលឈានចុះកាន់ អមតៈ មានបរិយោសានជាលក្ខណៈ ពិត ឥតប្រែប្រួល[6]។ ព្រះភគវាទ្រង់ទៅហើយ កាន់លក្ខណៈពិត ដោយញាណគតិ

6 សូមរ្បីបទទាំងឡាយដទៃទៀត ដែលមិនមាន ក៏គួរនាំមកដូចគ្នា។

ដល់ហើយ សម្រេចហើយ ដោយមិនខុស ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា តថាគត ដោយប្រការយ៉ាងនេះ។ ព្រះភគវាទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គមកហើយ កាន់លក្ខណៈពិត ដោយប្រការយ៉ាងនេះ។

កថំ តថធម្មេ យាថាវតោ អភិសម្ពុទ្ធោតិ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គត្រាស់ដឹងនូវពួកធម៌ដែលពិត តាមសេចក្តីពិត តើដូចម្តេច? ឈ្មោះថាពួកធម៌ដែលពិត (តថធម៌) គឺអរិយសច្ច៤ ។ សមដូចព្រះអង្គទ្រង់ត្រាស់ថា៖

"ចត្តារិមានិ ភិក្ខវេ តថានិ អវិតថានិ អនញ្ញថានិ។ កតមានិ ចត្តារិ? 'ឥទំ ទុក្ខ'ន្តិ ភិក្ខវេ តថមេតំ អវិតថមេតំ អនញ្ញថមេតំ; 'អយំ ទុក្ខសមុទយោ'តិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ; 'អយំ ទុក្ខនិរោធោ'តិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ; 'អយំ ទុក្ខនិរោធគាមិនី បដិបទា'តិ តថមេតំ អវិតថមេតំ អនញ្ញថមេតំ– ឥមានិ ខោ ភិក្ខវេ ចត្តារិ តថានិ អវិតថានិ អនញ្ញថានិ"។

"ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤យ៉ាងនេះ ជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ។ ធម្មជាត ៤ យ៉ាង គឺអ្វីខ្លះ? ម្នាលភិក្ខុទាំងឡាយ ពាក្យថា 'នេះ ជាទុក្ខ'

នុ៎ះជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះមិនក្លាយទៅជារបស់ដទៃឡើយ។ ពាក្យថា ‵នេះ ជាហេតុកើតឡើងនៃទុក្ខ′ នុ៎ះជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះមិនក្លាយទៅជារបស់ដទៃឡើយ។ ពាក្យថា ‵នេះជាសេចក្តីរំលត់ទុក្ខ′ នុ៎ះជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះមិនក្លាយទៅជារបស់ដទៃឡើយ។ ពាក្យថា ‵នេះ ជាបដិបទាជាដំណើរទៅកាន់ទីរំលត់ទុក្ខ′ នុ៎ះជារបស់ពិត នុ៎ះជារបស់មិនប្រែប្រួល នុ៎ះមិនក្លាយទៅជារបស់ដទៃឡើយ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤យ៉ាងនេះជារបស់ពិត មិនប្រែប្រួល មិនក្លាយទៅជារបស់ដទៃឡើយ″[7]។

ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងច្បាស់ នូវរបស់ទាំងនោះ ព្រោះហេតុនោះ ទើបបណ្ឌិតហៅថា តថាគត ព្រោះទ្រង់ត្រាស់ដឹងច្បាស់ នូវរបស់ពិតទាំងឡាយ។ គឺគតស័ព្ទក្នុងទីនេះ មានអភិសម្ពោធ(ត្រាស់ដឹងច្បាស់)ជាអត្ថ។

ម្យ៉ាងទៀត ជរាមរណស្ស ជាតិបច្ចយសម្ភូតសមុទាគតដ្ឋោ តថោ អវិតថោ អនញ្ញថោ ជរានិងមរណៈ ដែលកើតមានមកប្រាកដឡើង ព្រោះជាតិជាបច្ច័យ ជាសេចក្តី ពិត

7 សំ.ម.ធម្មចក្កប្បវត្តនវគ្គ តថសូត្រ។

ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, ជាតិ ដែលកើតមានមកប្រាកដឡើង ព្រោះភពជាបច្ច័យ ជាសេចក្ដី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, ភព ដែលកើតមានមកប្រាកដឡើង ព្រោះឧបាទានជាបច្ច័យ ជាសេចក្ដី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, ឧបាទាន ដែលកើតមានមកប្រាកដឡើង ព្រោះតណ្ហាជាបច្ច័យ ជាសេចក្ដី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, តណ្ហា ដែលកើតមានមកប្រាកដឡើង ព្រោះវេទនាជាបច្ច័យ ជាសេចក្ដី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, វេទនា ដែលកើតមានមកប្រាកដឡើង ព្រោះផស្សៈជាបច្ច័យ ជាសេចក្ដី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, ផស្សៈ ដែលកើតមានមកប្រាកដឡើង ព្រោះសឡាយតនៈជាបច្ច័យ ជាសេចក្ដី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, សឡាយតនៈ ដែលកើតមានមកប្រាកដឡើង ព្រោះនាមរូបជាបច្ច័យ ជាសេចក្ដី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, នាមរូប ដែលកើតមានមកប្រាកដឡើង ព្រោះវិញ្ញាណជាបច្ច័យ ជាសេចក្ដី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, វិញ្ញាណ ដែលកើតមានមកប្រាកដឡើង ព្រោះសង្ខារជាបច្ច័យ ជាសេចក្ដី ពិត

ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, សង្ខារទាំងឡាយ ដែលកើតមានមកប្រាកដឡើង ព្រោះអវិជ្ជាជាបច្ច័យ ជាសេចក្តីពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ។

អវិជ្ជាយ សង្ខារានំ បច្ចយដ្ឋោ តថោ អវិតថោ អនញ្ញថោ អវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, សង្ខារទាំងឡាយជាបច្ច័យដល់វិញ្ញាណ ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, វិញ្ញាណជាបច្ច័យដល់នាមរូប ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, នាមរូបជាបច្ច័យដល់សឡាយតនៈ ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, សឡាយតនៈជាបច្ច័យដល់ផស្សៈ ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, ផស្សៈ ជាបច្ច័យដល់វេទនា ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, វេទនាជាបច្ច័យដល់តណ្ហា ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, តណ្ហាជាបច្ច័យដល់ឧបាទាន ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, ឧបាទានជាបច្ច័យដល់ភព ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ, ភពជាបច្ច័យដល់ជាតិ ជាសេចក្តី ពិត ឥតប្រែប្រួល ឥតក្លាយ

ជាយ៉ាងដទៃ, ជាតិជាបច្ច័យដល់ជរានិងមរណៈ ជាសេចក្តីពិត ឥតប្រែប្រួល ឥតក្លាយជាយ៉ាងដទៃ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងច្បាស់ នូវរបស់ទាំងអស់នោះ។ ព្រោះហេតុនោះ ទើបបណ្ឌិតហៅថា តថាគត ព្រោះទ្រង់ត្រាស់ដឹងច្បាស់ នូវធម៌ទាំងឡាយដែលពិត។ ព្រះមានព្រះភាគទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គត្រាស់ដឹងច្បាស់នូវពួកធម៌ដែលពិត តាមសេចក្តីពិត ដោយប្រការយ៉ាងនេះ។

កថំ តថទស្សិតាយ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គឃើញនូវអារម្មណ៍ដែលពិត តើដូចម្តេច? គឺព្រះភគវាទ្រង់ជ្រាប ទ្រង់ឃើញ នូវរូបារម្មណ៍ ដែលមកកាន់គន្លងក្នុងចក្ខុទ្វារ របស់សត្វទាំងឡាយដែលប្រមាណមិនបាន ក្នុងលោកធាតុដែលប្រមាណមិនបាន ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ដោយអាការៈទាំងពួង។ រូបារម្មណ៍នោះ ព្រះអង្គទ្រង់ជ្រាប ទ្រង់ឃើញយ៉ាងនេះហើយ ទើបទ្រង់ចែកដោយអំណាចនៃឥដ្ឋារម្មណ៍ និងអនិដ្ឋាម្មណ៍ជាដើមក្តី ដោយអំណាចនៃបទដែលបាន ក្នុងអារម្មណ៍ដែលបានឃើញព្ទ

ជ្រាបនិងដឹងក្តី ដោយឈ្មោះជាច្រើន ដោយវារៈ១៣ ដោយន័យ៥២ តាមន័យជាដើមថា "រូបណា អាស្រ័យមហាភូតរូប ៤ មានពណ៌និងពន្លឺ ឃើញបាន ពាល់ត្រូវបាន ពណ៌ខៀវ ពណ៌លឿង, រូបនោះ ជារូបាយតនៈ ដូចម្តេច"? ដូច្នេះ ជារបស់ពិតតែម្យ៉ាង, របស់មិនពិត មិនមានទេ។ សូម្បីក្នុងសទ្ទារម្មណ៍ជាដើម ដែលមកកាន់គន្លងក្នុងសោតទ្វារជាដើម ក៏ន័យនេះដែរ។ សមដូចព្រះពុទ្ធដីកា ដែលព្រះភគវាទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណា ដែលលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពពួកសត្វទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស បានឃើញ បានឮ បានជ្រាប បានដឹង បានដល់ បានស្វែងរក បានជ្រើសរើសហើយ ដោយចិត្ត, តថាគតដឹងនូវអារម្មណ៍នោះ, តថាគតយល់ច្បាស់ នូវអារម្មណ៍នោះហើយ, អារម្មណ៍នោះ គឺតថាគតដឹងច្បាស់ហើយ, តថាគតមិនបានចូលទៅប្រកាន់នូវអារម្មណ៍នោះ (ដោយតណ្ហានិងទិដ្ឋិ)ទេ"[8]។ ព្រះមានព្រះភាគទ្រង់ព្រះនាមថាតថាគត ព្រោះ

---

8 អំ.ចតុក្ក.កាឡការាមសូត្រ។

ព្រះអង្គឃើញនូវអារម្មណ៍ដែលពិត ដោយប្រការយ៉ាងនេះឯង។ គប្បីជ្រាបការកើតនៃបទថា តថាគតោ ក្នុងអត្ថថាអ្នកឃើញពិត ក្នុងទីនេះ។

កថំ តថវាទិតាយ តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គពោលតែពាក្យពិត តើដូចម្តេច? គឺក្នុងរាត្រីណា ព្រះភគវាទ្រង់គង់លើអបរាជិតបល្ល័ង្ក ទៀបពោធិមណ្ឌដ្ឋាន ញាំញីនូវក្បាលរបស់មារទាំង៣ (គឺកិលេសមារ អភិសង្ខារ-មារ និងទេវបុត្តមារ) ហើយត្រាស់ដឹងនូវអនុត្តរសម្មា-សម្ពោធិញ្ញាណ និងក្នុងរាត្រីណា ព្រះអង្គទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ, ក្នុងរវាងរាត្រីទាំងពីរនុ៎ះ ក្នុងកាលប្រមាណ៤៥ព្រះវស្សា ព្រះពុទ្ធវចនៈឯណា ដែលព្រះភគវាទ្រង់ត្រាស់ហើយ ក្នុងបឋមពោធិកាលខ្លះ មជ្ឈិមពោធិកាលខ្លះ បច្ឆិមពោធិកាលខ្លះ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្មៈ វេទល្លៈ, ព្រះពុទ្ធវចនៈទាំងអស់នោះ គឺអ្នកណាមួយតិះដៀលមិនបាន ដោយអត្ថផង ដោយព្យញ្ជនៈផង មិនខ្វះ មិនលើស បរិបូណ៌ដោអាការៈទាំងពួង ញាំញីសេចក្តីស្រវឹងគឺរាគៈ ញាំញី

សេចក្ដីស្រវឹងគឺទោសៈ ញាំញីសេចក្ដីស្រវឹងគឺមោហៈ, សេចក្ដីខុសភ្លាត់សូម្បីមានប្រមាណប៉ុនចុងរោមទ្រាយ ក្នុងព្រះពុទ្ធវចនៈនោះ ក៏មិនមាន, ព្រះពុទ្ធវចនៈទាំងអស់នោះ ដូចគេប្រថាប់ដោយត្រាតែមួយផង ដូចវាល់ដោយនាឡិតែមួយផង ដូចគេថ្លឹងដោយជញ្ជីងតែមួយផង ជាព្រះតម្រាស់ពិត ឥតប្រែប្រួល។ ព្រោះហេតុនោះ ព្រះអង្គទ្រង់ត្រាស់ថា "ម្នាលចុន្ទ តថាគតត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរ ក្នុងរាត្រីណាផង បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងរាត្រីណាផង ពោល និយាយ សម្ដែងចេញ នូវពាក្យឯណា ក្នុងចន្លោះរាត្រី(ទាំងពីរ)នុ៎ះ ពាក្យទាំងអស់នោះ សុទ្ធតែពិតឥតប្រែក្លាយទៅជាយ៉ាងដទៃឡើយ។ ហេតុដូច្នោះហើយ បានជាគេហៅថា តថាគត[១]។ ពិតមែន គតស័ព្ទ ក្នុងបទថា តថាគតោ នេះ មានគទៈជាអត្ថ។ ព្រះមានព្រះភាគទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គពោលតែពាក្យពិតដោយប្រការយ៉ាងនេះឯង។

ម្យ៉ាងទៀត ការនិយាយ ឈ្មោះថាអាគទៈ អធិប្បាយថា វចនៈ(ពាក្យពោល)។ ព្រះមានព្រះភាគទ្រង់មានព្រះតម្រាស់

---

១ ទី.បាថិក.បាសាទិកសូត្រ។

ពិត ឥតវិបរិត ព្រោះធ្វើបំប្លែង ទ-អក្សរ ជា ត-អក្សរ គប្បីជ្រាបបទសិទ្ធិ (សម្រេចបទ) ក្នុងបទនេះ យ៉ាងនេះចុះ។

កចំ តថាការិតាយ តថាគតោ ទ្រង់ព្រះនាមថាតថាគតព្រោះព្រះអង្គធ្វើយ៉ាងនោះ តើដូចម្តេច? គឺព្រះកាយព្រះមានព្រះភាគ ស្របតាមព្រះវាចា, សូម្បីព្រះវាចា ក៏ស្របតាមព្រះកាយ, ព្រោះហេតុនោះ ទើបទ្រង់ជាយថាវាទីតថាការី (ត្រាស់យ៉ាងណាធ្វើយ៉ាងនោះ) យថាការីតថាវាទី (ធ្វើយ៉ាងណាត្រាស់យ៉ាងនោះ)។ ក៏ព្រះវាចារបស់ព្រះអង្គទ្រង់ជាយ៉ាងនោះ ត្រាស់យ៉ាងណា, សូម្បីព្រះកាយក៏ប្រព្រឹត្តទៅយ៉ាងនោះផង ព្រះកាយប្រព្រឹត្តទៅ យ៉ាងណា, សូម្បីព្រះវាចាក៏ត្រាស់ យ៉ាងនោះផង ព្រះវាចារបស់ព្រះអង្គទ្រង់ជាយ៉ាងនោះ ត្រាស់យ៉ាងណា, សូម្បីព្រះកាយក៏ប្រព្រឹត្តទៅយ៉ាងនោះផង ដូច្នោះ ទើបទ្រង់ព្រះនាមថាតថាគត។ ហេតុនោះ ព្រះអង្គបានត្រាស់ហើយថា "ម្នាលភិក្ខុទាំងឡាយតថាគតជាយថាវាទីតថាការី (ពោលយ៉ាងណាធ្វើយ៉ាងនោះ) យថាការីតថាវាទី (ធ្វើយ៉ាងណាពោលយ៉ាងនោះ)។ តថាគតជាយថាវាទីតថាការី យថាការីតថាវាទី ដូច្នេះ ហេតុនោះហើយ បានជាគេហៅថាតថាគត។ ព្រះមានព្រះភាគទ្រង់

ព្រះនាមថាតថាគត ព្រោះព្រះអង្គធ្វើយ៉ាងនោះ ដោយប្រការយ៉ាងនេះ។

កថំ អភិភវនដ្ឋេន តថាគតោ ទ្រង់ព្រះនាមថាតថាគត ព្រោះអត្ថថាព្រះអង្គគ្របសង្កត់នូវសព្វសត្វទាំងអស់ តើដូចម្តេច? គឺព្រះអង្គគ្រប់សង្កត់នូវសត្វទាំងអស់ ក្នុងលោកធាតុដែលមិនមានប្រមាណ ខាងលើដល់ភវគ្គព្រហ្ម ខាងក្រោមដល់អវីចិមហានរក ខាងទទឹងកំណត់ដោយទីបំផុតជុំវិញ ដោយសីលផង ដោយសមាធិផង ដោយបញ្ញាផង ដោយវិមុត្តិផង ។ ការថ្លឹង ឬប្រមាណនៃគុណនោះ មិនមាន, គឺថាព្រះអង្គជាអតុលៈ (អ្នកដែលគេថ្លឹងមិនបាន) ជាអប្បមេយ្យៈ (អ្នកដែលគេប្រមាណមិនបាន) ជាស្តេចលើស្តេចដ៏ប្រសើរ ជាទេវតាលើទេវតា ជាសក្កៈក្រៃលែងជាងសក្កៈ ជាព្រហ្មក្រៃលែងជាងព្រហ្ម។ ហេតុនោះ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកលើសលប់ មិនមានបុគ្គលដទៃគ្របសង្កត់បាន ជាអ្នកចង្អុលបង្ហាញនូវហេតុដ៏ពិត ជាអ្នកផ្សាយនូវអំណាចទៅ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ទាំងសមណៈព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស;

ព្រោះហេតុនោះ បានជាគេហៅថាតថាគត[10] ។

អ្នកសិក្សាគប្បីជ្រាបបទសិទ្ធិក្នុងបទថា តថាគតោ នោះយ៉ាងនេះថា៖ អគទៈ (អាគទៈ) ប្រែថា ឱសថ (ថ្នាំ) ក៏ដូចអគទៈ ដែលប្រែថា វាចា ដែរ។ ចុះអ្វីជាឱសថនុ៎ះ? គឺធម្មទេសនាដ៏វិលាស (ពីរោះ) និងការកពូនឡើងនៃបុណ្យ។ ព្រោះថា ព្រះអង្គមានអានុភាពច្រើន ជាពេទ្យដ៏ប្រសើរ ទ្រង់គ្របសង្កត់នូវពួកបរប្បវាទ(តិរ្ថិយ)ទាំងអស់ ក្នុងលោក ព្រមទាំងទេវលោក ដូចគ្របសង្កត់នូវពស់ ដោយឱសថទិព្វ។ ដូច្នេះ ព្រះមានព្រះភាគទ្រង់មានអគទៈ គឺធម្មទេសនាដ៏វិលាស និងការកពូនឡើងនៃបុណ្យ ដែលពិត ឥតវិបរិតដោយការគ្រប់សង្កត់នូវសត្តលោកទាំងអស់ ព្រោះហេតុនោះទើបទ្រង់ព្រះនាមថាតថាគត ព្រោះធ្វើបំប្លែង ទ-អក្សរ ជា ត-អក្សរ គប្បីជ្រាបបទសិទ្ធិ (សម្រេចបទ) ក្នុងបទនេះ យ៉ាងនេះចុះ។ ទ្រង់ព្រះនាមថាតថាគត ព្រោះអត្ថថាព្រះអង្គគ្របសង្កត់នូវសព្វសត្វទាំងអស់ ដោយប្រការយ៉ាងនេះឯង។

ម្យ៉ាងទៀត ព្រះអង្គទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គជ្រាបហើយ ដោយសេចក្តីពិតក៏មាន ទ្រង់ព្រះនាមថា

---

10 អំ.ចតុក្ក.លោកសូត្រ។

តថាគត ព្រោះព្រះអង្គដល់ហើយ នូវសេចក្តីពិតក៏មាន។ ស័ព្ទថា គតៈ (នេះ) មានអត្ថថា អវគតៈ (យល់ដឹង) អតីតៈ (ប្រព្រឹត្តកន្លង) បត្តៈ (ដល់ សម្រេច) បដិបន្នៈ (ប្រតិបត្តិ)។ បណ្តាអត្ថទាំង៤យ៉ាងនោះ ព្រះអង្គទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គជ្រាបហើយ នូវលោកទាំងអស់ ដោយសេចក្តីពិត គឺតីរណបរិញ្ញា, ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គប្រព្រឹត្តកន្លងហើយ នូវលោកសមុទ័យ ដោយសេចក្តីពិត គឺបហានបរិញ្ញា, ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គដល់ហើយ នូវលោកនិរោធ ដោយសេចក្តីពិត គឺសច្ឆិកិរិយា, ទ្រង់ព្រះនាមថាតថាគត ព្រោះព្រះអង្គប្រតិបត្តិហើយ នូវលោក-និរោធគាមិនីបដិបទា ដោយសេចក្តីពិត។ ព្រោះហេតុនោះ តម្រាស់ឯណា ដែលព្រះភគវាទ្រង់ត្រាស់ថា៖

"ម្នាលភិក្ខុទាំងឡាយ លោក គឺតថាគតដឹងច្បាស់ហើយ, តថាគតប្រាសចាកលោកហើយ; ម្នាលភិក្ខុទាំងឡាយ លោកសមុទ័យ គឺតថាគតដឹងច្បាស់ហើយ, តថាគតលះបង់លោកសមុទ័យហើយ; ម្នាលភិក្ខុទាំងឡាយ លោកនិរោធ គឺតថាគតដឹងច្បាស់ហើយ, តថាគតធ្វើឲ្យជាក់ច្បាស់លោកនិរោធហើយ;

ម្នាលភិក្ខុទាំងឡាយ លោកនិរោធគាមិនីបដិបទា គឺតថាគតដឹងច្បាស់ហើយ, តថាគតចម្រើនលោកនិរោធគាមិនីបដិបទាហើយ; ម្នាលភិក្ខុទាំងឡាយ សច្ចៈឯណា ដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដែលពពួកសត្វ ទាំងសមណៈព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស បានឃើញ បានឮ បានជ្រាប បានដឹង បានដល់ បានស្វែងរក បានជ្រើសរើសហើយ ដោយចិត្ត, សច្ចៈទាំងអស់នោះ គឺតថាគតដឹងច្បាស់ហើយ, ព្រោះហេតុនោះ ទើបគេហៅថាតថាគត៉[11]។

សូម្បីអត្ថនៃពាក្យថាតថាគតនោះ ក៏គប្បីជ្រាបយ៉ាងនេះ។ មួយទៀត នេះ ក៏គ្រាន់តែជាប្រធាន ក្នុងការបំភ្លឺភាពតថាគត របស់ព្រះតថាគតប៉ុណ្ណោះ។ មានតែព្រះតថាគតហ្នឹងឯង គប្បីពណ៌នានូវភាពតថាគត របស់ព្រះតថាគតដោយអាការៈទាំងពួងបាន។

11 អំ.ចតុក្ក.លោកសូត្រ។

## ពាក្យថា **អរហំ**

ឯក្នុងបទថា **អរហំ សម្មាសម្ពុទ្ធោ** ដំបូងគប្បីជ្រាបថា **អរហំ** ដោយហេតុទាំងនេះ គឺ**អារកត្តា** ទ្រង់ព្រះនាមថាអរហំ ព្រោះព្រះអង្គឆ្ងាយចាកកិលេសហើយ១ **អរីនំ ហតត្តា** ព្រោះព្រះអង្គកម្ចាត់សត្រូវគឺកិលេសបានហើយ១ **អរានំ ហតត្តា** ព្រោះព្រះអង្គកម្ទេចកាំនៃសំសារចក្របានហើយ១ **បច្ចយា-ទីនំ អរហត្តា** ព្រោះព្រះអង្គគួរដល់ទក្ខិណាវត្ថុទាំងឡាយមានបច្ច័យជាដើម១ **បាបករណេ រហាភាវា** ព្រោះព្រះអង្គមិនមានទីកំបាំងក្នុងការធ្វើបាប១ ។

ពិតមែន ព្រះមានព្រះភាគទ្រង់ជាអ្នកឆ្ងាយ គឺទ្រង់ឋិតនៅក្នុងទីឆ្ងាយសែនឆ្ងាយចាកកិលេសទាំងពួង ព្រោះទ្រង់កម្ចាត់កិលេសទាំងឡាយ ព្រមទាំងវាសនា (គឺកាយបយោគនិងវចីបយោគ)បានហើយ ដោយមគ្គ ព្រោះហេតុនោះ ទ្រង់ព្រះនាមថាអរហំ ព្រោះព្រះអង្គឆ្ងាយចាកកិលេសហើយ។

សោ តតោ អារកា នាម, យស្ស យេនាសមង្គិតា;
អសមង្គី ច ទោសេហិ, នាថោ តេនា**រហំ** មតោ។

ព្រះមានព្រះភាគអង្គឯណា ទ្រង់មិនប្រកបដោយ
កិលេសណា និងមិនប្រកបដោយទោសទាំងឡាយ

ណា, ព្រះមានព្រះភាគអង្គនោះ ទ្រង់ជាទីពឹងនៃលោក ឈ្មោះថាជាអ្នកឆ្ងាយចាកកិលេស និងទោសទាំងនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ។

មួយទៀត សត្រូវគឺកិលេសទាំងឡាយនោះ គឺព្រះអង្គកម្ចាត់ហើយ ដោយមគ្គ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គកម្ចាត់សត្រូវគឺកិលេសបានហើយ។

យស្មា រាគាទិសង្ខាតា, សព្វេបិ អរយោ ហតា;
បញ្ញាសត្ថេន នាថេន, តស្មាបិ **អរហំ** មតោ។

សូម្បីពួកសត្រូវគឺកិលេសទាំងអស់ គឺព្រះលោកនាថទ្រង់កម្ចាត់ហើយ ដោយសស្ត្រាគឺបញ្ញា ព្រោះហេតុណា, ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ។

មួយទៀត សំសារចក្រ ដែលមានដុំសម្រេចហើយ ដោយអវិជ្ជានិងភវតណ្ហា មានកាំសម្រេចហើយ ដោយអភិសង្ខារ មានបុញ្ញាភិសង្ខារជាដើម មានខ្នងកង់សម្រេចហើយ ដោយជរានិងមរណៈ ស៊កភ្លៅសម្រេចហើយ ដោយអាសវសមុទយៈ បញ្ចូលទុក ក្នុងតួរថ គឺត្រៃភព វិលទៅរហូតអស់កាលរកខាងដើមមិនមានទុំៈ ឯណា, កាំទាំងឡាយទាំងអស់ របស់សំសារចក្រនោះ គឺព្រះអង្គទ្រង់ឋិតនៅលើផែនដី

គឺសីល ដោយព្រះបាទគឺវីរិយៈ ទ្រង់យកព្រះហស្តគឺសទ្ធា ចាប់យកពូថៅគឺព្រះញាណ (ដែលសំលៀងហើយដោយថ្ម គឺសមាធិ) ធ្វើនូវការអស់នៃកម្ម ទ្រង់កម្ចាត់ចោលអស់ហើយ ក្បែរពោធិមណ្ឌដ្ឋាន ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គកម្ទេចកាំ នៃសំសារចក្របានហើយ។

មួយវិញទៀត សំសារវដ្ត ដែលមានទីបំផុតខាងដើម គឺគេមិនអាចដឹងបាន ឈ្មោះថា **សំសារចក្រ**។ ក៏អវិជ្ជា ជាដុំរបស់វា ព្រោះជាខាងដើម, ជរានិងមរណៈ ជាខ្នងកង់ ព្រោះជាខាងចុង, ធម៌ទាំង១០ ដ៏សេស (គឺសង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ជាតិ) ជាកាំ ព្រោះមានអវិជ្ជាជាខាងដើម មានជរានិងមរណៈជាខាងចុង។ បណ្ដាធម៌ទាំងនោះ ការមិនដឹង ក្នុងអរិយសច្ចទាំងឡាយ មានទុក្ខសច្ចជាដើម ឈ្មោះថា**អវិជ្ជា**។ គឺអវិជ្ជាក្នុងកាមភព ជាបច្ច័យនៃសង្ខារទាំងឡាយក្នុងកាមភព, អវិជ្ជាក្នុងរូបភព ជាបច្ច័យនៃសង្ខារទាំងឡាយក្នុងរូបភព, អវិជ្ជាក្នុងអរូបភព ជាបច្ច័យនៃសង្ខារទាំងឡាយ ក្នុងអរូបភព។ សង្ខារទាំងឡាយ ក្នុងកាមភព ជាបច្ច័យនៃបដិសន្ធិវិញ្ញាណក្នុងកាមភព, សង្ខារទាំងឡាយ ក្នុងរូបភព ជាបច្ច័យនៃ

បដិសន្ធិវិញ្ញាណក្នុងរូបភព, សង្ខារទាំងឡាយ ក្នុងអរូបភព ជាបច្ច័យនៃបដិសន្ធិវិញ្ញាណក្នុងអរូបភព។ បដិសន្ធិវិញ្ញាណ ក្នុងកាមភព ជាបច្ច័យនៃនាមរូប ក្នុងកាមភព, បដិសន្ធិវិញ្ញាណក្នុងរូបភព ជាបច្ច័យនៃនាមរូបក្នុងរូបភព, តែបដិសន្ធិវិញ្ញាណ ក្នុងអរូបភព ជាបច្ច័យនៃនាមតែម្យ៉ាង។ នាមរូប ក្នុងកាមភព ជាបច្ច័យនៃអាយតនៈ៦ ក្នុងកាមភព, នាមរូប ក្នុងរូបភព ជាបច្ច័យនៃអាយតនៈ៣ (គឺចក្ខុ សោតៈ មនៈ) ក្នុងរូបភព, ឯនាម ក្នុងអរូបភព ជាបច្ច័យនៃ អាយតនៈតែ១ (គឺមនៈ)។ អាយតនៈ៦ ក្នុងកាមភព ជាបច្ច័យនៃផស្សៈ៦ ក្នុងកាមភព, អាយតនៈ៣ ក្នុងរូបភព ជាបច្ច័យនៃផស្សៈ៣ ក្នុងរូបភព, អាយតនៈ១ ក្នុងអរូបភព ជាបច្ច័យនៃផស្សៈ១ ។ ផស្សៈ៦ ក្នុងកាមភពជាបច្ច័យនៃវេទនា៦ ក្នុងកាមភព, ផស្សៈ៣ ក្នុងរូបភព ជាបច្ច័យនៃវេទនា៣ ក្នុងរូបភព, ផស្សៈ១ ក្នុងអរូបភព ជាបច្ច័យនៃវេទនា១។ វេទនា៦ ក្នុងកាមភពជាបច្ច័យនៃតណ្ហា៦ ក្នុងកាមភព, វេទនា៣ ក្នុងរូបភព ជាបច្ច័យនៃតណ្ហា៣ ក្នុងរូបភព, វេទនា១ ក្នុងអរូបភព ជាបច្ច័យនៃតណ្ហា១។ តណ្ហាក្នុងភពនោះៗ ជាបច្ច័យនៃឧបាទានក្នុងរូបភពនោះ។ ធម៌ទាំងឡាយដែលនៅ

សល់ មានឧបាទានជាដើម ជាបច្ច័យនៃធម៌ទាំងឡាយ មានភពជាដើម ។

សំណួរថា រឿងនោះ តើដូចម្ដេច? ចម្លើយថា បុគ្គលខ្លះក្នុងលោកនេះ ប្រាថ្នាថា "អញនឹងបរិភោគទាំងឡាយ" ហើយប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយចិត្ត ព្រោះកាមុបាទាន (កាប្រកាន់មាំក្នុងកាម)ជាបច្ច័យ, ព្រោះការបរិបូណ៌ដោយទុច្ចរិត គេក៏រមែងទៅកើត ក្នុងអបាយ។ កម្មដែលជាហេតុនៃការកើតឡើងក្នុងអបាយ របស់គេ ជាកម្មភព, ខន្ធទាំងឡាយដែលកើតឡើងហើយព្រោះកម្ម ជាឧបបត្តិភព, ការកើតឡើងនៃខន្ធទាំងឡាយ ជាជាតិ, ការចាស់ ជាជរា, ការបែកធ្លាយជាមរណៈ។

បុគ្គលខ្លះទៀត ប្រាថ្នាថា "អញនឹងសោយសម្បត្តិក្នុងឋានសួគ៌" ហើយប្រព្រឹត្តសុចរិត (ដោយកាយវាចាចិត្ត) ព្រោះកាមុបាទានជាបច្ច័យ, ព្រោះការបរិបូណ៌ដោយសុចរិត គេក៏រមែងទៅកើតក្នុងឋានសួគ៌។ កម្មដែលជាហេតុនៃការកើតឡើង ក្នុងទីនោះ របស់គេ ជាកម្មភព, ខន្ធទាំងឡាយដែលកើតឡើងហើយព្រោះកម្ម ជាឧបបត្តិភព, ការកើត

ឡើងនៃខន្ធទាំងឡាយ ជាជាតិ, ការចាស់ ជាជរា, ការបែកធ្លាយ ជាមរណៈ។

ចំណែកបុគ្គលខ្លះទៀត ប្រាថ្នាថា "អញនឹងសោយសម្បត្តិក្នុងព្រហ្មលោក" ហើយចម្រើនមេត្តា ចម្រើនករុណា ចម្រើនមុទិតា ចម្រើនឧបេក្ខា ព្រោះកាមុបាទានជាបច្ច័យដែរ, ព្រោះការបរិបូណ៌ដោយភាវនា គេក៏រមែងទៅកើតក្នុងព្រហ្មលោក។ កម្មដែលជាហេតុនៃការកើតឡើង ក្នុងទីនោះរបស់គេ ជាកម្មភព, ខន្ធទាំងឡាយដែលកើតឡើងហើយព្រោះកម្ម ជាឧបបត្តិភព, ការកើតឡើងនៃខន្ធទាំងឡាយជាជាតិ, ការចាស់ ជាជរា, ការបែកធ្លាយ ជាមរណៈ។

បុគ្គលខ្លះទៀត ប្រាថ្នាថា "អញនឹងសោយសម្បត្តិក្នុងអរូភព" ហើយចម្រើនសមាបត្តិ មានអាកាសានញ្ចាយតនៈជាដើម ព្រោះកាមុបាទានជាបច្ច័យដែរ, ព្រោះការបរិបូណ៌ដោយភាវនា គេក៏រមែងទៅកើតក្នុងអរូបភពនោះៗ ។ កម្មដែលជាហេតុនៃការកើតឡើង ក្នុងទីនោះៗ របស់គេ ជាកម្មភព, ខន្ធទាំងឡាយដែលកើតឡើងហើយព្រោះកម្ម ជាឧបបត្តិភព, ការកើតឡើងនៃខន្ធទាំងឡាយ ជាជាតិ, ការចាស់ ជាជរា, ការបែកធ្លាយ ជាមរណៈ។ ន័យសូម្បីក្នុងការ

ប្រកបទាំងឡាយ មានឧបាទានដែលនៅសល់ ជាដើមហេតុ ក៏មានន័យនេះដូចគ្នាដែរ។

បញ្ញា ក្នុងការកំណត់បច្ច័យថា "អវិជ្ជា ជាហេតុ, សង្ខារទាំងឡាយ កើតឡើងហើយអំពីហេតុ, អវិជ្ជានិងសង្ខារទាំងពីរនេះ កើតឡើងហើយអំពីហេតុដូចគ្នាដែរ" នេះ ឈ្មោះថាធម្មដ្ឋិតិញាណ។ បញ្ញា ក្នុងការកំណត់បច្ច័យថា "អវិជ្ជា ជាហេតុ, សង្ខារទាំងឡាយ កើតឡើងហើយអំពីហេតុ, អវិជ្ជានិងសង្ខារទាំងពីរនេះ កើតឡើងហើយអំពីហេតុដូចគ្នា ទាំងអតីតទ្ធា ទាំងអនាគតទ្ធា" ដូច្នេះ ឈ្មោះថាធម្មដ្ឋិតិញាណដោយប្រការដូច្នេះឯង។ បណ្ឌិតគប្បីពង្រីកបទទាំងអស់ ឲ្យបានពិស្តារ តាមន័យនេះចុះ។

ក្នុងធម៌ទាំងនោះ អវិជ្ជានិងសង្ខារ ជាសង្ខេប១ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ជាសង្ខេប១ តណ្ហា ឧបាទាន និងភព ជាសង្ខេប១ ជាតិនិងជរាមរណៈ ជាសង្ខេប១។ ក្នុងសង្ខេបទាំង៤នោះ សង្ខេបខាងដើម ជាអតីតទ្ធា, សង្ខេបពីរត្រង់កណ្ដាល ជាបច្ចុប្បន្នទ្ធា, (សង្ខេបខាងចុងគឺ) ជាតិនិងជរាមរណៈ ជាអនាគតទ្ធា។ មួយទៀត ក្នុងធម៌ទាំងនោះ តណ្ហាឧបាទាននិងភព ជាធម៌គឺលោកកាន់

យកហើយ ដោយការកាន់យកអវិជ្ជានិងសង្ខារ ព្រោះហេតុនោះ ធម៌ទាំង៥នេះ ជាកម្មវដ្តៈ ក្នុងអតីតៈ, ធម៌៥(នេះ) គឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ជាវិបាកវដ្តៈ ក្នុងកាលឥឡូវនេះ, អវិជ្ជានិងសង្ខារ ជាធម៌គឺលោកកាន់យកហើយ ដោយការកាន់យក តណ្ហា ឧបាទាន និងភព ព្រោះហេតុនោះ ធម៌ទាំង៥នេះ ជាកម្មវដ្តៈ ក្នុងកាលឥឡូវនេះ, ធម៌៥នេះ ជាវិបាកវដ្តៈ ក្នុងកាលតទៅ ព្រោះធម៌ ៥ ដែលលោកសម្តែងហើយ ដោយការសំអាងយកជាតិ និងជរាមរណៈ។ ធម៌ទាំងនោះ មានដោយអាការៈ២០ ។ ក្នុងធម៌ទាំងនោះ ចន្លោះសង្ខារនិងវិញ្ញាណ ជាសន្ធិ១ ចន្លោះវេទនានិងតណ្ហា ជាសន្ធិ១ ចន្លោះភពនិងជាតិ ជាសន្ធិ១ យ៉ាងនេះឯង។ ព្រះមានព្រះភាគ ទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់ដឹងច្បាស់ ទ្រង់ចាក់ធ្លុះ នូវបដិច្ចសមុប្បាទ ដែលមានសង្ខេប៤ អទ្ធា៣ អាការៈ២០ សន្ធិ៣ នុ៎ះ ដោយអាការៈទាំងពួង តាមន័យដូចពោលមកនេះឯង។ ការជ្រាបនោះ ឈ្មោះថាញាណ ព្រោះអត្ថថាដឹង, ឈ្មោះថាញាណ ព្រោះអត្ថថាដឹងជាក់ច្បាស់, ហេតុនោះ ទើបលោកពោលថា "បញ្ញា ក្នុងការកំណត់បច្ច័យ ឈ្មោះថាធម្មដ្ឋិតិញាណ"។ ព្រះ

ភគវា កាលទ្រង់ជ្រាបនូវធម៌ទាំងនោះតាមសេចក្ដីពិត ដោយធម្មដ្ឋិតិញាណនេះហើយ ទ្រង់នឿយណាយ ធុញទ្រាន់ ជិនឆ្អន់ ក្នុងធម៌ទាំងឡាយនោះ ឈ្មោះថាទ្រង់កម្ទេច កម្ចាត់ទម្លាយ នូវកាំនៃសំសារចក្រនេះ មានប្រការដូចដែលបានពោលមកហើយ។ ទ្រង់ព្រះនាមថាអរហំ ព្រោះព្រះអង្គកម្ទេចកាំនៃសំសារចក្របានហើយ ដោយប្រការយ៉ាងនេះ។

អរា សំសារចក្កស្ស, ហតា ញាណាសិនា យតោ;
លោកនាថេន តេនេស, **អរហា**ន្តិ បវុច្ចតិ ។

កាំទាំងឡាយនៃសំសារចក្រ គឺព្រះលោកនាថ ទ្រង់កម្ទេចចោលហើយ ដោយសស្ត្រាគឺបញ្ញា ព្រោះហេតុណា, ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អរហំ**។

ន័យមួយទៀត ព្រះមានព្រះភាគទ្រង់គួរ (ដើម្បីទទួល) នូវបច្ច័យទាំងឡាយ មានចីវរជាដើម និងការបូជាដ៏វិសេស ព្រោះព្រះអង្គជាអគ្គទក្ខិណេយ្យបុគ្គល។ ក៏ព្រោះហេតុនោះហ្នឹងឯង កាលដែលព្រះតថាគតទ្រង់កើតឡើងហើយ ពួកបុគ្គលខ្លះ អ្នកមានស័ក្ដធំ ទាំងទេវតាទាំងមនុស្ស តែងមិនធ្វើការបូជា ក្នុងទីដទៃឡើយ។ ពិតមែនហើយ សហម្បតិព្រហ្មបានបូជាព្រះតថាគត កម្រងរតនៈ ប៉ុនភ្នំសិនេរុ។ ឯពួក

ទេវតានិងមនុស្សដទៃទៀត មានព្រះបាទពិម្ពិសារ និងព្រះបាទកោសលជាដើម ក៏បានបូជាតាមកម្លាំងរបស់ទ្រង់ដែរ។ ចំណែកឯព្រះអសោកមហារាជ បានចាត់ចែងចំណាយទ្រព្យប្រមាណ៩៦កោដិ ទ្រង់ឲ្យពួកជាងកសាងវិហារ ៨ម៉ឺន ៤ពាន់ ប្រតិស្ឋានទុកក្នុងជម្ពូទ្វីបទាំងអស់ ឧទ្ទិសចំពោះព្រះមានព្រះភាគ សូម្បីទ្រង់បរិនិព្វានទៅហើយក្តី។ នឹងចាំបាច់ពោលថ្វី ដល់ការបូជាដ៏វិសេសដទៃទៀត ព្រោះហេតុនោះ ទ្រង់ព្រះនាមថាអរហំ ព្រោះព្រះអង្គគួរដល់ទក្ខិណាវត្ថុទាំងឡាយ មានបច្ច័យជាដើម ដោយប្រការយ៉ាងនេះ។

បូជាវិសេសំ សហ បច្ចយេហិ,
យស្មា អយំ អរហតិ លោកនាថោ;
អត្ថានុរូបំ **អរហន្តិ** លោកេ,
តស្មា ជិនោ អរហតិ នាមមេតំ។

ព្រះលោកនាថអង្គនេះ ទ្រង់គួរ (ដើម្បីទទួល) នូវការបូជាដ៏វិសេស ព្រមទាំងបច្ច័យទាំងឡាយ ព្រោះហេតុណា, ព្រោះហេតុនោះ ព្រះអង្គជាអ្នកឈ្មោះ គួរ (ដើម្បីទទួល) នូវព្រះនាមនេះថា **អរហំ** ក្នុងលោក ដែលសមគួរដល់អត្ថ (នៃអរហសព្ទ)។

អត្ថមួយទៀតថា បុគ្គលពាលទាំងឡាយពួកខ្លះ ក្នុងលោក សម្គាល់ថាខ្លួនជាបណ្ឌិត រមែងធ្វើបាប ក្នុងទីស្ងាត់កំបាំង ព្រោះភ័យខ្លាចខូចកេរ្តិ៍ឈ្មោះ យ៉ាងណា, ព្រះភគវាអង្គនោះ ទ្រង់មិនធ្វើបាប ក្នុងទីណាៗ យ៉ាងនោះទេ; ព្រោះហេតុនោះ ទ្រង់ព្រះនាមថាអរហំ ព្រោះព្រះអង្គមិនមានទីស្ងាត់កំបាំង ក្នុងការធ្វើបាប (ដោយប្រការយ៉ាងនេះ)។

យស្មា នត្ថិ រហោ នាម, បាបកម្មេសុ តាទិនោ;
រហាភាវេន តេនេស, **អរហំ** ឥតិ វិស្សុតោ។

ឈ្មោះថាទីកំបាំង ក្នុងការធ្វើបាបទាំងឡាយ រមែងមិនមាន ដល់ព្រះមានព្រះភាគជាអ្នកនឹងធឹង ព្រោះហេតុណា, ព្រោះហេតុនោះ ទើបទ្រង់ប្រាកដព្រះនាមថា**អរហំ** ព្រោះព្រះអង្គមិនមានទីកំបាំងក្នុងការធ្វើបាប។

អារកត្តា ហតត្តា ច, កិលេសារីន សោ មុនិ;
ហតសំសារចក្ការោ, បច្ចយាទីន ចារហោ;
ន រហោ ករោតិ បាបានិ, **អរហំ** តេន វុច្ចតិ។

ព្រះមុនីអង្គនោះ ទ្រង់ព្រះនាមនេះថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកកិលេស១ ព្រោះព្រះអង្គកម្ចាត់សត្រូវគឺកិលេស១ ព្រោះព្រះអង្គកម្ទេចកាំនៃសំសារចក្រ១

ព្រោះព្រះអង្គគួរដល់ទក្ខិណាវត្ថុទាំងឡាយ មានបច្ច័យជាដើម១ ព្រោះព្រះអង្គមិនធ្វើបាបក្នុងទីកំបាំង១ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អរហំ** ដោយប្រការទាំងពួង ដោយពណ៌នាមកនេះឯង។

ពាក្យថា **សម្មាសម្ពុទ្ធោ**

រីឯព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវធម៌ទាំងពួង ដោយប្រពៃនិងដោយព្រះអង្គឯង។ ពិតដូច្នោះមែន ព្រះអង្គទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួង ដោយប្រពៃនិងដោយព្រះអង្គឯង គឺទ្រង់ត្រាស់ដឹងនូវធម៌ទាំងឡាយដែលគួរដឹងដោយបញ្ញាដ៏ក្រៃលែង ដោយភាពជាធម៌ដែលគួរដឹងដោយបញ្ញាដ៏ក្រៃលែង, ត្រាស់ដឹងនូវធម៌ទាំងឡាយដែលគួរកំណត់ដឹង ដោយភាពជាធម៌ដែលគួរកំណត់, ត្រាស់ដឹងនូវធម៌ទាំងឡាយដែលគួរលះ ដោយភាពជាធម៌ដែលគួរលះ, ត្រាស់ដឹងនូវធម៌ទាំងឡាយដែលគួរធ្វើឲ្យជាក់ច្បាស់ ដោយភាពជាធម៌ដែលគួរធ្វើឲ្យជាក់ច្បាស់, ត្រាស់ដឹងនូវធម៌ទាំងឡាយដែលគួរចម្រើន ដោយភាពជាធម៌ដែលគួរចម្រើន។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ទុកថា ៖

អភិញ្ញេយ្យំ អភិញ្ញាតំ, ភាវេតព្វញ្ច ភាវិតំ;
បហាតព្វំ បហីនំ មេ, តស្មា ពុទ្ធោស្មិ ព្រាហ្មណ។

វត្ថុដែលគួរដឹងដោយបញ្ញាដ៏ក្រៃលែង តថាគតបានដឹងដោយបញ្ញាដ៏ក្រៃលែងហើយ, វត្ថុដែលគួរចម្រើនតថាគតបានចម្រើនហើយ, (វត្ថុដែលគួរកំណត់ដឹងតថាគតបានកំណត់ដឹងហើយ,) វត្ថុដែលគួរលះបង់តថាគតបានលះបង់ហើយ, ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ តថាគតទើបជាអ្នកត្រាស់ដឹង[12]។

អត្ថមួយទៀតថា ព្រះមានព្រះភាគទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួង ដោយប្រពៃនិងដោយព្រះអង្គឯង ដោយលើកឡើងនូវបទមួយៗ យ៉ាងនេះថា "ចក្ខុ ជាទុក្ខសច្ច, តណ្ហាដែលមានមកអំពីភពមុន ដែលជាហេតុឲ្យកើតឡើង ព្រោះភាពជាតួហេតុដែលជាឫសគល់នៃចក្ខុនោះ ជាសមុទយសច្ច, ការមិនប្រព្រឹត្តទៅនៃចក្ខុនិងចក្ខុសមុទ័យទាំងពីរ ជានិរោធសច្ច, បដិបទាដែលជាហេតុដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច"។ ក្នុងសោតៈ ឃានៈ ជិវ្ហា កាយ និងមនៈ ក៏ន័យនេះដែរ។

---

12 ម.ម.សេលសូត្រ។

អាយតនៈ(អារម្មណ៍)៦ គឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ធម្មារម្មណ៍។

កងវិញ្ញាណ៦ គឺចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ។

ផស្សៈ៦ គឺចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស។

វេទនា៦ ចក្ខុសម្ផស្សជាវេទនា សោតសម្ផស្សជាវេទនា ឃានសម្ផស្សជាវេទនា ជិវ្ហាសម្ផស្សជាវេទនា កាយសម្ផស្សជាវេទនា មនោសម្ផស្សជាវេទនា។

សញ្ញា៦ គឺរូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញា។

ចេតនា៦ គឺរូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា។

កងតណ្ហា៦ គឺរូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា។

វិតក្កៈ៦ គឺរូបវិតក្កៈ សទ្ទវិតក្កៈ គន្ធវិតក្កៈ រសវិតក្កៈ ផោដ្ឋព្វវិតក្កៈ ធម្មវិតក្កៈ។

វិចារៈ៦ គឺរូបវិចារៈ សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ

ផោដ្ឋព្វវិចារៈ ធម្មវិចារៈ។

ខន្ធ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ វិញ្ញាណខន្ធ។

កសិណ១០ គឺបថវីកសិណ អាបោកសិណ តេជោកសិណ វាយោកសិណ នីលកសិណ បីតកសិណ លោហិតកសិណ ឱទាតកសិណ អាកាសកសិណ វិញ្ញាណកសិណ។

អនុស្សតិ១០គឺពុទ្ធានុស្សតិ ធម្មានុស្សតិ សង្ឃានុស្សតិ សីលានុស្សតិ ចាគានុស្សតិ ទេវតានុស្សតិ មរណានុស្សតិ កាយគតាសតិ អានាបានស្សតិ ឧបសមានុស្សតិ។

សញ្ញា១០ គឺឧទ្ធុមាតកសញ្ញា វិនីលកសញ្ញា វិបុព្វកសញ្ញា វិច្ឆិទ្ទកសញ្ញា វិក្ខាយិតកសញ្ញា វិក្ខិត្តកសញ្ញា ហតវិក្ខិត្តកសញ្ញា លោហិតកសញ្ញា បុឡុវកសញ្ញា អដ្ឋិកសញ្ញា។

អាការៈ៣២ គឺកេសា (សក់) លោមា (រោម) នខា (ក្រចក) ទន្តា (ធ្មេញ) តចោ (ស្បែក), មំសំ (សាច់) នហារូ (សរសៃ) អដ្ឋី (ឆ្អឹង) អដ្ឋិមិញ្ជំ (ខួរក្នុងឆ្អឹង) វក្កំ (តម្រងនោម), ហទយំ (បេះដូង) យកនំ (ថ្លើម) កិលោមកំ (វាវ) បិហកំ (ក្រពះ) បប្ផាសំ (សួត), អន្តំ (ពោះវៀនធំ) អន្តគុណំ (ពោះ

វៀនតូច) ឧទរិយំ (អាហារថ្មី) ករីសំ (អាហារចាស់) មត្ថលុង្គំ (ខួរក្នុងក្បាល), បិត្តំ (ប្រមាត់) សេម្ហំ (ស្លេស្ម៍) បុព្វោ (ខ្ទុះ) លោហិតំ (ឈាម) សេទោ (ញើស) មេទោ (ខ្លាញ់ខាប់), អស្សុ (ទឹកភ្នែក) វសា (ខ្លាញ់រាវ) ខេឡោ (ទឹកមាត់) សិង្ឃាណិកា (ទឹកសំបោរ) លសិកា (ទឹករំអិល) មុត្តំ (ទឹកមូត្រ)។

អាយតនៈ១២ គឺចក្ខាយតនៈ រូបាយតនៈ សោតាយតនៈ សទ្ទាយតនៈ ឃានាយតនៈ គន្ធាយតនៈ ជិវ្ហាយតនៈ រសាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ ធម្មាយតនៈ។

ធាតុ១៨ គឺចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ, ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ។

ភព៩ គឺកាមភព រូបភព អរូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព បញ្ចវោការភព ចតុវោការភព ឯកវោការភព ។

ឈាន៤ គឺបឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថ-

ជ្ឈាន។

អប្បមញ្ញា៤ គឺមេត្តាភាវនា ករុណាភាវនា មុទិតាភាវនា ឧបេក្ខាភាវនា។

អរូបសមាបត្តិ៤ គឺអាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ។

អង្គនៃបដិច្ចសមុប្បាទ គឺជរាមរណៈ ជាតិ ភព ឧបាទាន តណ្ហា វេទនា ផស្សៈ សឡាយតនៈ នាមរូប វិញ្ញាណ សង្ខារ អវិជ្ជា ដោយបដិលោម, អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ជាតិ ជរាមរណៈ ដោយអនុលោម បណ្ឌិតគប្បីជ្រាបប្រកបតាមន័យនេះដែរ។ នេះជាការប្រកបបទមួយៗ ក្នុងសព្វធម៌នោះ។ ព្រះភគវាទ្រង់ត្រាស់ដឹង ទ្រង់ត្រាស់ដឹងដោយអនុលោម ទ្រង់ត្រាស់ដឹងដោយបដិលោម នូវធម៌ទាំងពួង ដោយប្រពៃ និងដោយព្រះអង្គឯង ដោយលើកឡើងនូវបទមួយៗ យ៉ាងនេះថា "ជរាមរណៈ ជាទុក្ខសច្ច, តណ្ហាដែលមានមកអំពីភពមុន ដែលជាហេតុឲ្យកើតឡើង ព្រោះភាពជាតួហេតុដែលជាឫសគល់នៃជរាមរណៈនោះ ជាសមុទយសច្ច, ការមិន

ប្រព្រឹត្តទៅនៃជរាមរណៈ និងជរាមរណសមុទ័យទាំងពីរ ជានិរោធសច្ច, បដិបទា ដែលជាហេតុដឹងច្បាស់នូវនិរោធ ជាមគ្គសច្ច៉។ ព្រោះហេតុនោះ ទើបលោកពោលថា "ព្រះមានព្រះភាគទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវធម៌ទាំងពួង ដោយប្រពៃនិងដោយព្រះអង្គឯង៉។

អដ្ឋកថាសូត្រទី១ ចប់៕

## អដ្ឋកថាសូត្រទី២

ក្នុងសូត្រទី២ បទថា **ឃាតុនាខោ** បានដល់ ឧបត្តិ ការសម្រេច។ ពីរបទថា **ទុល្លភោ លោកស្មឹ** បានដល់ បានដោយលំបាក បានដោយលំបាកបំផុត បានដោយលំបាកក្រៃលែង។ ដែលឈ្មោះថា បានដោយលំបាក ព្រោះហេតុអ្វី? ព្រោះព្រះអង្គមិនអាចបំពេញទានបារមី អស់វារៈតែម្តង ហើយបានជាព្រះពុទ្ធទេ, ព្រះអង្គមិនអាចបំពេញទានបារមី អស់វារៈ២ដង... ១០ដង... ២០ដង... ៥០ដង... ១រយដង... ១ពាន់ដង... ១សែនដង... អស់វារៈ១សែនកោដិដង ហើយបានជាព្រះពុទ្ធទេ; ព្រះអង្គមិនអាចបំពេញទានបារមី អស់១ថ្ងៃ... ២ថ្ងៃ... ១០ថ្ងៃ... ២០ថ្ងៃ... ៥០ថ្ងៃ... ១រយថ្ងៃ... ១ពាន់

ថ្ងៃ... ១សែនថ្ងៃ... អស់១សែនកោដិថ្ងៃ ហើយបានជាព្រះពុទ្ធទេ; ព្រះអង្គមិនអាចបំពេញទានបារមី អស់១ខែ... ២ខែ... ១០ខែ... ២០ខែ... ៥០ខែ... ១រយខែ... ១ពាន់ខែ... ១សែនខែ... អស់១សែនកោដិខែហើយបានជាព្រះពុទ្ធទេ; ព្រះអង្គមិនអាចបំពេញទានបារមី អស់១ឆ្នាំ... ២ឆ្នាំ... ១០ឆ្នាំ... ២០ឆ្នាំ... ៥០ឆ្នាំ... ១រយឆ្នាំ... ១ពាន់ឆ្នាំ... ១សែនឆ្នាំ... អស់១សែនកោដិឆ្នាំ ហើយបានជាព្រះពុទ្ធទេ; ព្រះអង្គមិនអាចបំពេញទានបារមី អស់១កប្ប... ២កប្ប... ១០កប្ប... ២០កប្ប... ៥០កប្ប... ១រយកប្ប... ១ពាន់កប្ប... ១សែនកប្ប... អស់១សែនកោដិកប្ប ហើយបានជាព្រះពុទ្ធទេ; ព្រះអង្គមិនអាចបំពេញទានបារមី អស់១អសង្ខេយ្យកប្ប... អស់២អសង្ខេយ្យកប្ប... អស់៣អសង្ខេយ្យកប្ប ហើយបានជាព្រះពុទ្ធទេ។ សូម្បីក្នុងសីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី និងឧបេក្ខាបារមី ក៏ន័យនេះដូចគ្នាដែរ។ ប៉ុន្តែចុងបំផុត ព្រះអង្គបំពេញបារមី១០ អស់៤អសង្ខេយ្យ ១សែនកប្បហើយ ទើបអាចបានជាព្រះពុទ្ធ។ ព្រោះហេតុដូចបានពោលមកនេះ ព្រះអង្គទើបឈ្មោះថា **ទុល្លភោ** រកបាន

ដោយកម្រ បានដោយលំបាក។

អដ្ឋកថាសូត្រទី២ ចប់៕

## អដ្ឋកថាសូត្រទី៣

ក្នុងសូត្រទី៣ បទថា **អច្ឆរិយមនុស្សោ** គឺមនុស្សដ៏អស្ចារ្យ (អ្នកដែលគេស្ងើចគួរទះដៃ)។ សេចក្តីថា មិនមានជានិច្ច ដូចមនុស្សខ្វាក់ឡើងលើភ្នំ។ សទ្ទន័យ មានប៉ុណ្ណេះសិន។ ឯអដ្ឋកថាន័យនេះវិញ មានសេចក្តីថា ដែលឈ្មោះថា អច្ឆរិយៈ ព្រោះគួរដល់ការទះដៃ។ អធិប្បាយថា គួរទះដៃសំឡឹងមើល។ មួយទៀត ដែលឈ្មោះថា អច្ឆរិយមនុស្ស ព្រោះទ្រង់ប្រកបដោយធម៌ដែលអស្ចារ្យ ចម្លែក ដ៏ច្រើន មានយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ៤យ៉ាង ដែលអស្ចារ្យ ចម្លែក រមែងកើតប្រាកដ ព្រោះការកើតប្រាកដនៃព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ៤យ៉ាង គឺអ្វីខ្លះ? គឺម្នាលភិក្ខុទាំងឡាយ ពោធិសត្វច្យុតចាកពួកទេវតាជាន់តុសិត មានស្មារតី ដឹងខ្លួន ចុះកាន់ផ្ទៃនៃព្រះមាតា ក្នុងកាលណា, ក្នុងកាលនោះ ពន្លឺដ៏រុងរឿងក្រៃលែង ប្រមាណមិនបាន កន្លងបង់នូវទេវានុភាព របស់ទេវតាទាំងឡាយ ក៏កើត

ប្រាកដក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ទាំងសមណៈព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស។ ចំណែកលោក-ន្តរិកនរក ទាំងប៉ុន្មាន ដែលទីចំហ មិនមានអ្វីទ្រខាងក្រោម ជាទីងងឹត មានតែអ័ព្ទងងឹតសូន្យសុង, ពន្លឺនៃព្រះចន្ទនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ រមែងផ្សាយទៅមិនដល់លោកន្តរិកនរកណា, ពន្លឺដ៏រុងរឿងក្រៃលែង ប្រមាណមិនបាន កន្លងបង់នូវទេវា-នុភាព របស់ទេវតាទាំងឡាយ ក៏កើតប្រាកដក្នុងលោកន្តរិក-នរកនោះឯង។ ពួកសត្វណា ដែលកើតក្នុងទីនោះ, ពួកសត្វនោះ ក៏ស្គាល់គ្នានិងគ្នា ដោយសារពន្លឺនោះថា ‘ឱហ្ន៎! ពួកសត្វដទៃ មកកើតក្នុងទីនេះដែរតើ’។ ម្នាលភិក្ខុទាំងឡាយនេះ ជាធម៌ ដែលអស្ចារ្យ ចម្លែក ទី១ រមែងកើតប្រាកដព្រោះការកើតប្រាកដនៃព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ពោធិសត្វប្រសូតចាកផ្ទៃនៃមាតា មានស្មារតី ដឹងខ្លួន ចុះកាន់ផ្ទៃនៃព្រះមាតា ក្នុងកាលណា, ក្នុងកាលនោះ ពន្លឺដ៏រុងរឿងក្រៃលែង ប្រមាណមិនបាន កន្លងបង់នូវទេវានុភាព របស់ទេវតាទាំងឡាយ ក៏

កើតប្រាកដក្នុងមនុស្សលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ទាំងសមណៈព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស។ ចំណែកលោក-ន្តរិកនរក ទាំងប៉ុន្មាន ដែលទីចំហ មិនមានអ្វីទ្រខាងក្រោម ជាទីងងឹត មានតែអ័ព្ទងងឹតសូន្យសុង, ពន្លឺនៃព្រះចន្ទនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ រមែងផ្សាយទៅមិនដល់លោកន្តរិកនរកណា, ពន្លឺដ៏រុងរឿងក្រៃលែង ប្រមាណមិនបាន កន្លងបង់នូវទេវា-នុភាព របស់ទេវតាទាំងឡាយ ក៏កើតប្រាកដក្នុងលោកន្តរិក-នរកនោះឯង។ ពួកសត្វណា ដែលកើតក្នុងទីនោះ, ពួកសត្វនោះ ក៏ស្គាល់គ្នានិងគ្នា ដោយសារពន្លឺនោះថា ‵ឱហ្ន៎! ពួកសត្វដទៃ មកកើតក្នុងទីនេះដែរតើ′។ ម្នាលភិក្ខុទាំងឡាយ នេះ ជាធម៌ ដែលអស្ចារ្យ ចម្លែក ទី២ រមែងកើតប្រាកដព្រោះការកើតប្រាកដនៃព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតបានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលណា, ក្នុងកាលនោះ ពន្លឺដ៏រុងរឿងក្រៃលែង ប្រមាណមិនបាន កន្លងបង់នូវទេវានុ-ភាព របស់ទេវតាទាំងឡាយ ក៏កើតប្រាកដក្នុងមនុស្សលោក

ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្ស ដ៏សេស។ ចំណែកលោកន្តរិកនរក ទាំងប៉ុន្មាន ដែលទីចំហ មិនមានអ្វីទ្រខាងក្រោម ជាទីងងឹត មានតែអ័ព្ទងងឹតសូន្យ សុង, ពន្លឺនៃព្រះចន្ទនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិ ច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ រមែងផ្សាយ ទៅមិនដល់លោកន្តរិកនរកណា, ពន្លឺដ៏រុងរឿងក្រៃលែង ប្រមាណមិនបាន កន្លងបង់នូវទេវានុភាព របស់ទេវតា ទាំងឡាយ ក៏កើតប្រាកដក្នុងលោកន្តរិកនរកនោះឯង។ ពួក សត្វណា ដែលកើតក្នុងទីនោះ, ពួកសត្វនោះ ក៏ស្គាល់គ្នា និងគ្នា ដោយសារពន្លឺនោះថា ‹ឱហ្ន៎! ពួកសត្វដទៃ មកកើត ក្នុងទីនេះដែរតើ›។ ម្នាលភិក្ខុទាំងឡាយ នេះ ជាធម៌ ដែល អស្ចារ្យ ចម្លែក ទី៣ រមែងកើតប្រាកដ ព្រោះការកើតប្រាកដ នៃព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតញុំាងធម្មចក្រ ដ៏ប្រសើរឲ្យប្រព្រឹត្តទៅ ក្នុងកាលណា, ក្នុងកាលនោះ ពន្លឺ ដ៏រុងរឿងក្រៃលែង ប្រមាណមិនបាន កន្លងបង់នូវទេវានុភាព របស់ទេវតាទាំងឡាយ ក៏កើតប្រាកដក្នុងមនុស្សលោក ព្រម

ទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស។ ចំណែកលោកន្តរិកនរក ទាំងប៉ុន្មាន ដែលទីចំហមិនមានអ្វីទ្រខាងក្រោម ជាទីងងឹត មានតែអ័ព្ទងងឹតសូន្យសុង, ពន្លឺនៃព្រះចន្ទនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ រមែងផ្សាយទៅមិនដល់លោកន្តរិកនរកណា, ពន្លឺដ៏រុងរឿងក្រៃលែងប្រមាណមិនបាន កន្លងបង់នូវទេវានុភាព របស់ទេវតាទាំងឡាយ ក៏កើតប្រាកដក្នុងលោកន្តរិកនរកនោះឯង។ ពួកសត្វណា ដែលកើតក្នុងទីនោះ, ពួកសត្វនោះ ក៏ស្គាល់គ្នានិងគ្នា ដោយសារពន្លឺនោះថា ‛ឱហ្ន៎! ពួកសត្វដទៃ មកកើតក្នុងទីនេះដែរតើ‛។ ម្នាលភិក្ខុទាំងឡាយ នេះ ជាធម៌ ដែលអស្ចារ្យ ចម្លែក ទី៤ រមែងកើតប្រាកដ ព្រោះការកើតប្រាកដនៃព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ ម្នាលភិក្ខុទាំងឡាយធម៌ទាំងឡាយ៤យ៉ាងនេះឯង ដែលអស្ចារ្យ ចម្លែក រមែងកើតប្រាកដ ព្រោះការកើតប្រាកដ នៃព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ[13]”។

---

13 អំ.ចតុក្ក.បឋមតថាគតអច្ឆរិយសូត្រ។

(ព្រះអង្គទ្រង់កើតឡើង) ជាមនុស្សដ៏អស្ចារ្យ ក៏ព្រោះព្រះអង្គជាមនុស្សអាចិណ្ណៈ (ធ្លាប់សន្សំមកហើយ) ក៏មាន។ ពិតមែន ការដែលព្រះអង្គទ្រង់ប្រជុំធម៌ ៨ប្រការ ដែលធ្វើឲ្យអភិនីហារដល់ព្រម ហើយទ្រង់ចងព្រះទ័យគង់ នាមហាពោធិមណ្ឌដ្ឋាន ចំពោះព្រះភ័ក្ត្ររបស់ព្រះពុទ្ធមួយអង្គ ដែលអ្នកណាដទៃ មិនសន្សំហើយ, ព្រះសព្វញ្ញុពោធិសត្វប៉ុណ្ណោះ សន្សំមកហើយ។ ដូចគ្នានេះដែរ ការដែលព្រះអង្គទ្រង់បានទទួលព្យាករណ៍ ក្នុងសម្នាក់នៃព្រះពុទ្ធទាំងឡាយ ទ្រង់ជាអ្នកមិនត្រឡប់ក្រោយ អធិដ្ឋាននូវសេចក្តីព្យាយាមដ៏មាំ ហើយបំពេញពុទ្ធការកធម៌ ដែលអ្នកណាដទៃ មិនសន្សំហើយ, ព្រះសព្វញ្ញុពោធិសត្វប៉ុណ្ណោះ សន្សំមកហើយ។ ដូចគ្នានេះទៀត ការដែលព្រះអង្គទ្រង់ធ្វើបារមីទាំងឡាយឲ្យកាន់យកបន្ទប់(គឺឲ្យចាស់ក្លា) ឋិតនៅក្នុងអត្តភាពដូចអត្តភាពព្រះវេស្សន្តរ ហើយឲ្យសត្តសតកមហាទាន (ការប្រទានដ៏ធំនូវវត្ថុ១មុខៗ ៧០០ៗ) យ៉ាងនេះគឺ ដំរី ៧០០ក្បាល សេះ ៧០០ក្បាល រថ ៧០០គ្រឿង ស្ត្រី ៧០០នាក់ មេគោទឹកដោះ ៧០០ក្បាល ទាសៈ ៧០០នាក់ ទាសី ៧០០នាក់ ដែលប្រដាប់ដោយគ្រឿងអលង្ការគ្រប់ប្រភេទ, ប្រទានបុត្ត

ដូចជាលីកុមារ ប្រទានធីតាដូចកណ្ហាជិនា និងប្រទានភរិយា ដូចព្រះនាងមទ្រី ឲ្យទុកក្នុងប្រធាននៃទាន ឋិតអស់អាយុកប្ប ក្នុងអត្តភាពទី២ ទ្រង់ចាប់បដិសន្ធិ ក្នុងពិភពតុសិត ដែលអ្នកណាដទៃ មិនសន្សំហើយ, ព្រះសព្វញ្ញុពោធិសត្វប៉ុណ្ណោះ សន្សំមកហើយ។ ទ្រង់ឋិតនៅអស់អាយុកប្ប ក្នុងតុសិតបុរី ទទួលការអារាធនារបស់ពួកទេវតា ហើយសំឡឹងមើលមហាវិលោកនៈ៥ មានស្មារតី មានសេចក្តីដឹងខ្លួន ច្យុតចាកតុសិតបុរី ចាប់បដិសន្ធិក្នុងត្រកូលអ្នកមានទ្រព្យដ៏ច្រើន ដែលអ្នកណាដទៃ មិនសន្សំហើយ, ព្រះសព្វញ្ញុពោធិសត្វប៉ុណ្ណោះ សន្សំមកហើយ។ មួយទៀត មួយម៉ឺនលោកធាតុកម្រើកញាប់ញ័រ ក្នុងថ្ងៃចាប់បដិសន្ធិផង កាលដែលព្រះអង្គទ្រង់មានស្មារតី មានសេចក្តីដឹងខ្លួន គង់នៅក្នុងផ្ទៃនៃព្រះមាតាផង កាលដែលព្រះអង្គទ្រង់មានស្មារតី មានសេចក្តីដឹងខ្លួន មួយម៉ឺនលោកធាតុកម្រើកញាប់ញ័រ ក្នុងថ្ងៃប្រសូតចាកផ្ទៃផង កាលទ្រង់ប្រសូតហើយភ្លាម ទ្រង់យាងទៅបាន ៧ជំហានផង ការបាំងដោយស្វេតច្ឆ័ត្រទិព្វផង ការបក់ដោយផ្លិតវាលវីជនីទិព្វផង ការទតមើលក្នុងទិសទាំងអស់ ដូចការរកមើលរបស់សីហៈ មិនឃើញនូវសត្វណាមួយ ដែលដូច

ដោយអត្តភាពនឹងព្រះអង្គ ហើយបន្លឺសីហទាន យ៉ាងនេះថា "អគ្គោហមស្មិ លោកស្ស, ជេដ្ឋោហមស្មិ លោកស្ស, សេដ្ឋោហមស្មិ លោកស្ស, អយមន្តិមា ជាតិ, នត្ថិ ទានិ បុនព្ភវោ" ផង នាកាលញាណចាស់ក្លាហើយ ទ្រង់លះបង់នូវមហាសម្បត្តិ យាងទៅសាងផ្នួសផង កាលទ្រង់គង់ពែនភ្នែននាមហាពោធិមណ្ឌដ្ឋាន ទ្រង់ឈ្នះមារជាដើម មានការរលឹកបុព្វេនិវាស (ក្នុងបឋមយាម) ជម្រះទិព្វចក្ខុ (ក្នុងមជ្ឈិមយាម) ត្រាស់ដឹងគំនរគុណសព្វញ្ញុតញ្ញាណ (ក្នុងបច្ឆិមយាម) មួយម៉ឺនលោកធាតុកម្រើកញាប់ញ័រផង ការប្រកាសធម្មចក្រដ៏ប្រសើរ ដែលមានបរិវដ្ដៈ៣ ក្នុងបឋមធម្មទេសនាផង ហេតុដ៏អស្ចារ្យទាំងអស់ដូចបានពោលមកយ៉ាងនេះជាដើម ដែលអ្នកណាដទៃ មិនសន្សំហើយ, ព្រះសព្វញ្ញុពោធិសត្វប៉ុណ្ណោះ សន្សំមកហើយ។ ព្រះអង្គទ្រង់កើតឡើងជាមនុស្សដ៏អស្ចារ្យ ក៏ព្រោះព្រះអង្គជាមនុស្សអាចិណ្ណៈ (ធ្លាប់សន្សំមកហើយ) យ៉ាងនេះឯង។

អដ្ឋកថាសូត្រទី៣ ចប់។

## អដ្ឋកថាសូត្រទី៤

ក្នុងសូត្រទី៤ បទថា **កាលកិរិយា** សេចក្ដីថា កិរិយាដែលប្រាកដក្នុងកាលមួយ ព្រោះហេតុនោះ ទើបឈ្មោះថា កាលកិរិយា។ អធិប្បាយថា ព្រះតថាគតទ្រង់ឋិតនៅអស់ ៤៥វស្សា ប្រកាសបិដក៣ និកាយ៥ សត្ថុសាសន៍មានអង្គ ៩ ព្រះធម៌ ៨ម៉ឺន ៤ពាន់ធម្មក្ខន្ធ ទ្រង់ធ្វើមហាជន ឲ្យបង្អោនទៅក្នុងព្រះនិព្វាន ឲ្យឈមមុខទៅរកព្រះនិព្វាន ទ្រង់ផ្ទំត្រង់ចន្លោះដើមសាលព្រឹក្សទាំងគូ ទ្រង់ហៅភិក្ខុសង្ឃ ប្រទានឱវាទដោយអប្បមាទធម៌ មានស្មារតី មានសេចក្ដីដឹងខ្លួន បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ។ កាលកិរិយារបស់ព្រះអង្គនេះ មានប្រាកដមករហូតដល់សព្វថ្ងៃ ព្រោះហេតុនោះ ទើបឈ្មោះថា**កាលកិរិយា**។ ព្រោះកិរិយាដែលប្រាកដក្នុងកាលមួយ។ ពីរបទថា **អនុតប្បា ហោតិ** បានដល់ជាការធ្វើសេចក្ដីសោយស្ដាយតាមក្រោយ។ ក្នុងសេចក្ដីនោះ កាលកិរិយា របស់ស្ដេចចក្កពត្តិ ជាការធ្វើសេចក្ដីសោយស្ដាយតាមក្រោយ នៃទេវតានិងមនុស្សទាំងឡាយ ក្នុងចក្កវាឡមួយ។ កាលកិរិយា របស់ព្រះពុទ្ធ ជាការធ្វើសេចក្ដីសោយស្ដាយតាមក្រោយ នៃទេវតានិងមនុស្សទាំងឡាយ

ក្នុងមួយម៉ឺនចក្កវាឡ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ``**ជាទីសោយស្ពាយនៃជនច្រើន**´´។

អដ្ឋកថាសូត្រទី៤ ចប់។

## អដ្ឋកថាសូត្រទី៥

ក្នុងសូត្រទី៥ បទថា **អទុតិយោ** សេចក្ដីថា ឈ្មោះថា អទុតិយោ ព្រោះមិនមានព្រះពុទ្ធជាគម្រប់២ ។ ពិតហើយ ពុទ្ធបុគ្គល មាន៤ប្រភេទ គឺសុតពុទ្ធ១ ចតុសច្ចពុទ្ធ១ បច្ចេកពុទ្ធ១ សព្វញ្ញុពុទ្ធ១ ។ បណ្ដាពុទ្ធបុគ្គល៤ប្រភេទនោះ ភិក្ខុជាពហុស្សូត ឈ្មោះថា**សុតពុទ្ធ**។ ព្រះខីណាសព្រ ឈ្មោះថា**ចតុសច្ចពុទ្ធ**។ បុគ្គលបំពេញបារមីអស់២អសង្ខេយ្យ ១សែនកប្ប ហើយបានចាក់ធ្លុះបច្ចេកពោធិញាណ ឈ្មោះថា **បច្ចេកពុទ្ធ**។ បុគ្គលបំពេញបារមី អស់៤អសង្ខេយ្យ ១សែនកប្ប ឬអស់៨អសង្ខេយ្យ ១សែនកប្ប ឬក៏អស់១៦ អសង្ខេយ្យ ១សែនកប្ប ហើយបានញាំញីនូវក្បាលមារទាំង ៣ រួចចាក់ធ្លុះសព្វញ្ញុតញ្ញាណ ឈ្មោះថា**សព្វញ្ញុពុទ្ធោ**។ ក្នុងពុទ្ធបុគ្គលទាំង៤នេះ ព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះ ឈ្មោះថា **មិនមានអ្នកជាគម្រប់ពីរ**។ ឈ្មោះថាព្រះសព្វញ្ញុពុទ្ធអង្គដទៃ មិន

កើតឡើងជាមួយនឹងព្រះអង្គឡើយ។

បទថា **អសហាយោ** សេចក្តីថា ឈ្មោះថាអសហាយោ ព្រោះមិនមានសំឡាញ់អ្នកដូចដោយអត្តភាព ឬដោយធម៌ ដែលទ្រង់ចាក់ធ្លុះ។ ក៏សេខៈនិងអសេខៈ ឈ្មោះថាជាសម្លាញ់របស់ព្រះពុទ្ធទាំងឡាយ ដោយបរិយាយនេះថា "ព្រះភគវាអង្គនោះ ទ្រង់ជាសម្លាញ់ដែលពួកសេខបដិបទា (និងអសេខបដិបទា)បានហើយ។

បទថា **អប្បដិមោ** សេចក្តីថា អត្តភាព ឈ្មោះថាបដិមា, ឈ្មោះថាអប្បដិមា ព្រោះមិនមានបដិមាដទៃ ដូចអត្តភាពរបស់ព្រះអង្គ។ មួយទៀត ពួកមនុស្សចេះធ្វើបដិមាទាំងឡាយណា ដែលសម្រេចដោយមាសនិងប្រាក់ជាដើម, ក្នុងបដិមាទាំងនោះ ឈ្មោះថាអ្នកអាចដើម្បីធ្វើឱកាស សូម្បីមានប្រមាណប៉ុនរោមទ្រាយ ឲ្យដូចអត្តភាពនៃព្រះតថាគតរមែងមិនមាន ព្រោះហេតុនោះ ទើបទ្រង់ឈ្មោះថាអប្បដិមោ (មិនមានអ្នកមានអត្តភាពដូច) សូម្បីដោយប្រការទាំងពួង។

បទថា **អប្បដិសមោ** សេចក្តីថា អត្តភាព ឈ្មោះថាអប្បដិសមោ ព្រោះអ្នកណាមួយ ឈ្មោះថាដូចដោយអត្តភាពរបស់ព្រះអង្គ រមែងមិនមាន។

បទថា **អប្បដិភាគោ** សេចក្តីថា ឈ្មោះថាអប្បដិភាគោ (អ្នកបែកចែកចំណែកធម៌ មិនមានអ្នកចាប់កំហុសបាន) ព្រោះធម៌ទាំងឡាយណា ដែលព្រះតថាគតទ្រង់សម្តែងហើយ ដោយន័យជាដើមថា "សតិបដ្ឋានមាន៤" ឈ្មោះថាអ្នកដែលអាចដើម្បីធ្វើការបែងចែក ក្នុងធម៌ទាំងនោះដោយន័យជាដើមថា "សតិបដ្ឋាន មិនមែនមាន៤ ទេ, តែមាន៣ ឬ ៥" រមែងមិនមាន។

បទថា **អប្បដិបុគ្គលោ** សេចក្តីថា ឈ្មោះថាអប្បដិបុគ្គលោ (មិនមានបុគ្គលប្រៀបផ្ទឹមបាន) ព្រោះបុគ្គលដទៃណាមួយដែលអាចដើម្បីធ្វើការបដិញ្ញាយ៉ាងនេះថា "យើងជាព្រះពុទ្ធ" ដូច្នេះ រមែងមិនមាន។

បទថា **អសមោ** សេចក្តីថា ឈ្មោះថាមិនមានបុគ្គលស្មើ ព្រោះមិនស្មើដោយសព្វសត្វទាំងអស់ ព្រោះព្រះអង្គមិនមានបុគ្គលប្រៀបផ្ទឹមបាន។

បទថា **អសមសមោ** សេចក្តីថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយទាំងអតីតៈទាំងអនាគត លោកហៅថា**អសមៈ** (បុគ្គលដែលឥតគេស្មើ), ព្រះអង្គស្មើតែនឹងបុគ្គលដែលឥតគេស្មើទាំងឡាយនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា

**អសមសមោ** (ស្មើតែនឹងបុគ្គលដែលឥតគេស្មើ)។

ពីរបទថា **ទ្វិបទានំ អគ្គោ** សេចក្ដីថា ព្រះសម្មាសម្ពុទ្ធទ្រង់ប្រសើរជាងពួកសត្វ ដែលឥតជើង មានជើង២ មានជើង៤ មានជើងច្រើន មានរូប មិនមានរូប មានសញ្ញា មិនមានសញ្ញា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន។ សំណួរថា ចុះព្រោះហេតុអ្វី ទើបក្នុងទីនេះ ពោលថាព្រះអង្គប្រសើរជាងពួកសត្វមានជើងពីរ? ចម្លើយថា ដោយអំណាចនៃសត្វមានជើងពីរប្រសើរជាងពួកសត្វទាំងនោះ។ ពិតមែនធម្មតាអ្នកប្រសើរបំផុតក្នុងលោកនេះ កាលកើតឡើង រមែងមិនកើតឡើង ក្នុងពួកសត្វដែលឥតជើង មានជើង៤ មានជើងច្រើនទេ, គឺកើតឡើងក្នុងពួកសត្វមានជើងពីរប៉ុណ្ណោះ។ ក្នុងពួកសត្វមានជើងពីរ ដូចម្ដេច? គឺក្នុងពួកមនុស្ស និងពួកទេវតា។ អ្នកប្រសើរបំផុត កាលកើតឡើងក្នុងពួកមនុស្ស រមែងកើតឡើងជាព្រះពុទ្ធ អាចដើម្បីធ្វើតិសហស្សិមហាសហស្សិលោកធាតុ (បីពាន់លោកធាតុ និងច្រើនពាន់លោកធាតុ) ឲ្យប្រព្រឹត្តទៅ ក្នុងអំណាចបាន។ កាលកើតឡើងក្នុងពួកទេវតា រមែងកើតឡើងជាមហាព្រហ្ម អ្នកមានអាចធ្វើម៉ឺនលោកធាតុ ឲ្យប្រព្រឹត្តទៅក្នុងអំណាចបាន។

មហាព្រហ្មនោះ រមែងសម្រេចជាកប្បិយការកៈ ឬអារាមិកៈ របស់ព្រះអង្គបាន, ហេតុនោះ ទើបលោកពោលថា ព្រះអង្គទ្រង់ប្រសើរបំផុតជាងពួកសត្វមានជើងពីរ ដោយអំណាចទ្រង់ប្រសើរបំផុតជាងមនុស្សនិងទេវតាទាំងនោះ។

អដ្ឋកថាសូត្រទី៥ ចប់។

## អដ្ឋកថាសូត្រទី៦-១៧

ក្នុងសូត្រទី៦ ជាដើម ច្រើនបទថា **ឯកបុគ្គលស្ស ភិក្ខវេ បាតុភាវា មហតោ ចក្ខុស្ស បាតុភាវោ ហោតិ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃចក្ខុដ៏ប្រសើរ រមែងមាន ព្រោះការកើតប្រាកដនៃបុគ្គលឯក គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ។ កាលបើបុគ្គលនោះ កើតប្រាកដហើយ ចក្ខុនោះក៏ប្រាកដដែរ, វៀរចាកការកើតប្រាកដនៃបុគ្គលនោះ ចក្ខុក៏រមែងមិនកើតប្រាកដ។ ឧប្បត្តិ (ការកើតឡើង) និប្ផត្តិ (ការសម្រេចបាន) ឈ្មោះថា **បាតុភាវោ**។ ចក្ខុ តើដូចម្ដេច? គឺបញ្ញាចក្ខុ។ បញ្ញាចក្ខុ តើដូចម្ដេច? ដូចវិបស្សនាបញ្ញាព្រះសារីបុត្តត្ថេរ, ដូចសមាធិបញ្ញាព្រះមហាមោគ្គល្លានត្ថេរ។ សូម្បីក្នុងស័ព្ទថា **អាលោកៈ** (**ពន្លឺ**)ជាដើម ក៏ន័យដូចគ្នា។

ពិតហើយ អាលោកៈ លោកបំណាងក្នុងទីនេះ ដូចបញ្ញាអា-លោកៈ របស់អគ្គសាវកទាំងពីរ, ឱភាស លោកបំណងក្នុងទីនេះ ដូចបញ្ញាឱភាស របស់អគ្គសាវកទាំងពីរដែរ។ សូម្បីបទទាំងបីនេះគឺ "មហតោ ចក្ខុស្ស, មហតោ អាលោកស្ស, មហតោ ឱភាសស្ស" គប្បីជ្រាបថា ទ្រង់ត្រាស់លាយគ្នាទាំងលោកិយៈទាំងលោកុត្តរៈ។

ពីរបទថា **ឆន្នំ អនុត្តរិយានំ** សេចក្ដីថា ធម៌ដ៏ខ្ពង់ខ្ពស់៦យ៉ាង ដែលមិនមានធម៌ដទៃក្រៃលែងជាង។ ក្នុងពាក្យនោះមានអធិប្បាយថា អនុត្តរិយៈ៦យ៉ាងនេះ គឺទស្សនានុត្តរិយៈ (ការឃើញដ៏ប្រសើរបំផុត)១ សវនានុត្តរិយៈ (ការស្ដាប់ដ៏ប្រសើរបំផុត)១ លាភានុត្តរិយៈ (ការបានដ៏ប្រសើរបំផុត)១ សិក្ខានុត្តរិយៈ (ការសិក្សាដ៏ប្រសើរបំផុត)១ បារិចរិយានុត្ត-រិយៈ (ការបម្រើដ៏ប្រសើរបំផុត)១ អនុស្សតានុត្តរិយៈ (ការរលឹកដ៏ប្រសើរបំផុត)។ អធិប្បាយថា ព្រះអានន្ទត្ថេរបានដើម្បីឃើញព្រះតថាគត ដោយចក្ខុវិញ្ញាណទាំងល្ងាចទាំងព្រឹក, នេះ ឈ្មោះថា**ទស្សនានុត្តរិយៈ**។ សូម្បីអ្នកដទៃទៀតជាសោតាបន្នក្ដី សកទាគាមីក្ដី អនាគាមីក្ដី ក៏រមែងបានដើម្បីឃើញព្រះតថាគត ដូចព្រះអានន្ទត្ថេរ, នេះ ក៏ឈ្មោះថា**ទស្ស**-

**នានុត្តរិយៈ**។ អ្នកដទៃជាកល្យាណបុថុជ្ជន បានដើម្បីឃើញព្រះទសពល ដូចព្រះអានន្ទត្ថេរ ហើយធ្វើការឃើញនោះឲ្យចម្រើន រួចសម្រេចនូវសោតាបត្តិមគ្គ។ នេះ ក៏ឈ្មោះថាទស្សនៈដែរ, តែទស្សនៈជាមូល ឈ្មោះថាទស្សនានុត្តរិយៈ។

ព្រះអានន្ទត្ថេរហ្នឹងឯង បានដើម្បីស្តាប់ព្រះពុទ្ធដីកានៃព្រះទសពលរឿយៗ ដោយសោតវិញ្ញាណ, នេះ ឈ្មោះថា **សវនានុត្តរិយៈ**។ សូម្បីអ្នកដទៃទៀត ជាសោតាបន្នក្តី សកទាគាមីក្តី អនាគាមីក្តី ក៏រមែងបានដើម្បីស្តាប់ព្រះពុទ្ធដីកាព្រះតថាគត ដូចព្រះអានន្ទត្ថេរ, នេះ ក៏ឈ្មោះថា**សវនា-នុត្តរិយៈ**។ អ្នកដទៃជាកល្យាណបុថុជ្ជន បានដើម្បីស្តាប់ព្រះទសពល ដូចព្រះអានន្ទត្ថេរ ហើយធ្វើការស្តាប់នោះឲ្យចម្រើន រួចសម្រេចនូវសោតាបត្តិមគ្គ។ នេះ ក៏ឈ្មោះថាសវនៈដែរ, តែសវនៈជាមូល ឈ្មោះថាសវនានុត្តរិយៈ។

ព្រះអានន្ទត្ថេរហ្នឹងឯង បានចំពោះនូវសទ្ធា ក្នុងព្រះទសពល, នេះ ឈ្មោះថា**លាភានុត្តរិយៈ**។ សូម្បីពួកអ្នកដទៃមានសោតាបន្នជាដើម ក៏រមែងបានចំពោះនូវសទ្ធាក្នុងព្រះទសពល ដូចព្រះអានន្ទត្ថេរ, នេះ ក៏ឈ្មោះថា**លាភានុត្ត-រិយៈ**។ អ្នកដទៃជាកល្យាណបុថុជ្ជន បានដើម្បីស្តាប់ព្រះ

ទសពល ដូចព្រះអានន្ទត្ថេរ ហើយធ្វើការស្តាប់នោះឲ្យចម្រើន រួចសម្រេចនូវសោតាបត្តិមគ្គ។ នេះ ក៏ឈ្មោះថាលាភដែរ, តែលាភជាមូល ឈ្មោះថាលាភានុត្តរិយៈ។

ព្រះអានន្ទត្ថេរហ្នឹងឯង សិក្សាត្រៃសិក្ខា ក្នុងសាសនាព្រះទសពល, នេះ ឈ្មោះថា**សិក្ខានុត្តរិយៈ**។ សូម្បីពួកអ្នកដទៃមានសោតាបន្នជាដើម ក៏រមែងសិក្សាត្រៃសិក្ខា ក្នុងសាសនាព្រះទសពល ដូចព្រះអានន្ទត្ថេរ, នេះ ក៏ឈ្មោះថា**សិក្ខានុត្តរិយៈ**។ អ្នកដទៃជាកល្យាណបុថុជ្ជន សិក្សាត្រៃសិក្ខា ក្នុងសាសនាព្រះទសពល ដូចព្រះអានន្ទត្ថេរ ហើយធ្វើការសិក្សាត្រៃសិក្ខានោះ ឲ្យចម្រើន រួចសម្រេចនូវសោតា-បត្តិមគ្គ។ នេះ ក៏ឈ្មោះថាសិក្ខាដែរ, តែសិក្ខាជាមូល ឈ្មោះថាសិក្ខានុត្តរិយៈ។

ព្រះអានន្ទត្ថេរហ្នឹងឯង បម្រើព្រះទសពលរឿយៗ, នេះ ឈ្មោះថា**បារិចរិយានុត្តរិយៈ**។ សូម្បីពួកអ្នកដទៃ មានសោតាបន្នជាដើម ក៏រមែងបម្រើព្រះទសពលរឿយៗ ដូចព្រះអានន្ទត្ថេរ, នេះ ក៏ឈ្មោះថា**បារិចរិយានុត្តរិយៈ**។ អ្នកដទៃជាកល្យាណបុថុជ្ជន បម្រើព្រះទសពលរឿយៗ ដូចព្រះអានន្ទត្ថេរ ហើយធ្វើការបម្រើនោះ ឲ្យចម្រើន រួចសម្រេចនូវ

សោតាបត្តិមគ្គ។ នេះ ក៏ឈ្មោះថាបារិចរិយៈដែរ, តែបារិចរិយៈជាមូល ឈ្មោះថាបារិចរិយានុត្តរិយៈ។

ព្រះអានន្ទត្ថេរហ្នឹងឯង តែងរលឹកនូវគុណទាំងឡាយទាំងលោកិយៈទាំងលោកុត្តរៈ នៃព្រះទសពល, នេះ ឈ្មោះថា**អនុស្សតានុត្តរិយៈ**។ សូម្បីពួកអ្នកដទៃ មានសោតាបន្នជាដើម ក៏តែងរលឹកនូវគុណទាំងឡាយ ទាំងលោកិយៈទាំងលោកុត្តរៈ នៃព្រះទសពល ដូចព្រះអានន្ទត្ថេរ, នេះក៏ឈ្មោះថា**អនុស្សតានុត្តរិយៈ**។ អ្នកដទៃជាកល្យាណបុថុជ្ជន តែងរលឹកនូវគុណទាំងឡាយ ទាំងលោកិយៈទាំងលោកុត្តរៈ នៃព្រះទសពល ដូចព្រះអានន្ទត្ថេរ ហើយធ្វើការរលឹកនោះឲ្យចម្រើន រួចសម្រេចនូវសោតាបត្តិមគ្គ។ នេះ ក៏ឈ្មោះថាអនុស្សតិដែរ, តែអនុស្សតិជាមូល ឈ្មោះថាអនុស្សតា-នុត្តរិយៈ។

ការកើតប្រាកដនៃអនុត្តរិយៈ៦នេះ (រមែងមានព្រោះការកើតប្រាកដនៃបុគ្គលឯកគឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ)។ បណ្ឌិតគប្បីជ្រាបអនុត្តរិយៈទាំង៦នេះ គឺព្រះអង្គទ្រង់ត្រាស់លាយគ្នាទាំងលោកិយៈទាំងលោកុត្តរៈ។

ច្រើនបទថា **ចតុន្នំ បដិសម្ភិទានំ សច្ឆិកិរិយា ហោតិ** សេចក្តីថា បដិសម្ភិទាមាន៤ គឺអត្ថប្បដិសម្ភិទា១ ធម្មប្បដិ-សម្ភិទា១ និរុត្តិប្បដិសម្ភិទា១ បដិភាណប្បដិសម្ភិទា១ ។ ក្នុងបដិសម្ភិទាទាំង៤នោះ ញាណ (សេចក្តីដឹង) ក្នុងអត្ថទាំងឡាយ ឈ្មោះថា **អត្ថប្បដិសម្ភិទា**, ញាណក្នុងធម៌ទាំងឡាយឈ្មោះថា **ធម្មប្បដិសម្ភិទា**, ញាណក្នុងការពោលភាសាអត្ថនិងធម៌ ឈ្មោះថា**និរុត្តិប្បដិសម្ភិទា**, ញាណក្នុងញាណទាំងឡាយ ឈ្មោះថា**បដិភាណប្បដិសម្ភិទា**។ សេចក្តីសង្ខេប ក្នុងទីនេះ មានត្រឹមតែប៉ុណ្ណេះ, ចំណែកឯសេចក្តីពិស្តារ នៃបដិសម្ភិទាទាំងនោះមកហើយក្នុងអភិធម្ម ថា៖

## បដិសម្ភិទាវិភង្គ

(១) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា។ សេចក្តីដឹងក្នុងអត្ថ ឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្តីដឹងក្នុងធម៌ ឈ្មោះថា ធម្មប្បដិសម្ភិទា, សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថានិរុត្តិប្បដិសម្ភិទា, សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថាបដិភាណ-ប្បដិសម្ភិទា ។ នេះ ជាសង្ខេបវារៈ។

(២) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា។ សេចក្ដីដឹងក្នុងទុក្ខ ឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្ដីដឹងក្នុងការកើតឡើងនៃទុក្ខ ឈ្មោះថាធម្មប្បដិសម្ភិទា, សេចក្ដីដឹងក្នុងការរលត់ទុក្ខ ឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្ដីដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថាធម្មប្បដិ-សម្ភិទា, សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថានិរុត្តិប្បដិសម្ភិទា, សេចក្ដីដឹងក្នុងញាណទាំងឡាយ ឈ្មោះថាបដិភាណប្បដិសម្ភិទា។ នេះជាសច្ចវារៈ។

(៣) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា។ សេចក្ដីដឹងហេតុ ឈ្មោះថាធម្មប្បដិសម្ភិទា, សេចក្ដីដឹងផលនៃហេតុ ឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្ដីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងធម៌និងអត្ថនោះ ឈ្មោះថានិរុត្តិប្បដិសម្ភិទា, សេចក្ដីដឹងក្នុងញាណទាំងឡាយ ឈ្មោះថាបដិភាណ-ប្បដិសម្ភិទា។ នេះ ជាហេតុវារៈ។

(៤) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា។ ធម៌ទាំងឡាយណា កើត ចំរើន លូតលាស់ ដុះដាល ចំរុងចំរើន កើតប្រាកដហើយ សេចក្តីដឹងក្នុងធម៌ទាំងឡាយនោះ ឈ្មោះថាអត្ថប្បដិសម្ភិទា, ធម៌ទាំងឡាយនោះ កើត ចំរើន លូតលាស់ ដុះដាល ចំរុងចំរើន កើតប្រាកដហើយ អំពីធម៌ទាំងឡាយណា សេចក្តីដឹងក្នុងធម៌ទាំងឡាយនោះ ឈ្មោះថាធម្មប្បដិសម្ភិទា, សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថានិរុត្តិប្បដិសម្ភិទា, សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថាបដិភាណ-ប្បដិសម្ភិទា ។ នេះ ជាធម្មវារៈ។

(៥) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា។ សេចក្តីដឹងក្នុងជរានិងមរណៈ ឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្តីដឹងក្នុងការកើតឡើងនៃជរានិងមរណៈ ឈ្មោះថាអត្ថប្បដិ-សម្ភិទា សេចក្តីដឹងក្នុងការរលត់នៃជរានិងមរណៈ ឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃជរានិងមរណៈ ឈ្មោះថាធម្មប្បដិសម្ភិទា,

សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថន័យធម៌នោះ ឈ្មោះថានិរុត្តិប្បដិសម្ភិទា, សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថាបដិភាណប្បដិសម្ភិទា ។

(៦) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា។ សេចក្តីដឹងក្នុងជាតិ។បេ។ សេចក្តីដឹងក្នុងភព។បេ។ សេចក្តីដឹងក្នុងឧបាទាន។បេ។ សេចក្តីដឹងក្នុងតណ្ហា ។បេ។ សេចក្តីដឹងក្នុងវេទនា។បេ។ សេចក្តីដឹងក្នុងផស្សៈ។បេ។ សេចក្តីដឹងក្នុងសឡាយតនៈ ។បេ។ សេចក្តីដឹងក្នុងនាមរូប។បេ។ សេចក្តីដឹងក្នុងវិញ្ញាណ។បេ។ សេចក្តីដឹងក្នុងសង្ខារទាំងឡាយ ឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្តីដឹងក្នុងការកើតឡើងនៃសង្ខារ ឈ្មោះថាធម្មប្បដិសម្ភិទា សេចក្តីដឹងក្នុងការរលត់នៃសង្ខារ ឈ្មោះថាអត្ថប្បដិសម្ភិទា, សេចក្តីដឹងក្នុងបដិបទា ជាដំណើរទៅកាន់ទីរលត់នៃសង្ខារ ឈ្មោះថាធម្មប្បដិសម្ភិទា, សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ ឈ្មោះថានិរុត្តិប្បដិសម្ភិទា, សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថាបដិភាណប្បដិសម្ភិទា ។ នេះ ជាបដិច្ចសមុប្បាទវារៈ។

(៧) បដិសម្ភិទា ៤ គឺ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា។ បណ្តាបដិសម្ភិទាទាំង ៤ នោះ ធម្មប្បដិសម្ភិទា តើដូចម្តេច? ភិក្ខុក្នុងសាសនានេះ ដឹងនូវធម៌ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ, នេះគេហៅថា ធម្មប្បដិសម្ភិទា។ ភិក្ខុនោះ ដឹងនូវសេចក្តីនៃភាសិតនោះៗ ថា "នេះសេចក្តីនៃភាសិតនេះ, នេះសេចក្តីនៃភាសិតនេះ", នេះគេហៅថា អត្ថប្បដិសម្ភិទា ។ សេចក្តីដឹងក្នុងការពោលនូវធម្មនិរុត្តិ ក្នុងអត្ថនិងធម៌នោះ, នេះគេហៅថា និរុត្តិប្បដិសម្ភិទា។ សេចក្តីដឹងក្នុងញាណទាំងឡាយ នេះគេហៅថា បដិភាណប្បដិសម្ភិទា។ នេះ ជាបរិយត្តិវារៈ។[14]

# សម្មោហវិនោទនី

## *ពណ៌នាសង្ខេបវារៈ*

ពាក្យថា "**បដិសម្ភិទា**" បានដល់ បភេទ (ដែលជាឈ្មោះរបស់ញាណ = ការដឹង, សេចក្តីដឹង), អធិប្បាយថា

14 អភិ.វិ.បដិសម្ភិទាវិភង្គ។

ក៏ព្រោះខាងមុខនេះ ព្រះមានព្រះភាគត្រាស់ទុកថា "អត្ថេ ញាណំ អត្ថប្បដិសម្ភិទា = ញាណក្នុងអត្ថ ឈ្មោះថាអត្ថប្ប-ដិសម្ភិទា"ជាដើម, ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបថា មិនមែនជាការដឹង របស់អ្នកដទៃទេឡើយ, គឺជាការដឹងរបស់ញាណតែប៉ុណ្ណោះ, ដោយប្រការដូច្នោះ ទើបខ្ញុំសង្គ្រោះសេចក្តីនេះថា **ការដឹងរបស់ញាណ៤** នេះ ចុះក្នុងបទថា "**បដិសម្ភិទា៤**" បដិសម្ភិទាក្នុងអត្ថ ឈ្មោះថា **អត្ថប្បដិ-សម្ភិទា**, អធិប្បាយថា ញាណ គឺសេចក្តីដឹងក្នុងអត្ថ ដើម្បីអាចធ្វើការវិគ្រោះ (បែងចែក) អត្ថប្រភេទផ្សេងៗ ឲ្យជាក់ច្បាស់ដោយការពិចារណា។ សូម្បីក្នុងបទដែលនៅសល់ ក៏ន័យនេះដែរ។ ពិតមែន ញាណ គឺសេចក្តីដឹងក្នុងអត្ថ ក្នុងធម៌ ដើម្បីអាចធ្វើការវិគ្រោះធម្មជាតិផ្សេងៗ ឲ្យជាក់ច្បាស់ក្នុងការពិចារណា ឈ្មោះថា**ធម្មប្បដិសម្ភិទា**, ញាណ គឺសេចក្តីដឹងក្នុងអត្ថ ក្នុងការពោលនូវនិរុត្តិធម៌ ដើម្បីអាចធ្វើការវិគ្រោះនិរុត្តិ (គឺភាសាផ្សេងៗ) ឲ្យជាក់ច្បាស់ដោយការពិចារណា ឈ្មោះថា**និរុត្តិប្បដិសម្ភិទា**។ ញាណ គឺសេចក្តីដឹងក្នុងអត្ថ ក្នុងបដិភាណ (គឺឈ្លាសវៃក្នុងការឆ្លើយតបបានទាន់ពេល) ដើម្បីអាចធ្វើវិគ្រោះបដិភាណប្រភេទផ្សេងៗ ឲ្យជាក់

ច្បាស់ក្នុងការពិចារណា ឈ្មោះថា**បដិភាណប្បដិសម្ភិទា**។

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ចែកសម្តែងបដិសម្ភិទាទាំងឡាយ តាមដែលទ្រង់ត្រាស់ទុក ទើបត្រាស់ពាក្យថា "**អត្ថេ ញាណំ អត្ថប្បដិសម្ភិទា**"ជាដើម។ បណ្តាពាក្យទាំងនោះ ពាក្យថា "**អត្ថះ**" កាលពោលដោយសង្ខេប បានដល់ ផលរបស់ហេតុ (ផលដែលកើតពីហេតុ)។ ពិតមែន ផលនៃហេតុនោះ គប្បីជារបស់ស្ងប់ (គឺប្រាសចាកកិលេស) គប្បីដល់ គប្បីសម្រេចបាន ដោយអំណាចនៃហេតុ, ព្រោះហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា **អត្ថះ**។ កាលពោល ដោយប្រភេទហើយ បណ្ឌិតគប្បីជ្រាបថា បានដល់ធម៌៥នេះ គឺៈសភាវៈណាមួយ ដែលអាស្រ័យគ្នាកើតឡើង ព្រោះបច្ច័យ១ ព្រះនិព្វាន១ អត្ថនៃភាសិត១ វិបាក១ កិរិយា១ ។ កាលពិចារណាអត្ថនោះហើយ ញាណ គឺសេចក្តីដឹង ក្នុងអត្ថនោះៗ ឈ្មោះថាអត្ថប្បដិសម្ភិទា។

ពាក្យថា "**ធម្មះ**" កាលពោលដោយសង្ខេប បានដល់បច្ច័យ។ ពិតមែន ព្រោះបច្ច័យនោះ រមែងចាត់ចែង រមែងឲ្យធម៌នោះៗ ប្រព្រឹត្តទៅផង ឲ្យដល់ផង, ព្រោះ

ហេតុដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ហៅថា ធម្មៈ, តែកាលពោលដោយប្រភេទហើយ បណ្ឌិតគប្បីជ្រាបថា បានដល់ ធម៌ទាំង៥នេះ គឺហេតុណាមួយ ដែលញ៉ាំងផលឲ្យកើតឡើង១ អរិយមគ្គ១ ភាសិត (វាចាដែលពោលហើយ)១ កុសល១ អកុសល១ ។ កាលពិចារណាធម៌នោះហើយ ញាណ គឺសេចក្ដីដឹងក្នុងធម៌នោះ ឈ្មោះថាធម្មប្បដិសម្ភិទា។

គប្បីជ្រាបវិនិច្ឆ័យក្នុង៦ថា **ញាណក្នុងការពោលនូវធម្មនិរុត្តិ** ដូច្នេះ៖ សភាវនិរុត្តិ (ភាសារបស់សភាវៈ) យ៉ាងណា រមែងប្រព្រឹត្តទៅក្នុងអត្ថផង ក្នុងធម៌ផង, កាលពិចារណាធ្វើស័ព្ទ (សម្លេង) ដែលជាសភាវនិរុត្តិនោះ ក្នុងការពោលយ៉ាងនោះ ញាណ គឺសេចក្ដីដឹង ក្នុងពាក្យនិយាយដែលជាសភាវនិរុត្តិនោះ ឈ្មោះថានិរុត្តិប្បដិសម្ភិទា។ និរុត្តិប្បដិសម្ភិទានេះ កើតឡើងដោយអាការយ៉ាងនេះ ឈ្មោះថា មានសម្លេងជាអារម្មណ៍, មិនឈ្មោះថា មានបញ្ញត្តិជាអារម្មណ៍ទេ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះស្ដាប់សម្លេងហើយរមែងដឹងថា "នេះជាសភាវនិរុត្តិ, នេះមិនមែនជាសភាវនិរុត្តិទេ"។ ពិតមែន អ្នកសម្រេចបដិសម្ភិទានោះ កាលមានអ្នកពោលថា

"**ផស្សោ**" ដូច្នេះ រមែងដឹងថា "នេះជាសភាវនិរុត្តិ", ឬថា កាលអ្នកដទៃពោលថា "**ផស្សា**" ឬ "**ផស្សំ**" ដូច្នេះ ក៏រមែងដឹងថា "នេះមិនមែនជាសភាវនិរុត្តិ", សូម្បីក្នុងវេទនាជាដើម ក៏ន័យនេះដែរ។ សួរថា ក៏អ្នកសម្រេចបដិសម្ភិទានោះរមែងដឹង ឬរមែងមិនដឹងនូវសម្លេងនៃព្យញ្ជនៈ ដែលជានាម អាខ្យាត និងឧបសគ្គដទៃៗឬ? ឆ្លើយថា ក្នុងកាលណា ស្តាប់សម្លេងចំពោះមុខ រមែងដឹងថា "នេះជាសភាវនិរុត្តិ, នេះមិនមែន" ក្នុងកាលនោះ នឹងដឹងបានសូម្បីនូវពាក្យនោះតាំងពីដើម។ តែសេចក្តីនេះ មានអ្នកជំទាស់ថា "នេះមិនមែនជាកិច្ចរបស់បដិសម្ភិទា" ដូច្នេះ ហើយបានលើកយករឿងព្រះថេរៈមកពោលថា៖

បានឮថា ព្រះតិស្សទត្តត្ថេរ កាន់យកស្លាកដែលជាវិការៈនៃមាសត្រង់ពោធិមណ្ឌដ្ឋាន ហើយបវារណា (គឺសម្គាល់សេចក្តីថាបើកឱកាស ឬអនុញ្ញាតឲ្យភិក្ខុស្តាប់ភាសាផ្សេងៗ តាមដែលត្រូវការ) ដល់ភិក្ខុទាំងឡាយ ដោយពាក្យថា "ក្នុងបណ្តាភាសា១៨ ខ្ញុំនឹងពោលដោយភាសាណា" ដូច្នេះ, ក៏ពាក្យបវារណានោះ ព្រះថេរៈលោកតាំងនៅក្នុងការសិក្សារបស់ខ្លួន ទើបបានបវារណា, មិនមែនតាំងនៅក្នុងបដិ

សម្ពិទា ហើយពោលបវារណាទេ។ ព្រោះថាព្រះថេរៈនោះ លោកឲ្យបុគ្គលប្រាប់ហើយៗ លោកក៏រៀនយកភាសានោះៗ ព្រោះភាវៈនៃលោកជាអ្នកមានបញ្ញាច្រើន, បន្ទាប់ពីនោះមក ទើបលោកបវារណាយ៉ាងនេះ ព្រោះតាំងនៅហើយក្នុងការ សិក្សារៀនសូត្រ។

ក៏ឯគ្រាលោកពោលហើយ ទើបពោលពាក្យក្នុងទីនេះ តទៅទៀតថា "ធម្មតាថា សត្វទាំងឡាយក៏រមែងរៀនភាសា" ដូច្នេះ, ពិតមែន មាតានិងបិតាឲ្យកូនតូចដេកលើគ្រែ ឬលើ តាំងក្នុងវេលាដែលកូននៅជាទារក ហើយនិយាយនូវកិច្ច នោះៗ ធ្វើនូវកិច្ចនោះៗ, ក្មេងទាំងឡាយរមែងកំណត់ភាសា នោះៗ របស់មាតា ឬបិតាថា "ពាក្យនេះ អ្នកនេះពោល ហើយ, ពាក្យនោះ អ្នកនោះពោលហើយ" កាលកន្លងទៅៗ ពួកក្មេងៗ រមែងដឹងភាសាសូម្បីទាំងអស់។ មាតាជាអ្នក ស្រុកទមិឡ, បិតាជាអ្នកស្រុកអន្ធកៈ, ក្មេងដែលកើតអំពីជន ទាំងពីរនោះ បើគេស្តាប់ពាក្យរបស់មាតាមុន, គេនឹងនិយាយ ភាសាទមិឡមុន, បើស្តាប់ពាក្យរបស់បិតាមុន, គេនឹងពោល ភាសាអ្នកស្រុកអន្ធកៈមុន។ តែកាលមិនបានស្តាប់ពាក្យ របស់ជនសូម្បីទាំងពីរ ក៏នឹងពោលមាគធភាសា (ភាសា

របស់អ្នកស្រុកមគធៈ)។ សូម្បីទារកណាកើតក្នុងព្រៃធំ មិនមានផ្ទះ (មិនមានភូមិ), អ្នកដទៃ ឈ្មោះថាពោលហើយមិនមានក្នុងព្រៃធំនោះ, សូម្បីទារកនោះ កាលនឹងញ៉ាំងវាចាឲ្យតាំងឡើង តាមធម្មតារបស់ខ្លួន ក៏នឹងពោលមាគធភាសានោះនុ៎ះឯង។ មាគធភាសាប៉ុណ្ណោះ ប្រើច្រើនសន្ធឹកសន្ធាប់ (ជាភាសាយាន) ក្នុងទីទាំងពួង គឺនិរយៈ (នរក) កំណើតនៃសត្វតិរច្ឆាន (មានសត្វដំរីជាដើម) ប្រេតវិស័យ (កំណើតប្រេត) មនុស្សលោក ទេវលោក។ ក្នុងភាសារបស់សត្វទាំងឡាយ ភាសា១៨ ក្រៅអំពីមាគធភាសា មានភាសារបស់មនុស្សព្រៃ អ្នកស្រុកអន្ធកៈ អ្នកស្រុកយោនកៈ អ្នកស្រុកទមិឡៈ តាមដែលពោលហើយជាដើម រមែងប្រែប្រួលទៅ[15], មាគធភាសា ពោលគឺជាវោហាររបស់ព្រហ្ម ជាវោហាររបស់ព្រះអរិយៈ តាមសេចក្ដីពិត ភាសានេះតែមួយប៉ុណ្ណោះមិនផ្លាស់ប្ដូរប្រែប្រួល, សូម្បីព្រះសម្មាសម្ពុទ្ធ កាលទ្រង់នឹងលើកព្រះត្រៃបិដក គឺព្រះពុទ្ធវចនៈឡើងកាន់តន្តិ (បែបផែន) ក៏ទ្រង់លើកឡើងដោយមាគធភាសាដែរ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ក៏ព្រោះដើម្បីនឹងនាំមកនូវអត្ថ(ប្រយោជន៍)

---

15 ជួនកាលមាន ជួនកាលមិនមាន។

បានដោយងាយ។ ពិតមែន ការចូលដល់គន្លងក្រសែនៃព្រះពុទ្ធវចនៈ ដែលលើកឡើងកាន់តន្តិ ដោយមាគធភាសា រមែងមានមកយ៉ាងពិស្តារ ដល់អ្នកសម្រេចបដិសម្ភិទាទាំងឡាយ។ គឺថាកាលក្រសែនៃព្រះពុទ្ធវចនៈនោះ គ្រាន់តែអ្នកសម្រេចបដិសម្ភិទាហើយភ្លាមនុ៎ះឯង អត្ថរមែងមកប្រាកដរាប់រយន័យ រាប់ពាន់ន័យ។ ក៏កាលបុគ្គលអ្នកត្រាច់ទៅហើយៗ រៀនយកនូវព្រះពុទ្ធវចនៈ ដែលលើកឡើងកាន់បែបផែន ដោយភាសាដទៃមានហើយ, តែឈ្មោះថាការសម្រេចបដិសម្ភិទារបស់បុថុជ្ជន ព្រោះរៀនយកពុទ្ធវចនៈនោះ សូម្បីច្រើន ក៏មិនមាន។ ព្រះអរិយសាវ័កដែលមិនសម្រេចបដិសម្ភិទា មិនមានទេ។

ពាក្យថា "**ញាណេសុ ញាណំ** = សេចក្តីដឹងក្នុងញាណទាំងឡាយ" បានដល់ កាលលោកពិចារណាធ្វើញាណក្នុងទីទាំងពួង ឲ្យជាអារម្មណ៍ហើយ ញាណដែលដល់សេចក្តីដឹងផ្សៀវឆ្លាស ឈ្មោះថាបដិភាណប្បដិសម្ភិទា។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា បដិសម្ភិទាទាំង៤នេះ រមែងដល់ការញែកចេញក្នុងឋាន (ភូមិ) ២យ៉ាង, និងរមែងបរិសុទ្ធដោយហេតុ៥យ៉ាង។ សួរថា បដិសម្ភិទា៤

រមែងដល់ការញែកចេញក្នុងឋាន២ គឺអ្វីខ្លះ? ឆ្លើយថា ក្នុងឋាន២ គឺៈ សេក្ខភូមិ និងអសេក្ខភូមិ។ ក្នុងឋានទាំង២នោះ សូម្បីបដិសម្ភិទារបស់ព្រះមហាថេរៈទាំង៨០រូប ដល់ប្រភេទអសេក្ខភូមិ បានដល់ បដិសម្ភិទារបស់ព្រះសារីបុត្តត្ថេរ ព្រះមហាមោគ្គល្លានត្ថេរ ព្រះមហាកស្សបត្ថេរ ព្រះមហាកច្ចាយនត្ថេរ ព្រះមហាកោដ្ឋិតត្ថេរជាដើម។ បដិសម្ភិទារបស់អ្នកដល់សេក្ខភូមិ គឺបានដល់ បដិសម្ភិទារបស់ព្រះអានន្ទត្ថេរ ចិត្តគហបតី ធម្មិកឧបាសក ឧបាលិគហបតី នាងខុជ្ជុត្តរាឧបាសិកាជាដើម បដិសម្ភិទាទាំងឡាយ រមែងដល់ការញែកចេញ ក្នុងភូមិទាំងពីរនេះ ដោយប្រការដូច្នេះ។ សួរថា បដិសម្ភិទាទាំងឡាយ ជាធម្មជាតិបរិសុទ្ធដោយហេតុ៥យ៉ាង គឺអ្វីខ្លះ? ឆ្លើយថា ដោយអធិគម១ បរិយត្តិ១ សវនៈ១ បរិបុច្ឆា១ បុព្វយោគ១។ ក្នុងហេតុទាំង៥នោះ ព្រះអរហត្តឈ្មោះថា**អធិគមៈ**, ពិតមែន កាលសម្រេចអរហត្តហើយ បដិសម្ភិទាទាំងឡាយ ជាធម្មជាតិបរិសុទ្ធ។ ព្រះពុទ្ធវចនៈឈ្មោះថា**បរិយត្តិ**, ពិតមែន ការរៀនយកនូវព្រះពុទ្ធវចនៈ បដិសម្ភិទាទាំងឡាយ ជាធម្មជាតិបរិសុទ្ធ។ ការស្តាប់ធម៌ឈ្មោះថា**សវនៈ**, ពិតមែន កាលស្តាប់ព្រះធម៌ដោយគោរព

បដិសម្ភិទាទាំងឡាយ ជាធម្មជាតិបរិសុទ្ធ។ អដ្ឋកថា ឈ្មោះថា**បរិបុច្ឆា**, ពិតមែន កាលពោលនូវអត្ថនៃព្រះបាលីដែលខ្លួនរៀនមកហើយ បដិសម្ភិទាទាំងឡាយ ជាធម្មជាតិបរិសុទ្ធ។ ភាពជាព្រះយោគាវចរក្នុងកាលមុន គឺសេចក្តីដែលកម្មដ្ឋានដែលខ្លួនរក្សាហើយ ដោយន័យនៃការនាំកម្មដ្ឋានទៅ និងការនាំកម្មដ្ឋានត្រឡប់មក (ហរណបច្ចាហរណវត្ត) ក្នុងអតីតភព ឈ្មោះថា**បុព្វយោគ**, ពិតមែន កាលធ្លាប់ចុះកាន់ (ការឈានចុះ) សេចក្តីព្យាយាមមកហើយ ក្នុងកាលមុន បដិសម្ភិទាទាំងឡាយ ក៏ជាធម្មជាតិបរិសុទ្ធ។

បណ្តាហេតុទាំង៥នោះ គប្បីជ្រាបបដិសម្ភិទាទាំងឡាយ ព្រះតិស្សត្ថេរ អ្នកជាបុត្រនៃកុដុម្ពិក៍ ឈ្មោះបុនព្វសុ បានជាធម៌បរិសុទ្ធហើយ ដោយការសម្រេចព្រះអរហត្ត មានរឿងនិទានទុកថា៖ បានឮថា ព្រះតិស្សត្ថេរនោះ រៀនព្រះពុទ្ធវចនៈក្នុងតម្ពបណ្ណិទ្វីប (គឺក្នុងកោះរបស់ជនអ្នកមានបាតដៃក្រហម ឬហៅម្យ៉ាងទៀតថាលង្កាទ្វីប) ហើយទៅកាន់ត្រើយដទៃ រៀនយកពុទ្ធវចនៈ ក្នុងសំណាក់របស់ព្រះធម្មរក្ខិតត្ថេរ អ្នកស្រុកយោនកៈ សម្រេចពីការរៀន ក៏ដើរផ្លូវមកដល់កំពង់ជាទីឡើងទូក កើតសេចក្តីសង្ស័យក្នុងព្រះ

ពុទ្ធវចនៈមួយបទ ទើបធ្វើដំណើរត្រឡប់មកផ្លូវដើមវិញ ប្រមាណ១០០យោជន៍ កាលទៅកាន់សំណាក់របស់អាចារ្យ ក្នុងចន្លោះផ្លូវបានបកស្រាយបញ្ហាដល់កុដុម្ពិក៍ម្នាក់, កុដុម្ពិក៍ម្នាក់នោះ មានសេចក្តីជ្រះថ្លា បានថ្វាយសំពត់កម្ពលមានតម្លៃមួយសែន, ព្រះតិស្សត្ថេរនោះនាំសំពត់មកថ្វាយអាចារ្យ, អាចារ្យរបស់លោក ទម្លាយសំពត់ដែលមានតម្លៃមួយសែននោះ ដោយកាំបិត ហើយឲ្យធ្វើជារបស់ប្រើប្រាស់ក្នុងទីសម្រាប់អង្គុយ។ សួរថា ការដែលអាចារ្យធ្វើយ៉ាងនោះ ដើម្បីប្រយោជន៍អ្វី? ឆ្លើយថា ដើម្បីអនុគ្រោះ ដល់ប្រជុំជនជំនាន់ក្រោយ។ បានឮថា អាចារ្យនោះ មានបរិវិតក្កៈថា "ក្នុងអនាគតកាលសព្រហ្មចារីទាំងឡាយ និងសម្គាល់ដល់ការបដិបត្តិដែលខ្លួនឲ្យបរិបូណ៌ហើយ ដោយការពិចារណាដល់មគ្គដែលពួកយើងសម្រេចហើយ (មិនមែនមានសេចក្តីកង្វល់យ៉ាងដទៃទេ)"។ សូម្បីព្រះតិស្សត្ថេរ ក៏កាត់សេចក្តីសង្ស័យបានក្នុងសំណាក់របស់អាចារ្យហើយទើបទៅ លោកឈានចុះត្រង់កំពង់នៃប្រទេសឈ្មោះជម្ពុកោលៈ ដល់វិហារឈ្មោះថាវាលិកៈ ក្នុងវេលាដែលបោសលានព្រះចេតិយ លោកក៏បោសលានព្រះចេតិយ។ ព្រះថេរៈទាំងឡាយ

ឃើញទីជាទីដែលព្រះតិស្សត្ថេរនោះបោសហើយ ទើបគិតថា "ទីនេះ ជាទីបោសសំអាត ដែលភិក្ខុមានរាគៈទៅប្រាស ហើយ ធ្វើការបោសសំអាត" តែដើម្បីត្រូវការសាកល្បង ទើបសួរបញ្ហាផ្សេងៗ, ព្រះតិស្សត្ថេរនោះ ក៏ដោះស្រាយបញ្ហា ដែលភិក្ខុនោះ សួរហើយគ្រប់ៗបញ្ហា ព្រោះខ្លួនជាអ្នកសម្រេចបដិសម្ភិទាទាំងឡាយហើយ។

រីឯបដិសម្ភិទារបស់ព្រះតិស្សត្ថេរ និងព្រះនាគសេនត្ថេរ បានបរិសុទ្ធហើយ ដោយបរិយត្តិ។ បដិសម្ភិទារបស់សុធម្ម-សាមណេរ បានបរិសុទ្ធហើយ ព្រោះការស្តាប់ធម៌ដោយគោរព។ បានឮថា សាមណេរនោះ ជាក្មួយរបស់ព្រះធម្មទិន្នត្ថេរ អ្នកនៅក្នុងតឡង្គរវាសី ក្នុងខណៈដែលកោរសក់ស្រេច ក៏សម្រេចព្រះអរហន្ត, កាលលោកកំពុងស្តាប់ធម៌ក្នុងរោងវិនិច្ឆ័យធម៌ របស់ព្រះថេរៈអ្នកជាឪពុកធំនោះឯង បានជាអ្នកជំនាញព្រះត្រៃបិដកហើយ។ បដិសម្ភិទារបស់ព្រះតិស្សត្ថេរ អ្នកពោលអត្ថ (បរិបុច្ឆា) ដោយព្រះបាលីដែលខ្លួនរៀនមក បានជាអ្នកបរិសុទ្ធហើយ។ ម្យ៉ាងទៀត ទីបំផុតនៃព្រះយោគាវចរក្នុងកាលមុន បំពេញគតបច្ចាគតវត្ត (ការ

នាំកម្មដ្ឋានទៅនិងការនាំកម្មដ្ឋានត្រឡប់មក) ហើយខ្វល់ខ្វាយចម្រើននូវកម្មដ្ឋានដ៏សមគួរ មានបដិសម្ភិទា ដែលដល់សេចក្ដីបរិសុទ្ធហើយ រមែងមិនមាន ។

ក៏បណ្ដាហេតុទាំង៥នោះ ហេតុទាំង៣នេះ គឺៈ បរិយត្តិ សវនៈ និងបរិបុច្ឆា ជាហេតុ (គ្រឿងធ្វើ) ដែលមានកម្លាំងនៃបញ្ញាជាគ្រឿងបែកធ្លាយ។ បុព្វយោគ ជាបច្ច័យដ៏មានកម្លាំង) នៃអធិគមៈ (ការសម្រេចព្រះអរហត្ត)។ សួរថា បុព្វយោគ ជាបច្ច័យនៃបញ្ញាជាគ្រឿងបែកធ្លាយ ឬមិនជាបច្ច័យទេ? ឆ្លើយថា ជាបច្ច័យ, តែមិនជាបច្ច័យដ៏មានកម្លាំងដូច្នោះទេ។ ព្រោះថាបរិយត្តិសវនៈនិងបរិបុច្ឆា ក្នុងកាលមុនមាន ឬមិនមានក៏ដោយ, តែកាលពោលដោយបុព្វយោគហើយ វៀរការពិចារណាសង្ខារទាំងឡាយ ក្នុងកាលមុនផងក្នុងកាលបច្ចុប្បន្នផង ឈ្មោះថាបដិសម្ភិទាទាំងឡាយ រមែងមិនមានទេ។ ម្យ៉ាងទៀត បុព្វយោគក្នុងកាលមុន និងក្នុងកាលបច្ចុប្បន្ននេះ កាលរួមគ្នាចូលមកឧបត្ថម្ភហើយ រមែងធ្វើបដិសម្ភិទាឲ្យបរិសុទ្ធ។

### *ពណ៌នាសច្ចវារៈជាដើម*

ឥឡូវនេះ ដើម្បីចែកបដិសម្ភិទាទាំងឡាយ ដោយន័យនៃការសម្តែងប្រភេទនៃការសង្គ្រោះអត្ថ និងធម៌ទាំង៥វារៈពួកណាមួយ ក្នុងសង្គហវារៈ, ទើបព្រះមានព្រះភាគ ផ្តើមប្រភេទវារៈ (គឺវារៈដែលមានប្រភេទផ្សេងគ្នា) ដោយន័យជាដើមថា "**ចតស្សោ** = បដិសម្ភិទា៤" ដូច្នេះទៀត។ វារៈនោះមាន៥យ៉ាង ដោយអំណាចនៃសច្ចវារៈ ហេតុវារៈធម្មវារៈ បច្ចយាការវារៈ និងបរិយត្តិវារៈ។ ក្នុងវារៈទាំងនោះព្រះមានព្រះភាគត្រាស់ **សច្ចវារៈ** ទុក ក៏ដើម្បីសម្តែងដល់ព្រះនិព្វានជាធម៌ដែលសម្រេចបានដោយបច្ច័យនៃទុក្ខដែលអាស្រ័យគ្នា ហើយកើតឡើងថា ជាអត្ថ និងដើម្បីសម្តែងដល់អរិយមគ្គ ដែលនាំមកនូវព្រះនិព្វាន ដែលជាហេតុញុំាងផលឲ្យកើតឡើងថាជាធម្ម។ ព្រះមានព្រះភាគត្រាស់ថាហេតុវារៈ[16] ទុកក៏ដើម្បីសម្តែងដល់ហេតុទាំងឡាយ ដែលញុំាងផលយ៉ាងណាមួយឲ្យកើតថា **ជាធម្មៈ** និងដើម្បីសម្តែងដល់ផលរបស់ហេតុថាជាអត្ថ ក្នុងសេចក្តីនេះ ព្រះភគវាទ្រង់លើកធម្មប្បដិសម្ភិទាឡើងពន្យល់មុន ដោយមិនប្រព្រឹត្តទៅ

16 បដិសម្ភិទា៤ គឺៈ អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទា ព្រះមានបុណ្យអធិប្បាយធម្មៈ (ហេតុ) មុន អត្ថៈ។

តាមរបៀបដែលពោលដោយលំដាប់នៃហេតុ និងផលដែលទ្រង់តាំងទុកទេ។ ម្យ៉ាងទៀត ធម៌ពួកណាដែលផ្សេងដោយរូប និងអរូបធម៌ (ខន្ធ៥) ដែលកើតឡើងហើយ មានហើយពីហេតុនោះៗ, ដើម្បីសម្ដែងនូវធម៌ទាំងនោះថា ជាអត្ថ និងដើម្បីសម្ដែងនូវហេតុដែលជាទីកើតឡើងនៃរូប និងអរូបធម៌នោះៗ ថា ជាធម្មៈ ទើបព្រះមានព្រះភាគត្រាស់ធម្មវារៈទុក។ ក៏ដើម្បីសម្ដែងនូវធម៌មានជរា និងមរណៈជាដើមថា ជាអត្ថ (អត្ថប្បដិសម្ភិទា) និងនូវធម៌ គឺជាតិ (ការកើត) ពោលគឺហេតុកើតឡើងនៃជរា និងមរណៈជាដើម ទើបព្រះមានព្រះភាគត្រាស់ **បច្ចយាការវារៈ**។

លំដាប់នោះ ដើម្បីសម្ដែងនូវភាសិតនោះៗ ពោលគឺព្រះបរិយត្តិ និងនូវសេចក្ដីនៃអត្ថភាសិត ដែលគប្បីសម្រេចបានដោយបច្ច័យ ពោលគឺភាសិត ទើបព្រះមានព្រះភាគត្រាស់ **បរិយត្តិវារៈ**, ក្នុងសេចក្ដីនេះ អត្ថនៃភាសិតនោះដែលនឹងគប្បីដឹងបាន រមែងដឹងបានដោយភាសិត, ព្រោះហេតុដូច្នោះ ទើបព្រះអង្គទ្រង់លើកធម្មប្បដិសម្ភិទាឡើងពន្យល់សម្ដែងមុនអត្ថប្បដិសម្ភិទា ដោយមិនបានសម្ដែងទៅតាមលំដាប់ នៃភាសិតដែលព្រះអង្គត្រាស់ទុកហើយៗ។

ម្យ៉ាងទៀត ដើម្បីសម្ដែងប្រភេទនៃព្រះបរិយត្តិធម៌ថា "ក្នុងបដិសម្ភិទាទាំង៤នោះ ធម្មប្បដិសម្ភិទា តើដូចម្ដេច?"។ ទើបត្រាស់បដិនិទ្ទេសវារៈ (គឺវារៈដែលបែរត្រឡប់មកពន្យល់) មានពាក្យសួរជាប្រធាន។ ក្នុងវារៈបែរត្រឡប់មកពោលពន្យល់នោះ ទ្រង់កាន់យកបែបផែនទាំងអស់ ដោយមិនមានសល់ដោយអង្គ៩ ដែលមានពាក្យថាសុត្តៈជាដើមជាធម្មប្បដិសម្ភិទា, ទ្រង់កាន់យកបែបផែនទាំងអស់ ដោយអស់ជើង ដោយការសម្ដែងមិនឲ្យនៅសល់ ដោយអំណាចនៃភាសិត សូម្បីក្នុងទីនេះថា "**នេះជាអត្ថនៃភាសិតនេះ, នេះជាអត្ថនៃភាសិតនេះ**" ជាអត្ថប្បដិសម្ភិទា ដូច្នេះឯង[17]។

ការធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា៤ នេះ រមែងមានតែក្នុងពុទ្ធុប្បាទ វៀរចាកពុទ្ធុប្បាទហើយ រមែងមិនមាន។ អត្ថថា ការធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទាទាំងនុ៎ះ គប្បីជ្រាបថាទ្រង់ត្រាស់ហើយ ទាំងលោកិយៈទាំងលោកុត្តរៈដែរ។

បទថា **អនេកធាតុបដិវេធោ** សេចក្ដីថា ការចាក់ធ្លុះនូវធាតុទាំង១៨ គឺចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ

17 សម្មោហវិនោទនី អដ្ឋកថានដសម្ភិទាវិភង្គ។

ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ, កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ និងមនោវិញ្ញាណធាតុ រមែងមានតែក្នុងពុទ្ធុប្បាទ, វៀរចាកពុទ្ធុប្បាទហើយ រមែងមិនមាន។

ធាតុទាំង១៨ នេះ ក្នុងបទថា **នានាធាតុបដិវេធោ** គប្បីជ្រាបថា ជាធាតុផ្សេងៗគ្នា ព្រោះជាសភាវៈផ្សេងៗគ្នា។ ក៏ការចាក់ធ្លុះឯណា នូវធាតុទាំងនោះ ដោយហេតុផ្សេងៗយ៉ាងនេះថា "ធាតុទាំងនេះ មានសភាវៈផ្សេងគ្នា", នេះឈ្មោះថាការរចាក់ធ្លុះនូវធាតុផ្សេងគ្នា។

ញាណក្នុងផល ឈ្មោះថា**វិជ្ជា** ក្នុងបទនេះថា **វិជ្ជា-វិមុត្តិផលសច្ឆិកិរិយា**, **វិមុត្តិ** បានដល់ ធម៌ទាំងឡាយដែលសម្បយុត្តដោយផល សល់អំពីវិជ្ជានោះ។

បទថា **សោតាបត្តិផលសច្ឆិកិរិយា** សេចក្តីថា បឋមមគ្គលោកហៅថាសោតៈ, ផលដែលបុគ្គលគប្បីដល់ ដោយសោតៈនោះ ព្រោះហេតុនោះ ទើបឈ្មោះថាសោតាបត្តិផល។ **សកទាគាមិផលជាដើម** ប្រាកដច្បាស់មែនពិត។

អដ្ឋកថាសូត្រទី៦-១៧ ចប់។

**១៨៧. អនុត្តរន្តិ** និរុត្តរំ។ **ធម្មចក្កន្តិ** សេដ្ឋចក្កំ។ ចក្កសទ្ទោ ហេស –

''ចតុព្ភិ អដ្ឋជ្ឈគមា, អដ្ឋាហិបិ ច សោឡស;
សោឡសាហិ ច ពាត្តិំស, អត្រិច្ឆំ ចក្កមាសទោ;
ឥច្ឆាហតស្ស បោសស្ស, ចក្កំ ភមតិ មត្ថកេ''តិ។ (ជា. ១.១.១០៤; ១.៥.១០៣) –

ឯត្ថ ឧរចក្កេ អាគតោ។ ''ចក្កសមារុឡ្ហា ជានបទា បរិយាយន្តី''តិ (អ. និ. ៣.៦៣; ៥.៥៤) ឯត្ថ ឥរិយាបថចក្កេ។ ''អថ ខោ សោ, ភិក្ខវេ, រថការោ យំ តំ ចក្កំ ឆហិ មាសេហិ និដ្ឋិតំ, តំ បវត្តេសី''តិ (អ. និ. ៣.១៥) ឯត្ថ ទារុចក្កេ។ ''អទ្ទសា ខោ ទោណោ ព្រាហ្មណោ ភគវតោ បាទេសុ ចក្កានិ សហស្សារានី''តិ (អ. និ. ៤.៣៦) ឯត្ថ លក្ខណចក្កេ។ ''ចត្តារិមានិ, ភិក្ខវេ, ចក្កានិ, យេហិ សមន្នាគតានំ ទេវមនុស្សានំ ចតុចក្កំ វត្តតី''តិ (អ. និ. ៤.៣១) ឯត្ថ សម្បត្តិចក្កេ។ ''ទិព្ពំ ចក្ករតនំ បាតុភវតី''តិ (ទី. និ. ២.២៤៣; ម. និ. ៣.២៥៦) ឯត្ថ រតនចក្កេ។ ឥធ បន ធម្មចក្កេ អាគតោ។

**បវត្តិតន្តិ** ឯត្ថ ធម្មចក្កំ អភិនីហរតិ នាម, អភិនីហដំ នាម, ឧប្បាទេតិ នាម, ឧប្បាទិតំ នាម, បវត្តេតិ នាម, បវត្តិតំ នាមាតិ អយំ បភេទោ វេទិតព្ពោ។ កុតោ បដ្ឋាយ ធម្មចក្កំ **អភិនីហរតិ** នាមាតិ? យទា សុមេធព្រាហ្មណោ ហុត្វា កាមេសុ អាទីនវំ នេក្ខម្មេ ច អានិសំសំ ទិស្វា សត្តសតកមហាទានំ ទត្វា

ឥសិបព្ពជ្ជំ បព្ពជិត្វា បញ្ច អភិញ្ញា អដ្ឋ សមាបត្តិយោ និព្ពត្តេតិ, តតោ បដ្ឋាយ ធម្មចក្កំ អភិនីហរតិ នាម។

កុតោ បដ្ឋាយ **អភិនីហាដំ** នាមាតិ? យទា អដ្ឋ ធម្មេ សមោធានេត្វា ទីបង្ករបាទមូលេ មហាពោធិមណ្ឌត្ថាយ មានសំ ពន្ធិត្វា ''ព្យាករណំ អលទ្ធា ន វុដ្ឋហិស្សាមី''តិ វីរិយាធិដ្ឋានំ អធិដ្ឋាយ និបន្នោ ទសពលស្ស សន្តិកា ព្យាករណំ លភិ, តតោ បដ្ឋាយ ធម្មចក្កំ អភិនីហដំ នាម។

កុតោ បដ្ឋាយ **ឧប្បាទេតិ** នាមាតិ? តតោ បដ្ឋាយ ទានបារមី បូរេន្តោបិ ធម្មចក្កំ ឧប្បាទេតិ នាម។ សីលបារមី បូរេន្តោបិ...បេ.... ឧបេក្ខាបារមី បូរេន្តោបិ ធម្មចក្កំ ឧប្បាទេតិ នាម។ ទស បារមិយោ ទស ឧបបារមិយោ ទស បរមត្ថបារមិយោ បូរេន្តោបិ, បញ្ច មហាបរិច្ចាគេ បរិច្ចជន្តោបិ, ញាតត្ថចរិយំ បូរេន្តោបិ ធម្មចក្កំ ឧប្បាទេតិ នាម។ វេស្សន្តរត្តភាវេ ឋត្វា សត្តសតកមហាទានំ ទត្វា បុត្តទារំ ទានមុខេ និយ្យាតេត្វា បារមិកូដំ គហេត្វា តុសិតបុរេ និព្ពត្តិត្វា តត្ថ យាវតាយុកំ ឋត្វា ទេវតាហិ អាយាចិតោ បដិញ្ញំ ទត្វា បញ្ចមហាវិលោកនំ វិលោកេន្តោបិ ធម្មចក្កំ ឧប្បាទេតិយេវ នាម។ មាតុកុច្ឆិយំ បដិសន្ធឹ គណ្ហន្តោបិ, បដិសន្ធិក្ខណេ ទសសហស្សចក្កវាឡំ កម្បេន្តោបិ, មាតុកុច្ឆិតោ និក្ខន្តទិវសេ តថេវ លោកំ កម្បេន្តោបិ, សម្បតិជាតោ សត្ត បទានិ គន្ត្វា ''អគ្គោមហស្មី''តិ សីហនាទំ នទន្តោបិ, ឯកូនតិំស

សំវច្ឆរានិ អគារមជ្ឈេ វសន្តោបិ, មហាភិនិក្ខមនំ និក្ខមន្តោបិ, អនោមានទីតីរេ បព្ពជន្តោបិ, មហាបធានេ ឆព្ពស្សានិ វីរិយំ ករោន្តោបិ, សុជាតាយ ទិន្នំ មធុបាយាសំ ភុញ្ជិត្វា សុវណ្ណបាតិំ នទិយា បវាហេត្វា សាយន្ហសមយេ ពោធិមណ្ឌវរគតោ បុរត្ថិមំ លោកធាតុំ ឱលោកេន្តោ និសីទិត្វា សូរិយេ ធរមានេយេវ មារពលំ វិធមេត្វា បឋមយាមេ បុព្ពេនិវាសំ អនុស្សរន្តោបិ, មជ្ឈិមយាមេ ទិព្ពចក្ខុំ វិសោធេន្តោបិ, បច្ចូសកាលសមនន្តរេ បច្ចយាការំ សម្មសិត្វា សោតាបត្តិមគ្គំ បដិវិជ្ឈន្តោបិ, សោតាបត្តិផលំ សច្ឆិករោន្តោបិ, សកទាគាមិមគ្គំ សកទាគាមិផលំ អនាគាមិមគ្គំ អនាគាមិផលំ សច្ឆិករោន្តោបិ, អរហត្តមគ្គំ បដិវិជ្ឈន្តោបិ ធម្មចក្កំ ឧប្បាទេតិយេវ នាម។

អរហត្តផលក្ខណេ បន តេន ធម្មចក្កំ **ឧប្បាទិតំ** នាម។ ពុទ្ធានញ្ហិ សកលលោកិយលោកុត្តរគុណរាសិ អរហត្តផលេនេវ សទ្ធិំ ឥជ្ឈតិ។ តស្មា តេន តស្មិំ ខណេ ធម្មចក្កំ ឧប្បាទិតំ នាម ហោតិ។

កទា **បវត្តេតិ** នាម? ពោធិមណ្ឌេ សត្តសត្តាហំ វីតិនាមេត្វា ឥសិបតនេ មិគទាយេ អញ្ញាកោណ្ឌញ្ញត្ថេរំ កាយសក្ខិំ កត្វា ធម្មចក្កប្បវត្តនសុត្តន្តំ ទេសេន្តោ ធម្មចក្កំ បវត្តេតិ នាម។

យទា បន អញ្ញាកោណ្ឌញ្ញត្ថេរេន ទសពលស្ស ទេសនាញាណានុភាវនិព្ពត្តំ សវនំ លភិត្វា សព្ពបឋមំ ធម្មោ

អធិគតោ, តតោ បដ្ឋាយ ធម្មចក្កំ **បវត្តិតំ** នាម ហោតីតិ វេទិតព្ពំ។ ធម្មចក្កន្តិ ចេតំ ទេសនាញាណស្សបិ នាមំ បដិវេធញាណស្សបិ។ តេសុ ទេសនាញាណំ លោកិយំ, បដិវេធញាណំ លោកុត្តរំ។ កស្ស ទេសនាបដិវេធញាណន្តិ? ន អញ្ញស្ស កស្សចិ, សម្មាសម្ពុទ្ធស្សេវ ទេសនាញាណញ្ច បដិវេធញាណញ្ចាតិ វេទិតព្ពំ។

**សម្មទេវា**តិ ហេតុនា នយេន ការណេនេវ។ **អនុប្បវត្តេតី**តិ យថា បុរតោ គច្ឆន្តស្ស បច្ឆតោ គច្ឆន្តោ តំ អនុគច្ឆតិ នាម, ឯវំ បឋមតរំ សត្ថារា បវត្តិតំ ថេរោ អនុប្បវត្តេតិ នាម។ កថំ? សត្ថា ហិ ''ចត្តារោមេ, ភិក្ខវេ, សតិបដ្ឋានា។ កតមេ ចត្តារោ''តិ កថេន្តោ ធម្មចក្កំ បវត្តេតិ នាម, ធម្មសេនាបតិ សារិបុត្តត្ថេរោបិ ''ចត្តារោមេ, អាវុសោ, សតិបដ្ឋានា''តិ កថេន្តោ ធម្មចក្កំ អនុប្បវត្តេតិ នាម។ សម្មប្បធានាទីសុបិ ឯសេវ នយោ។ ន កេវលញ្ច ពោធិបក្ខិយធម្មេសុ, ''ចត្តារិមានិ, ភិក្ខវេ, អរិយសច្ចានិ។ ចត្តារោមេ, ភិក្ខវេ, អរិយវំសា''តិអាទីសុបិ អយំ នយោ នេតព្ពោវ។ ឯវំ សម្មាសម្ពុទ្ធោ ធម្មចក្កំ បវត្តេតិ នាម, ថេរោ ទសពលេន បវត្តិតំ ធម្មចក្កំ អនុប្បវត្តេតិ នាម។

ឯវំ ធម្មចក្កំ អនុប្បវត្តេន្តេន បន ថេរេន ធម្មោ ទេសិតោបិ បកាសិតោបិ សត្ថារាវ ទេសិតោ បកាសិតោ ហោតិ។ យោ ហិ កោចិ ភិក្ខុ វា ភិក្ខុនី វា ឧបាសកោ វា ឧបាសិកា វា ទេវោ វា

សក្កោ វា មារោ វា ព្រហ្មា វា ធម្មំ ទេសេតុ បកាសេតុ, សព្ពោ សោ សត្ថារា ទេសិតោ បកាសិតោវ នាម ហោតិ, សេសជនោ បន លេខហារកបក្ខេ ឋិតោវ នាម ហោតិ។ កថំ? យថា ហិ រញ្ញោ ទិន្នំ បណ្ណំ វាចេត្វា យំ យំ កម្មំ ករោន្តិ, តំ តំ កម្មំ យេន កេនចិ កតម្បិ ការិតម្បិ រញ្ញា ការិតន្តេវ វុច្ចតិ។ មហារាជា វិយ ហិ សម្មាសម្ពុទ្ធោ។ រាជបណ្ណំ វិយ តេបិដកំ ពុទ្ធវចនំ។ បណ្ណទានំ វិយ តេបិដកេ នយមុខទានំ បណ្ណំ វាចេត្វា តំតំកម្មានំ ករណំ វិយ ចតុន្នំ បរិសានំ អត្តនោ ពលេន ពុទ្ធវចនំ ឧគ្គណ្ហិត្វា បរេសំ ទេសនា បកាសនា។ តត្ថ យថា បណ្ណំ វាចេត្វា យេន កេនចិ កតម្បិ ការិតម្បិ តំ កម្មំ រញ្ញា ការិតមេវ ហោតិ, ឯវមេវ យេន កេនចិ ទេសិតោបិ បកាសិតោបិ ធម្មោ សត្ថារា ទេសិតោ បកាសិតោវ នាម ហោតីតិ វេទិតព្ពោ។ សេសំ សព្ពត្ថ ឧត្តានត្ថមេវាតិ។

ឯកបុគ្គលវគ្គវណ្ណនា។

# មនោរថបូរណី អដ្ឋកថា

# អង្គុត្តរនិកាយ ឯកកនិបាត ចប់។